# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ ២០១៦

**សេចក្តីសង្ខេបរួម**

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈការបោះឆ្នោតសភា ។ នៅក្នុងការបោះឆ្នោតកាលពីពេលថ្មីៗបំផុតនេះ ដែលរៀបចំធ្វើឡើងនៅឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជា (CPP) បានឈ្នះ ដោយប្រកិតបំផុត គិតតាំងពីឆ្នាំ ១៩៩៣ មក ដោយទទួលបានអាសនៈចំនួន ៦៨ ចំណែកគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) បានទទួលអាសនៈចំនួន ៥៥ ។ អ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាល (NGO) ក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ បានវាយតម្លៃថា ដំណើរការបោះឆ្នោតនេះមានខ្វះចន្លោះច្រើន ដូចជាបញ្ហាក្នុងការចុះឈ្មោះអ្នកបោះឆ្នោត លទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធឃោសនាមិនស្មើគ្នា ការចេញប័ណ្ណបោះឆ្នោតផ្លូវការបណ្តោះអាសន្នច្រើនមិនធម្មតាអោយអ្នកបោះឆ្នោត។ ទោះបីជាមានកង្វល់យ៉ាងនេះក្តីស្តីពីដំណើរការបោះឆ្នោត នៅទីបំផុតគណបក្សទាំងពីរបានយល់ព្រមលើលទ្ធផលផ្លូវការ ហើយបានចូលអង្គុយក្នុងសភាជាតិ។

កងកម្លាំងសន្តិសុខស្ថិតនៅក្រោមអាជ្ញាធរស៊ីវិល។

បញ្ហាធំបំផុតផ្នែកសិទ្ធិមនុស្សរួមមានការដែលតុលាការមានលក្ខណៈនយោបាយ និងគ្មានប្រសិទ្ធភាព ការរឹតត្បឹតកាន់តែច្រើនឡើងលើសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំគ្នា និងការចងក្រងគ្នាជាក្រុម មានទាំងការគំរាម ទាំងភាពជាក់ស្តែងនៃការប្រើហឹង្សា និងការដាក់ពន្ធនាគារដើម្បីសំឡុតគណបក្សប្រឆាំង និងសង្គមស៊ីវិល ព្រមទាំងដើម្បីបង្ក្រាបលើសំលេងប្រឆាំង។

បញ្ហាសិទ្ធិមនុស្សផ្សេងទៀតរួមមានការបន្តរំលោភលើអ្នកជាប់ពន្ធនាគារ ការរឹតត្បិតលើសេរីភាពសារព័ត៌មាន ការសំដែងមតិតាមអ៊ិនធ័រណែត ការខកខានមិនបានផ្តល់លទ្ធភាពស្មើគ្នា និងការប្រព្រឹត្តដោយមិនត្រឹមត្រូវលើអ្នកសុំសិទ្ធិជ្រកកោន អំពើពុករលួយដែលមានជាទូទៅ និងការជួញដូរមនុស្ស។

ទោះបីជារដ្ឋាភិបាលកាត់ទោសមន្ត្រីខ្លះដែលបានប្រព្រឹត្តបទរំលោភ រួមទាំងអ្នកដែលមានការពាក់ព័ន្ធនឹងករណីពុករលួយក្តី តែនិទណ្ឌភាពចំពោះការរំលោភភាគច្រើននៅតែមាននៅឡើយ។

**ផ្នែកទី១ ៖ ការគោរពភាពថ្លៃថ្នូររបស់មនុស្ស រួមទាំងសេរីភាពរួចផុតពី ៖**

## ក. ការដកហូតជីវិតតាមអំពើចិត្ត និងការសំលាប់ដោយសារហេតុផលនយោបាយ ឬដោយខុសច្បាប់

គ្មានរបាយការណ៍ដែលគួរអោយទុកចិត្តបានថា រដ្ឋាភិបាលឬភ្នាក់ងាររបស់រដ្ឋាភិបាលបានធ្វើឃាតតាមអំពើចិត្ត ឬដោយខុសច្បាប់ឡើយ នៅក្នុងឆ្នាំនៃរបាយការណ៍។ គ្មានភាពជឿនលឿនទៅមុខទេ នៅក្នុងការស៊ើបអង្កេតលើការសំលាប់មនុស្សដែលត្រូវបានគេចោទថា ធ្វើដោយខុសច្បាប់ នៅឆ្នាំ ២០១៤។

នៅថ្ងៃទី ១០ ខែកក្កដា ខ្មាន់កាំភ្លើងម្នាក់បានសំលាប់លោក កែម ឡី ដែលជាអ្នកវិភាគផ្នែកនយោបាយ និងសង្គមដោយមិនសំចៃមាត់និងដែលមានប្រជាប្រិយភាពម្នាក់ នៅក្នុងហាងមួយ ក្នុងរាជធានីភ្នំពេញ។ នគរបាលបានចាប់ជនសង្ស័យម្នាក់ ដែលក្រោយមកត្រូវបានគេដឹងថា មានឈ្មោះ អឿត អាង ដែលបាននិយាយថា គេសំលាប់លោក កែម ឡី ដោយសារលោក កែម ឡីជំពាក់បំណុលគាត់ចំនួន ៣០០០ ដុល្លា (១២ លានរៀល) ។ ទាំងខាងគ្រួសារលោក កែម ឡី ទាំងខាងគ្រួសាររបស់ជននេះបាននិយាយថា អ្នកទាំងពីរមិនដែលស្គាល់គ្នាទេ។ ដោយកត់សំគាល់លើរឿងនេះ និងភាពមិនប្រក្រតីដទៃទៀតនៅក្នុងករណីនេះ ដោយរួមទាំងការដែលជនបាញ់សំលាប់ដែលជាជនក្រីក្រម្នាក់ហើយមានកាំភ្លើងខ្លីដ៏ថ្លៃនោះអ្នកសង្កេតការណ៍ជាច្រើនជឿថា ភាគីទី៣ បានជួលឈ្មោះ អឿត អាង។ មកដល់ត្រឹមខែតុលា អាជ្ញាធរមិនឃើញមានភាពជឿនលឿនណាមួយនៅក្នុងការស៊ើបអង្កេតទេ ដោយលើកហេតុផលថា អឿតអាង មិនព្រមធ្វើសហប្រតិបត្តិការជាមួយនគរបាល។

តុលាការកាត់ទោសខ្មែរក្រហម (ECCC) ត្រូវបានបង្កើតឡើងដើម្បីចាប់អោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅក្រោមរបបខ្មែរក្រហម។ ECCC គឺជាតុលាការ "កូនកាត់" ពីព្រោះមានបុគ្គលិក ព្រះរាជអាជ្ញា និងចៅក្រមអន្តរជាតិនិងក្នុងស្រុក តែជាផ្នែកមួយនៃប្រព័ន្ធច្បាប់របស់ប្រទេស។ ថ្វីត្បិតតែ ECCC ត្រូវបានបង្កើតឡើងនៅក្រោមច្បាប់ជាតិក្តី តែដំណើរក្តីស្ថិតនៅក្រោមកិច្ចព្រមព្រៀងឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាល។ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងឆ្នាំ ២០០៣ រដ្ឋាភិបាលបានព្រមអនុវត្តសាលដីការបស់តុលាការនេះ។ តែនៅក្នុងឆ្នាំ ២០១៥ នគរបាលយុត្តិធម៌មិនបានអនុវត្តតាមដីការចាប់ខ្លួន ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ ដែលនាំអោយមានការចោទប្រកាន់ថា រដ្ឋាភិបាលជ្រៀតជ្រែកនៅក្នុងកិច្ចការរបស់ ECCC ។ ក្រោយមកចុងចោទបានស្ម័គ្រចិត្តបង្ហាញខ្លួន នៅចំពោះមុខតុលាការ។

## ខ. ការបាត់ខ្លួន

នៅឆ្នាំ ២០១៤ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបាននិយាយថា ខែម សុផាតបាត់ខ្លួនបន្ទាប់ពីកំលាំងសន្តិសុខរបស់រដ្ឋាភិបាលត្រូវបានគេនិយាយថា បានបាញ់គាត់ នៅក្នុងការប៉ះទង្គិចហឹង្សាមួយ នៅក្រៅរោងចក្រកាត់ដេរ Canadia ។ សាក្សីបានឃើញគាត់ត្រូវបានគេលើកដាក់ក្នុងឡានពេទ្យ។ គិតមកដល់ខែកញ្ញា សុផាតនៅបាត់ខ្លួននៅឡើយ។

## គ. ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មបន្ថោកបន្ទាប អមនុស្សធម៌ ឬឃោរឃៅដទៃទៀត

រដ្ឋធម្មនុញ្ញហាមប្រាមទង្វើបែបនេះ តែការវាយដំ និងទំរង់ដទៃទៀតនៃការធ្វើបាបលើរូបរាងកាយទៅលើអ្នកជាប់ឃុំរបស់នគរបាល និងអ្នកជាប់ពន្ធនាគារនៅតែមានជាបន្ត នៅក្នុងឆ្នាំនៃរបាយការណ៍។

មានរបាយការណ៍ដែលអាចទុកចិត្តបានថា យោធា និងនគរបាលស៊ីវិលបានធ្វើទារុណកម្មលើរាងកាយ និងផ្លូវចិត្ត ហើយមានពេលខ្លះ វាយដុំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវឃុំខ្លួនដោយសារបទព្រហ្មទណ្ឌទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ គិតមកដល់ខែកក្កដា អង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះអាដហុកបានរាយការណ៍ថា អាជ្ញាធរបានធ្វើទារុណកម្មទៅលើអ្នកជាប់ពន្ធនាគារឬអ្នកជាប់ឃុំចំនួនយ៉ាងហោចណាស់ ១៥ ករណី ចំណែកនៅក្នុងឆ្នាំ ២០១៥ ទាំងមូលមាន២០ ករណី។ អង្គការ NGO មួយទៀតបានរាយការណ៍ពីការវាយដំលើរូបរាងកាយចំនួន ៣១ ករណី។ នៅក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំ ២០១៥ មាន១៩ ករណី។ មានស្លាប់ក្នុង ៨ ករណី និងរបួសជិតស្លាប់ក្នុង ៤ ករណី។ តុលាការយកចំលើយសារភាពដោយបង្ខំធ្វើជាភស្តុតាងស្របច្បាប់នៅអំឡុងពេលជំនុំជម្រះក្តី ទោះបីជាច្បាប់ហាមមិនអោយយកការសារភាពបែបនេះជាការបានក្តី ។

គិតមកត្រឹមខែកក្កដា អង្គការអាដហុកបានរាយការណ៍ពីករណីចំនួន ១០ ដែលក្នុងនោះអាជ្ញាធរមូលដ្ឋាន ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជនរបស់មន្ត្រីរដ្ឋាភិបាលបានប្រើកំលាំងវាយដំទៅលើជនស៊ីវិល។ នៅក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំ ២០១៥ មាន ១២ ករណី។ ក្នុងករណីខ្លះ នគរបាលបានប្រើកំលាំងដើម្បីទប់ទល់នឹងការគំរាមប្រើហឹង្សា ឬអំពើហឹង្សាដោយអ្នកធ្វើបាតុកម្ម។ ក្នុងករណីខ្លះទៀត នគរបាលបានប្រើកំលាំងប្រឆាំងនឹងអ្នកធ្វើបាតុកម្មអហឹង្សា បន្ទាប់ពីអ្នកធ្វើបាតុកម្មធ្វើអោយរំខានដល់ចរាចរតាមផ្លូវ ហើយមិនព្រមបំបែកគ្នាតាមការបញ្ជា។

មានមជ្ឈមណ្ឌលបន្សាបថ្នាំញៀនរបស់រដ្ឋាភិបាលចំនួន ៧។ អ្នកសង្កេតការភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះគឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌល ដោយ

សមត្ថកិច្ច ឬសមាជិកគ្រួសារ។ យោងតាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្មានអ្នកដែលជាប់នៅក្នុងមណ្ឌលមានអាយុក្រោម ១៨ ឆ្នាំទេ។ អ្នកសង្កេតការណ៍បានកត់សំគាល់ឃើញថាបុគ្គលិកក្នុងមណ្ឌលជាញឹកញាប់ប្រើវិធីបង្ខំ ដើម្បី "គ្រប់គ្រង"ទៅលើអ្នកជាប់ក្នុងនោះ ដូចជាចងពួកគេ ឬអោយហាត់ប្រាណយ៉ាងខ្លាំង ឬប្រើវិធីក្តៅផ្សេងទៀត។ ថ្នាក់ដឹកនាំរដ្ឋាភិបាលទទួលស្គាល់សារៈសំខាន់នៃការព្យាបាលការញៀនថ្នាំ ដែលត្រូវបានចាត់ទុកថា ជារឿងសុខភាព ជាជាងរឿងព្រហ្មទណ្ឌ តែគ្មានចាត់វិធានការច្រើនតាមការនិយាយនោះទេ។ អាជ្ញាធរចាប់មនុស្សប្រមាណ ២០០០ ដាក់នៅក្នុងមជ្ឈមណ្ឌលទាំងនោះ។

## ស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមិនសមស្របតាមបទដ្ឋានអន្តរជាតិឡើយ ។ ស្ថានភាពជាច្រើននៅតែមានលក្ខណៈយ៉ាប់ ហើយក្នុងករណីជាច្រើន គម្រាមកំហែងដល់អាយុជីវិតទៀតផង ។

**<u>ទំហំភាពចង្អៀតណែន៖</u>** ការមានអ្នកទោសច្រើននាំអោយចង្អៀតខ្លាំងគឺជាបញ្ហាមួយ។យោងតាមអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដោយគិតត្រឹមខែតុលា មានអ្នកទោស និងអ្នកជាប់ពន្ធនាគារ ចំនួន ប្រមាណ ២០ ០០០ នាក់ នៅក្នុងពន្ធនាគារចំនួន ២៧ ដែលត្រូវបានបង្កើតឡើងដើម្បីដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំត្រឹមតែចំនួន ១១ ០០០ នាក់ ។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់អោយនៅដាច់ពីគ្នាទេរវាងអ្នកទោសជាមនុស្សពេញវ័យ និងអ្នកទោសជាកុមារ រវាងប្រុស និងស្រី ឬរវាងអ្នកទោសធ្ងន់ និងអ្នកទោសស្រាលទេ។ អ្នកជាប់ឃុំដែលមិនទាន់បានកាត់ក្តី និងអ្នកដែលត្រូវបានតុលាការកាត់ក្តីហើយ ជាធម្មតា ត្រូវបានគេដាក់អោយនៅឡុកឡំគ្នា។

បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ នារីមានផ្ទៃពោះ និងកូនមួយចំនួនរស់នៅជាមួយម្តាយរបស់គេក្នុងពន្ធនាគារ។

នាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា ដោយគិតមកត្រឹមខែសីហា មានអ្នកជាប់ពន្ធនាគារចំនួន ៧ នាក់បានស្លាប់ក្នុងពន្ធនាគារ។ នគរបាលបានអះអាងថា គេបានធ្វើការស៊ើបអង្កេត ហើយបានរកឃើញថាការស្លាប់គឺបណ្តាលមកពីការមានជំងឺពីមុនមក ឬជំងឺដទៃទៀត ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានអះអាងថា របបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅតែមិនគ្រប់គ្រាន់ទេ។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសំរាប់ទិញអាហារសំរាប់អ្នកទោស ពេលខ្លះ ត្រូវបានកិបកេងយកដោយអាជ្ញាធរ ដែលជាការធ្វើអោយមានកង្វះ

អាហារូបត្ថម្ភ និងជំងឺអ្នកទោសមានកាន់តែច្រើន។ អ្នកទោសមានទឹកស្អាតប្រើប្រាស់តែនៅក្នុងពន្ធនាគារចំនួន ១៨ ទេ ក្នុងចំណោមពន្ធនាគារចំនួន ២៧។ ពន្ធនាគារគ្មានកន្លែងគ្រប់គ្រាន់សំរាប់ជនពិការរាងកាយ និងអ្នកឡប់សតិឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានចោទប្រកាន់ថា អ្នកគ្រប់គ្រងពន្ធនាគារប្រព្រឹត្តមិនស្មើគ្នាលើអ្នកទោស ដូចជាករណីផ្តល់ការអនុញ្ញាតអោយអ្នកចូលសួរសុខទុក្ខ ការប្តូរទៅបន្ទប់ល្អ និងឱកាសចេញពីបន្ទប់ នៅពេលថ្ងៃ សំរាប់អ្នកទោសដែលគ្រួសាររបស់គេមានលុយសូក។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាល អ្នកទោសដែលមានការចងក្រងគ្នាគេ ហើយត្រូវបានរៀបចំឡើងនិងដឹកនាំដោយឆ្មាំពន្ធនាគារដែលគេហៅថា “គណកម្មាធិការគ្រប់គ្រងខ្លួនឯងរបស់អ្នកទោស” ពេលខ្លះ ធ្វើការវាយដំលើអ្នកទោសដទៃទៀត។

**<u>រដ្ឋបាល</u>៖** អាជ្ញាធរមិនបានប្រើវិធីផ្សេងក្រៅពីការដាក់គុកទេ សំរាប់ជនល្មើសអហឹង្សា។ អ្នកទោស និងអ្នកជាប់ការឃុំឃាំងជាធម្មតាត្រូវបានអនុញ្ញាតអោយជួបជាមួយអ្នកទៅមើល តែអង្គការសិទ្ធិមនុស្សបានអះអាងថា ពេលខ្លះ គ្រួសារត្រូវផ្តល់សំណូកដល់មន្ត្រីពន្ធនាគារដើម្បីបានសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ឬត្រូវផ្តល់ស្បៀងអាហារ និងរបស់របរចាំបាច់ដទៃទៀត ។ មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូក មុននឹងអនុញ្ញាតអោយអ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តីឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារដែលបានបញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ។

អ្នកទោសអាចដាក់បណ្តឹងស្តីពីការរំលោភបំពានទៅតុលាការ តាមរយៈមេធាវី ដោយមិនមានការត្រួតពិនិត្យកែប្រែឡើយ។ តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឡើយ។ រដ្ឋាភិបាលស៊ើបអង្កេតលើពាក្យបណ្តឹងបែបនេះ ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំង តាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ អគ្គនាយកដ្ឋានពន្ធនាគារមិនបញ្ចេញរបាយការណ៍នេះដល់ ទោះបីជាអង្គការសង្គមស៊ីវិលបានធ្វើការស្នើសុំជាញឹកញាប់ក្តី។

**<u>ការតាមដានដោយឯករាជ្យ</u>៖** ជាទូទៅ រដ្ឋាភិបាលបន្តអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្រុមសិទ្ធិមនុស្សក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ជួនកាល ការសហការពីអាជ្ញាធរ ដែនដីនៅមានកម្រិត ដែលជាការធ្វើអោយមានការលំបាកសម្រាប់ទាក់ទងអ្នកជាប់ឃុំដែលមិន

ទាន់ទទួលការជំនុំជម្រះក្តី ។ ក្រសួងមហាផ្ទៃតម្រូវអោយមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាត មុននឹងចូលជួបអ្នកជាប់ពន្ធនាគារ ហើយក្នុងករណីខ្លះ រដ្ឋាភិបាលតំរូវអោយអង្គការមិនមែនរដ្ឋាភិបាលចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាផ្លូវការ ដោយបញ្ជាក់ព្រំដែននៃ "តួនាទី" របស់គេ ក្នុងពេលទៅមើលអ្នកទោស។

ថ្វីបើក្រុមមនុស្សក្នុងស្រុកដែលធ្វើការតាមដានដោយឯករាជ្យ បានធ្វើសកម្មភាពដោយមានឯករាជ្យគ្រប់គ្រាន់ ដោយគ្មានទទួលឥទ្ធិពលពីរដ្ឋាភិបាលក្តី តែក្រុមខ្លះបានកត់សំគាល់ឃើញថា អាជ្ញាធរមិនអនុញ្ញាតអោយគេទៅមើលអ្នកទោសដោយសំងាត់ទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយដែលជាធម្មតា ផ្តល់ការថែទាំសុខភាពដល់អ្នកទោស បាននិយាយថា ពេលខ្លះរដ្ឋាភិបាលមិនអនុញ្ញាតអោយគេចូលមើលអ្នកទោសដែលកាត់ក្តីហើយ និងជាសមាជិកនៃគណបក្សប្រឆាំងឡើយ។ អង្គការមួយទៀតបាននិយាយថា រដ្ឋាភិបាលបានចោទខ្លួនថា មានគំនិតលំអៀងនយោបាយ ហើយប្រើការទៅមើលអ្នកទោសដើម្បីជំរុញអ្នកទោសអោយកាន់តែផ្គើនខ្លាំងឡើង។ តំណាងនៃការិយាល័យស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាននិយាយថា ធម្មតា ខ្លួនអាចជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារណាម្នាក់ដែលគួរអោយចាប់អារម្មណ៍ពិសេស ។

### ឃ. ការចាប់ ឬឃុំខ្លួនតាមអំពើចិត្ត

ច្បាប់ហាមប្រាមការចាប់ឬឃុំខ្លួនតាមអំពើចិត្ត តែពេលខ្លះ រដ្ឋាភិបាលមិនបានគោរពបំរាមទាំងនេះទេ។

### តួនាទីរបស់នគរបាល និងយន្តការសន្តិសុខ

អគ្គស្នងការនគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ គ្រប់គ្រងអង្គភាពនគរបាលស៊ីវិលទាំងអស់ ។ កម្លាំងនគរបាលត្រូវបែងចែកជាកម្លាំងដែលមានអំណាចដើម្បីធ្វើការចាប់ខ្លួន កម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌ ដែលអំណាចរបស់ខ្លួនមានដល់ការអនុវត្តដីការបស់តុលាការ ។ កងរាជអាវុធហត្ថទទួលបានការអនុញ្ញាតអោយចាប់ខ្លួនជនស៊ីវិល ប្រសិនបើមន្ត្រីទាំងនោះបំពេញលក្ខខ័ណ្ឌក្នុងការបណ្តុះបណ្តាល និងបទពិសោធន៍ដើម្បីបំពេញការងារជានគរបាលស៊ីវិល ប្រសិនបើជនស៊ីវិលស្ថិតនៅកន្លែងរបស់យោធា ឬក្នុងករណីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។ តែតាមភាពជាក់ស្តែង កងរាជអាវុធហត្ថធ្វើសកម្មភាពលើជនស៊ីវិលជាធម្មតា ក្រោមការអនុញ្ញាតនិងចង្អុលរបស់អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ដោយជាញឹកញាប់ ដើម្បីជួយនគរបាលស៊ីវិលដែលមិនអាចទប់ទល់នឹង

ហ្វូងមនុស្សដោយខ្លួនឯងបាន។ ក្រសួងមហាផ្ទៃគឺជាស្ថាប័នរដ្ឋាភិបាលសំខាន់សំរាប់វាយតំលៃការសំលាប់ដោយកំលាំងសន្តិសុខ។

មានការនិយាយមកថា មន្ត្រីនគរបាលបានប្រព្រឹត្តអំពើរំលោភបំពានផ្សេងៗដោយមាននិទណ្ឌភាព (ភាពគ្មានទោស) ហើយក្នុងករណីភាគច្រើន អាជ្ញាធរបានចាត់វិធានការបន្តិចបន្តួច ឬពុំមានចាត់វិធានការអ្វីឡើយ ។ នៅខែសីហា អង្គការអាដហុកបានរាយការណ៍ថាមានករណីនិទណ្ឌភាពចំនួន ៤៧។ ច្បាប់តម្រូវអោយនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមទាំងបណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និងព្រះរាជអាជ្ញាកម្រធ្វើការស៊ើបអង្កេតដោយឯករាជ្យណាស់។ ចៅក្រមជំនុំជម្រះ ជាធម្មតា ចេញសាលក្រមផ្អែកតាមតែរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលទទួលបានមកពីនគរបាល និងសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ ។ ជាទូទៅ នគរបាលបានទទួលការបណ្តុះបណ្តាលជំនាញបន្តិចបន្តួចតែប៉ុណ្ណោះ ។

## នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តទៅលើអ្នកជាប់ឃុំ

ច្បាប់តម្រូវអោយនគរបាលសុំដីកាពីចៅក្រមស៊ើបអង្កេត មុនធ្វើការចាប់ខ្លួន ប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មានដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទល្មើស ។ ច្បាប់អនុញ្ញាតអោយនគរឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបអង្កេតក្នុងរយៈពេល២៤ម៉ោងដោយមិនរាប់បញ្ចូលរយៈពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកផ្លូវការ មុននឹងធ្វើការចោទប្រកាន់ ឬជនសង្ស័យត្រូវបានដោះលែង ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថានភាពពិសេសដែលចែងដោយច្បាប់ នគរបាលអាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ ម៉ោងបន្ថែមដោយមានការឯកភាពពីព្រះរាជអាជ្ញា ។ ទោះជាយ៉ាងនេះក្តី ជាទម្លាប់ អាជ្ញាធរតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់ មុននឹងធ្វើការចោទប្រកាន់ ។

មានវិធីនៃការធានាអោយនៅក្រៅឃុំ តែអ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានាអោយ នៅក្រៅឃុំឡើយ ។ ជាធម្មតា សេចក្តីស្នើអោយនៅក្រៅឃុំត្រូវបានបដិសេធចំពោះករណីដែលត្រូវបានចាត់ទុកថា បណ្តាលមកពីហេតុផលនយោបាយ។ តាមច្បាប់ ជនជាប់ចោទអាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈ ពេល ២៤ម៉ោង មុននឹងអាចមានលទ្ធភាពទទួលបានប្រឹក្សាច្បាប់ ប៉ុន្តែអ្នកជាប់ពន្ធនាគារ ជាធម្មតា ត្រូវជាប់ឃុំជាច្រើនថ្ងៃ មុននឹងអាចជួបមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើន

បណ្តាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ ។ រដ្ឋាភិបាលមិនបានផ្តល់មេធាវីសំរាប់ជនជាប់ឃុំដែលក្រីក្រខ្លាំងទេ។

**<u>ការចាប់ខ្លួនតាមអំពើចិត្ត</u>៖** គិតមកដល់ខែសីហា អង្គការអាហុក បាននិយាយថា មានករណីចាប់ខ្លួន ឬឃុំខ្លួនចំនួន ១៧ ករណី ដែលគេចាត់ទុកថា ជាអំពើធ្វើតាមអំពើចិត្ត តែមិនបានលើកឡើងនូវឧទាហរណ៍ច្បាស់ណាមួយទេ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សមួយទៀតបាននិយាយថា មានករណីចាប់ខ្លួនឬឃុំខ្លួនដោយខុសច្បាប់ចំនួន ២៨ ករណី ចំណែកនៅឆ្នាំ ២០១៥ មាន១៦ករណី។ ចំនួននៃការចាប់ខ្លួនតាមអំពើចិត្តទំនងជាមានច្រើនជាងនេះ ពីព្រោះជនរងគ្រោះនៅតាមតំបន់ជនបទមិនប្តឹង ដោយសារមានការពិបាកធ្វើដំណើរមកការិយាល័យរបស់អង្គការអាដហុក ឬមានកង្វល់ពីសុវត្ថិភាពនៃគ្រួសាររបស់គេ។ អាជ្ញាធរមិនបានចាត់វិធានដាក់ទណ្ឌកម្ម ឬវិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះការឃុំខ្លួនដោយខុសច្បាប់ទេ ។

នៅក្នុងឆ្នាំនៃរបាយការណ៍នេះ អាជ្ញាធរក្រុងភ្នំពេញបានចាប់ខ្លួនមនុស្សរាប់សិបអ្នក ដែលជាធម្មតាគឺអ្នកគ្មានផ្ទះសម្បែង អ្នកវិកលចរិក អ្នកប្រើគ្រឿងញៀន ឬអ្នករកស៊ីផ្លូវភេទ ក្នុងអំឡុងពេលយុទ្ធនាការចុះបោសសំអាតតាមផ្លូវក្នុងក្រុង ហើយក្នុងចំណោមអ្នកដែលត្រូវបានចាប់នោះ មានខ្លះប្រហែលជាជនរងគ្រោះដោយសារការជួញដូរមនុស្ស។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបាននិយាយថា តាមធម្មតា អ្នកដែលត្រូវឃុំខ្លួន បាត់បង់លុយកាក់ និងទ្រព្យសម្បត្តិ ក្នុងអំឡុងពេលនៃការបោសសំអាតនោះ ដែលអាជ្ញាធរហៅថាជាការ "ធ្វើអោយសង្គមមានសណ្តាប់ធ្នាប់"។ អាជ្ញាធរយកអ្នកទាំងនោះទៅដាក់នៅមជ្ឈមណ្ឌលរបស់ក្រសួងសង្គមកិច្ច ដែលមានចំងាយ ១៥ ម៉ៃល៍ ពីក្រុងភ្នំពេញ ឬបញ្ជូនទៅអោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ អង្គការមិនមែនរដ្ឋាភិបាលច្រើនតែលែងគេមកវិញ នៅក្នុងរយៈពេលតែប៉ុន្មានម៉ោងតែប៉ុណ្ណោះ។

កាលពីខែមិថុនា មន្ត្រីសាលាក្រុងបានឃាត់ខ្លួនមនុស្សចំនួនជាង ១០០ នាក់ នៅមុនពិធីបុណ្យសាធារណៈ។ អ្នកដែលត្រូវបានឃាត់នោះមានកុមាររស់នៅតាមផ្លូវ អ្នកគ្មានផ្ទះសម្បែង អ្នករកស៊ីផ្លូវភេទ និងជនវិកលចរិក។ អាជ្ញាធរយកពួកគេទៅដាក់នៅមជ្ឈមណ្ឌលឃុំឃាំងព្រៃស្ពឺ។

**<u>ការឃុំខ្លួនមុនសវនាការ</u>៖** ច្បាប់អនុញ្ញាតអោយមានការឃុំខ្លួនមុនសវនាការរហូតដល់រយៈពេល ៦ ខែ ចំពោះបទល្មើសមជ្ឈិម និង ១៨ ខែ ចំពោះបទឧក្រិដ្ឋ។ គិតមកត្រឹមខែកញ្ញា ក្រសួងមហាផ្ទៃបាននិយាយថា មានមនុស្សចំនួន ៧០៣២ នាក់ស្ថិតក្នុងឃុំខ្លួនមុនសវនាការ។ បុគ្គលិកតុលាការត្រូវបានរាយការណ៍មកថា បានខិតខំពន្លឿនការពិនិត្យសំរេចលើករណីទាំងនោះ។ ថ្វីបើអ្នកជាប់ឃុំមុនសវនាការត្រូវបានឃុំដោយគ្មាន

តំណាងផ្នែកច្បាប់ក្តី តែគ្មានការរាយការណ៍មកថា មានការឃុំខ្លួនលើសពីរយៈពេលកំណត់ដោយច្បាប់ ឬក៏មានការបាត់បង់សំណុំរឿងទេ។ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា អ្នកទាំងនោះដែលជាប់ឃុំត្រូវបានចោទពីបទល្មើសស្រាល។

លទ្ធភាពរបស់អ្នកជាប់ឃុំក្នុងការចោទសួរពីភាពស្របច្បាប់នៃការឃុំខ្លួនមុនចូលតុលាការ៖ អ្នកដែលត្រូវបានចាប់ខ្លួនឬឃុំខ្លួនអាចតវ៉ាក្នុងតុលាការ ចំពោះមូលដ្ឋានច្បាប់ឬលក្ខណៈធ្វើតាមទំនើងចិត្តនៃការឃុំខ្លួនគេ តែអាជ្ញាធរច្រើនតែមិនគោរពសិទ្ធិនេះទេ។

## ខ. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាល ជាទូទៅមិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ តុលាការស្ថិតក្រោមឥទ្ធិពល និងការជ្រៀតជ្រែករបស់ផ្នែកនីតិប្រតិបត្តិ ដែលមានអំណាចដំឡើងសក្តិ បណ្តេញចេញ និងដាក់ពិន័យលើចៅក្រមតាមចិត្ត។ មន្ត្រីតុលាការច្រើនតែមានមុខតំណែងក្នុងពេលជាមួយគ្នា នៅក្នុងគណបក្សកាន់អំណាច ហើយអ្នកសង្កេតការណ៍បាននិយាយថា មានតែអ្នកដែលមានទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជន ឬផ្នែកប្រតិបត្តិទេ ដែលបានទទួលមុខតំណែងក្នុងតុលាការ។មានអំពើពុករលួយយ៉ាងរាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។

អ្នកសង្កេតការណ៍និយាយថា សមាគមមេធាវីជាតិលំអៀងយ៉ាងខ្លាំងទៅរកសមាជិកដែលមានខ្សែស្រឡាយជាមួយគណបក្សប្រជាជន នៅក្នុងការជ្រើសរើសសមាជិក។ ចំណែកមេធាវីមកពីគណបក្សប្រឆាំងឬក្រុមផ្សេងមិនសូវមានឱកាសទេ។ ពេលខ្លះ សមាគមជ្រើសយកអ្នកដែលគ្មានសមត្ថភាព ដោយសារតែខ្សែស្រឡាយនយោបាយ។ ជាញឹកញាប់ លទ្ធផលនៃសវនាការហាក់មានការកំណត់ទុកជាមុនស្រេច។ ឧទាហរណ៍ អ្នកសង្កេតការណ៍នៅក្នុងសវនាការនៃសកម្មជនរបស់គណបក្សប្រឆាំងចំនួន ១១ រូប ដែលរងការចោទថា បានធ្វើការបះបោរ បាននិយាយថា បន្ទាប់ពីចៅក្រមសំរាកដើម្បីធ្វើការពិចារណា នគរបាលយុត្តិធម៌បានព័ទ្ធបន្ទប់សវនាការ ហើយបានរៀបចំផ្ទេរជនសង្ស័យទៅពន្ធនាគារ ដែលជាការបង្ហាញថា សាលក្រមដាក់អោយជាប់ទោសត្រូវបានកំណត់ជាមុនស្រេចទៅហើយ (សូមមើលត្រង់អ្នកជាប់ឃុំ និងអ្នកទោសនយោបាយខាងក្រោម)។

កំរិតនៃអំពើពុករលួយខ្ពស់ និងអសមត្ថភាពមាននៅក្នុងប្រព័ន្ធតុលាការហើយរដ្ឋាភិបាលមិនបានធានាអោយមានដំណើរការក្តីត្រឹមត្រូវទេ។

បើយោងតាមរបាយការណ៍របស់រដ្ឋាភិបាល កង្វះចៅក្រម និងបន្ទប់តុលាការបានពន្យាករណីជាច្រើន។ អង្គការ NGO ក៏ជឿផងដែរថា មន្ត្រីតុលាការច្រើនផ្តោតលើករណីដែលក្នុងនោះ គេបានទទួលលុយ។ ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការច្រើនតែធ្វើអោយជនរងការចោទប្រកាន់រួចផុតពីការកាត់ទោស។ មន្ត្រីរដ្ឋាភិបាល និងសមាជិកគ្រួសាររបស់គេដែលប្រព្រឹត្តបទល្មើសច្រើនតែ មិនត្រូវបានដាក់ទោសឡើយ (និទណ្ឌភាព)។ អង្គការមិនមែនរដ្ឋាភិបាលបានអះអាងថា ដូចនៅក្នុងឆ្នាំកន្លងទៅដែរ ចុងចោទដែលមានទ្រព្យឬមានអំណាច រួមទាំងសមាជិកនៃកងកំលាំងសន្តិសុខផង តាមធម្មតា បង់លុយអោយជនរងគ្រោះ និងអាជ្ញាធរ ដើម្បីអោយទំលាក់ការចោទប្រកាន់ព្រហ្មទណ្ឌ។ អាជ្ញាធរត្រូវបានគេដឹងថា បានតឿនអោយជនរងគ្រោះ ឬគ្រួសាររបស់គេទទួលយកនូវសំណងប៉ះប៉ូវជាលុយកាក់ ជាថ្នូរនឹងការទំលាក់ចោលការចោទប្រកាន់ព្រហ្មទណ្ឌ ឬការមិនបង្ហាញមុខជាសាក្សី។

## នីតិវិធីជំនុំជម្រះក្តី

តាមច្បាប់ ចុងចោទមានសិទ្ធិត្រូវបានគេសន្មតថា ជាជនស្លូតត្រង់ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ ប៉ុន្តែដោយសារអំពើពុករលួយរីករាលដាល ជារឿយៗចុងចោទត្រូវសូកចៅក្រម ដើម្បីអោយចេញសាលក្រមដែលមានលក្ខណៈអនុគ្រោះ ។ សវនាការត្រូវបានធ្វើជាសាធារណៈ តែច្រើនតែត្រូវបានពន្យាពេលដោយសារការិយាធិបតេយ្យក្នុងតុលាការ។ ចុងចោទមានសិទ្ធិបង្ហាញវត្តមាន ហើយពិគ្រោះយោបល់ជាមួយមេធាវី ប្រឈម និងចោទសួរសាក្សីប្រឆាំងនឹងខ្លួន ហើយ បង្ហាញសាក្សី និងភស្តុតាងដោយខ្លួនគេ។ ក្នុងករណីព្រហ្មទណ្ឌ ប្រសិនបើចុងចោទគ្មានប្រាក់រកមេធាវីម្នាក់បាន តុលាការត្រូវផ្តល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ចុងចោទ ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្តល់ប្រឹក្សាផ្នែកច្បាប់ ហើយចុងចោទភាគច្រើនស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាងផ្នែកច្បាប់ ។ នៅក្នុងករណីគ្មានមេធាវីការពារចុងចោទក្នុងរឿងព្រហ្មទណ្ឌ តុលាការពន្យាករណីរហូតទាល់តែមេធាវីត្រូវបានរកបាន ហើយករណីបែបនេះច្រើនតែស៊ីពេលរាប់ខែ។ ការជំនុំជម្រះក្តីច្រើនតែធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ច ហើយការសួរដេញដោលដោយភាគីម្ខាងទៅភាគីម្ខាង ជាធម្មតា មិនបានកើតមានឡើយ ។ តុលាការបានធ្វើការបកស្រាយដោយសេរី។ ចុងចោទ និងមេធាវីរបស់ខ្លួនមានសិទ្ធិពិនិត្យមើលភស្តុតាងដែលរដ្ឋាភិបាលរក្សាទុក ទាក់ទងនឹងរឿងក្តីរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ គេច្រើនមានការពិបាកនឹងទទួលបានលទ្ធភាពដូចពោលនេះណាស់ ជាពិសេស ប្រសិនបើសំណុំរឿងនោះពាក់ព័ន្ធនឹងរឿងនយោបាយ ឬពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ឬសមាជិកឥស្សរជនដែលមានខ្សែរយៈរឹងមាំ ។ ច្បាប់ចែងពីសិទ្ធិទាំងនេះសំរាប់ចុងចោទទាំងអស់។

មានការខ្វះមេធាវីច្រើនដែលមានជំនាញត្រឹមត្រូវ ពិសេសនៅក្រៅក្រុងភ្នំពេញ។ អ្នកដែលគ្មានធនធានសំរាប់រកមេធាវី បាត់បង់សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌។ យោងតាមសមាគមនៃគណៈមេធាវី គិតមកដល់ខែកញ្ញា មានមេធាវីចំនួន ៨៦៩ នាក់ផ្តល់សេវាផ្លូវច្បាប់ នៅទូទាំងប្រទេស។ នៅក្នុងឆ្នាំ២០១៥ មានមេធាវីចំនួន ៧៩៦ នាក់។ អ្នកក្រអាចស្វែងរកសេវាផ្លូវច្បាប់ដោយឥតគិតថ្លៃពីមេធាវីទាំងនេះតាមរយៈអង្គការមិនមែនរដ្ឋាភិបាលខ្លះ។

អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ការថ្លែងជាលាយលក្ខណ៍អក្សររបស់សក្សី និងអ្នករងការចោទប្រកាន់ច្រើនតែត្រូវបានយកធ្វើជាភស្តុតាងតែមួយ នៅក្នុងសវនាការ។ ពេលខ្លះ ជនរងការចោទប្រកាន់ត្រូវបានបង្ខំអោយនិយាយ ដោយការវាយដំ ឬការគំរាមកំហែង ហើយចុងចោទដែលមិនចេះអក្សរ ជាញឹកញាប់ មិនត្រូវបានប្រាប់ពីសេចក្តីនៅក្នុងចំលើយសារភាព ដែលគេត្រូវបានបង្ខំអោយចុះហត្ថលេខាទៅលើនោះទេ។ សិទ្ធិរបស់ពលរដ្ឋក្នុងការមានវត្តមាននៅក្នុងសាលាឧទ្ធរណ៍ជាញឹកញាប់មានកំរិត ដោយសារការពិបាកនៅក្នុងការដឹកអ្នកទោសពីពន្ធនាគារខេត្តមកសាលាឧទ្ធរណ៍នៅភ្នំពេញ។ ដូច្នេះ ជាងពាក់កណ្តាលនៃសវនាការឧទ្ធរណ៍ប្រព្រឹត្តទៅដោយគ្មានវត្តមានរបស់ចុងចោទឡើយ។

គិតមកត្រឹមខែមិថុនា អង្គការ NGO ក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយបានធ្វើការតាមដានសវនាការចំនួន ១៤៣ ដោយក្នុងនោះ មាន ៧៣ ខ្វះវត្តមាននៃមេធាវី។ ក្នុងករណីចំនួន ៧០ នៃករណីទាំងនេះ ចុងចោទបានសារភាពពីបទល្មើស មុនពេលសវនាការចាប់ផ្តើម ចុងចោទចំនួន ១៣ នាក់បានអះអាងថា គេបានសារភាពដោយសារមានការធ្វើទារុណកម្ម ការបង្ខំ និងការគំរាមរបស់នគរបាល។

## អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ

យោងតាមអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស គិតមិត្រឹមខែមិថុនា អាជ្ញាធរបានចាប់ខ្លួនឬឃុំខ្លួនមនុស្សយ៉ាងតិចចំនួន ២៩ នាក់ ទាក់ទងនឹងនយោបាយ។

នៅខែកក្កដា ឆ្នាំ ២០១៥ តុលាការក្រុងភ្នំពេញបានកាត់ទោសអោយសកម្មជនគណបក្សសង្គ្រោះជាតិចំនួន ១១ អោយជាប់ពន្ធនាគារចំនួនពី ៧ ទៅ ២០ ឆ្នាំ ចំពោះតួនាទីតាមការចោទប្រកាន់ នៅក្នុងការតវ៉ានៅឆ្នាំ ២០១៤ ដែលបណ្តាលអោយអ្នកតវ៉ាចំនួន ៦ នាក់ និងសន្តិសុខខ័ណ្ឌដូនពេញចំនួន ៣៩ នាក់រងរបួស។ អ្នកសង្កេតការណ៍ខ្លះអះអាងថា តុលាការបានចេញសាលដីកានេះដោយគ្មានភស្តុតាងដែលភ្ជាប់សកម្មជនទាំងនោះទៅនឹងបទចោទ ហើយបែរជាបកស្រាយទោសទាំងនោះថាជាការដាក់ទណ្ឌកម្មចំពោះការចូលរួមរបស់ពួកគេ នៅក្នុងការតវ៉ាលើការកំណត់ព្រំដែនជាមួយវៀតណាម ដែលជាបញ្ហាមួយមានលក្ខណៈ

នយោបាយជាខ្លាំង។ សកម្មជនគណបក្សប្រឆាំងដែលជាប់ឃុំទាំង ១១ រូបបានធ្វើការប្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី ២៣ ខែសីហា សាលាឧទ្ធរណ៍បានយល់ព្រមបំបែកករណីជាពីរ គឺករណីមួយតវ៉ាចំពោះសាលក្រម ហើយករណីទី២ គឺតវ៉ាចំពោះនិតិវិធីច្បាប់មិនសមស្រប។

នៅខែសីហា ឆ្នាំ ២០១៥ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានបញ្ជាអោយអាជ្ញាធរចាប់ខ្លួនលោក ហុង សុខហួ សមាជិកព្រឹទ្ធសភាមកពីគណបក្សសម រង្ស៊ី ហើយបានចោទប្រកាន់គាត់ពីបទ "ក្លែងក្លាយឯកសារ" និង "ញុះញង់" តាមរយៈការចុះផ្សាយសន្ធិសញ្ញាព្រំដែនក្លែងក្លាយ ឆ្នាំ ១៩៧៩ រវាងរដ្ឋាភិបាល និងប្រទេសវៀតណាម ដែលតាមការនិយាយមកថា បានបង្ហាញពីកិច្ចព្រមព្រៀងលុបបំបាត់ព្រំដែនចោល រវាងប្រទេសទាំងពីរ។ នៅថ្ងៃទី ២៣ មិថុនា តុលាការកំពូលបានដំកល់សាលក្រមរបស់សាលាឧទ្ធរណ៍ ដែលបានបដិសេធមិនអោយលោកនៅក្រៅឃុំ ទោះបីមានការស្នើពីគ្រូពេទ្យរបស់គាត់ ដោយសារមានកង្វល់សុខភាពក្តី។ នៅថ្ងៃទី ៧ វិច្ឆិកា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ រស់ ពិសិដ្ឋបានរកឃើញថា លោកហុង សុខហួ មានទោសពីបទក្លែងឯកសារសាធារណៈ ប្រើឯកសារក្លែងក្លាយ និងញុះញង់អោយមានចលាចល ហើយបានដាក់ទោសអោយលោកជាប់ទោសក្នុងពន្ធនាគារចំនួន ៧ ឆ្នាំ។ អ្នកសង្កេតការណ៍ជាច្រើនបានបកស្រាយចំណាត់ការទាំងនេះថាជាមធ្យោបាយមួយក្នុងការគាបសង្កត់គណបក្សសង្គ្រោះជាតិកុំអោយធ្វើការរិះគន់រដ្ឋាភិបាលចំពោះការខកខានក្នុងការកំណត់ព្រំដែនជាមួយប្រទេសវៀតណាមអោយបានសមស្រប។

នៅខែឧសភា អង្គភាពប្រឆាំងអំពើពុករលួយ (ACU) បានចាប់ឃុំមន្ត្រីជាន់ខ្ពស់របស់សមាគមអាដហុកចំនួន ៤ រូប និងអគ្គលេខាធិការរងនៃគជបមួយរូប ដែលជាអតីតសមាជិករបស់សមាគមអាដហុក។ ACU ចោទអ្នកទាំង ៥ ថាបានធ្វើការសូកប៉ាន់ ស្រីកំណាន់ដូចដែលត្រូវបានចោទប្រកាន់ របស់លោក កឹម សុខា អោយកុហកក្នុងរឿងស្នេហាលួចលាក់មួយ។ អ្នកទាំង ៥ បន្តបដិសេធការចោទប្រកាន់នេះ។ ពួកគេនៅក្នុងឃុំ រង់ចាំការកាត់ក្តី។ ពីដំបូង អាជ្ញាធរចោទប្រកាន់ពលរដ្ឋម្នាក់ដែលធ្វើការអោយការិយាល័យសិទ្ធិមនុស្សរបស់សហប្រជាជាតិ នៅភ្នំពេញពីបទលើកទឹកចិត្តអោយស្រីកំណាន់នោះកុហក តែក្រោយមកអាជ្ញាធរបានទំលាក់ការចោទប្រកាន់នោះវិញ។

អ្នកនយោបាយនៃគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលបាននិយាយថា អាជ្ញាធរច្រើនតែមិនផ្តល់លទ្ធភាពអោយអ្នកទោស ដែលគេជឿថា ទោសរបស់គេនោះបណ្តាលមកពីហេតុផលនយោបាយ។ ក្នុងករណីមន្ត្រីអាដហុកទាំង ៤ រូប អាជ្ញាធរអនុញ្ញាតអោយមានការចូលសួរសុខទុក្ខចំនួន ២ ដងក្នុងមួយសប្តាហ៍។

## និតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ

ប្រទេសកម្ពុជាមានអង្គតុលាការមួយសម្រាប់បណ្តឹងរដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹងស្វែងរកសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយផ្នែករដ្ឋបាល ទាំងដំណោះស្រាយផ្នែកតុលាការ តែអាជ្ញាធរច្រើនតែមិនអនុវត្តសាលដីកាតុលាការ។

**សំណងទ្រព្យសម្បត្តិ** (Property Restitution)

ការបង្ខំយកមកដាក់ជាសមូហភាព នៅក្រោមរបបខ្មែរក្រហម និងការផ្លាស់ទីលំនៅរបស់ប្រជាជនបានធ្វើអោយកម្មសិទ្ធិដីធ្លីមានភាពមិនច្បាស់លាស់។ ច្បាប់ភូមិបាលចែងថា អ្នកដែលមានកម្មសិទ្ធិដោយសុខសាន្តលើដីឯកជន ឬដីរដ្ឋ (មិនរាប់បញ្ចូលដីសាធារណៈ ដូចជាសួនច្បារ) ឬបានរស់នៅក្នុងអាគាររដ្ឋដោយគ្មានការតវ៉ាទាមទារពីអ្នកផ្សេង ក្នុងរយៈពេល ៥ឆ្នាំ មុនការប្រកាសអោយប្រើច្បាប់នេះ នៅឆ្នាំ ២០០១ មានសិទ្ធិដាក់ពាក្យសុំកម្មសិទ្ធិលើដី/អាគារនោះជាស្ថាពរ។ តែ ប្រជាជនភាគច្រើននៅតែខ្វះការយល់ដឹងនិងមធ្យោបាយសំរាប់ទទួលបានឯកសារកម្មសិទ្ធិដីធ្លីជាផ្លូវការគ្រប់គ្រាន់។

ការិយាល័យសុរិយោដីខេត្តនិងស្រុកបន្តធ្វើតាមនិតិវិធីនៃការចុះបញ្ជីដីមុនឆ្នាំ ២០០១ ដែលមិនបញ្ចូលការសិក្សាអង្កេតបានត្រឹមត្រូវលើដី ឬឱកាសសំរាប់អោយសាធារណជនផ្តល់មតិ។ គណកម្មាការសុរិយោដីដែលរដ្ឋាភិបាលបានបង្កើតឡើង នៅឆ្នាំ ២០០២ ដើម្បីដោះស្រាយអោយបានឆាប់ និងតាមការពេញចិត្តរបស់ភាគីពាក់ព័ន្ធ នូវករណីដីមិនទាន់ចុះបញ្ជី (មិនរាប់បញ្ចូលករណីទាក់ទងនឹងមរតក ឬកុងត្រា) មិនបានអនុវត្តលើការកំណត់អត្តសញ្ញាណ និងការកំណត់ព្រំសីមានៃដីរដ្ឋ ដែលជាការនាំអោយមានវិវាទ និងការបណ្តេញ ដែលត្រូវបានជំរុញអោយលឿនដោយសកម្មភាពរបស់រដ្ឋក្នុងការធ្វើការអភិវឌ្ឍន៍លើដីមានជំលោះ។ ការទិញដីទុកលក់ ដោយគ្មានប័ណ្ណកម្មសិទ្ធិច្បាស់លាស់ បានបណ្តាលអោយមានជំលោះ នៅគ្រប់ខេត្តទាំងអស់ ហើយបានបង្កើនភាពតានតឹងរវាងអ្នកភូមិក្រីក្រតាមជនបទ និងឈ្មួញទិញលក់ដី។ សហគមន៍រស់នៅតាមតំបន់ក្រុងប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ដើម្បីយកកន្លែងសំរាប់គំរោងអភិវឌ្ឍន៍ពាណិជ្ជកម្ម។ គិតមកត្រឹមខែសីហា ក្រសួងរៀបចំដែនដីបានរាយការណ៍ថា ប័ណ្ណកម្មសិទ្ធិដីចំនួន៦១៩ ១៤០ ត្រូវបានចែកអោយអ្នកភូមិ គិតតាំងពីឆ្នាំ ២០១២ មក។ នៅឆ្នាំនៃរបាយការណ៍នេះ ប័ណ្ណកម្មសិទ្ធិដីចំនួន ៩ ១៤០ ត្រូវបានចែក។

ករណីអាជ្ញាធរបង្ខំអោយអ្នកស្រុកផ្លាស់ទីលំនៅនៅតែបន្តមាន ទោះបីក្នុងប៉ុន្មានឆ្នាំមកនេះ មានការថយចុះក្តី។ អ្នកខ្លះប្រើការគំរាមកំហែងប្តឹង ឬបណ្តេញចេញ ដើម្បីសំឡុតអ្នកក្រ និងអ្នកស្ថិតក្នុងស្ថានភាព

ខ្សត់ខ្សោយ អោយទូទាត់សំណងដីរបស់គេ នៅក្នុងតំលៃក្រោមតំលៃទីផ្សា។ ដោយគិតមកត្រឹមខែកក្កដា អង្គការអាដហុកបាននិយាយថា បានទទួលសំណុំរឿងថ្មីទាក់ទងនឹងជំលោះដីធ្លីរវាងអ្នករកស៊ី និងអ្នកភូមិ ចំនួន ៨១ករណី ដែលរួមមានការចោទពីការចាប់យកដី ការលួចធនធានធម្មជាតិ ដីសម្បទានសេដ្ឋកិច្ច និង ការ បណ្តេញចេញពីដីធ្លី។ ការនេះរួមបញ្ចូលដីចំនួន ២០៦១៤ acre ដែលប៉ះពាល់គ្រួសារចំនួនប្រមាណ ៧៦៥៧។ អ្នកក្រគ្មានឯកសារផ្លូវច្បាប់សំរាប់បញ្ជាក់លើអំណះអំណាងរបស់គេលើដីទេ ហើយខ្វះជំនឿលើ ប្រព័ន្ធតុលាការ។ អ្នកដែលរងការបណ្តេញចេញខ្លះបានតវ៉ាបានជោគជ័យនៅតុលាការ តែករណីភាគច្រើន មិនទាន់ត្រូវបានគេចាត់ការទៅលើទេ។

### ច. ការជ្រៀតជ្រែកតាមអំពើចិត្តក្នុងភាពឯកជន គ្រួសារ គេហដ្ឋាន ឬក្នុងការឆ្លើយឆ្លងគ្នា

ច្បាប់មានចែងអំពីភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងគ្នា ហើយហាមឃាត់ការឆែកឆេរខុស ច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយក៏អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាជាទម្លាប់ នគរបាលធ្វើការ ឆែកឆេរ និងរឹបអូស ដោយគ្មានដីកាពីតុលា ។ អង្គការ NGO មួយបាននិយាយ ដោយមិនបានផ្តល់ភស្តុតាង ថារដ្ឋាភិបាលបានដំឡើងបរិក្ខាតាមសង្កេតមើលកន្លែងផ្តល់សេវាអ៊ីនធ័រណែត ដើម្បីតាមដានចរាចរក្នុង អ៊ីនធ័រណែត ហើយជាធម្មតា តាមដានការទាក់ទងតាមទូរស័ព្ទជាលក្ខណៈឯកជន។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ ដែលរួមមាន

### ក. សេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពបញ្ចេញមតិ និងសេរីភាពផ្នែកសារព័ត៌មាន។ ទោះជាយ៉ាងណាក៏ ដោយ នៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិទាំងនេះមិនត្រូវបានគោរពជានិច្ចឡើយ ។

**<u>សេរីភាពក្នុងការបញ្ចេញមតិ</u>**

រដ្ឋធម្មនុញ្ញអនុញ្ញាតអោយមានការបញ្ចេញមតិដោយសេរី លើកលែងតែក្នុងករណីដែលវាប៉ះពាល់ ដល់សន្តិសុខសាធារណៈ ។ រដ្ឋធម្មនុញ្ញក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ “មិនអាចត្រូវគេរំលោភបាន” ហើយសេចក្តីណែនាំរបស់ ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មីនូវដែនកំណត់ ទាំងនេះ ហើយហាមប្រាមមិនអោយអ្នកបោះពុម្ព និងនិពន្ធនាយកផ្សព្វផ្សាយរឿងណា ដែលប្រមាថ និង បរិហាកេរ្តិ៍ព្រះមហាក្សត្រ ថ្នាក់ដឹកនាំនិងស្ថាប័នរដ្ឋាភិបាល ។

នៅខែមិនា ឆ្នាំ ២០១៥ រដ្ឋសភាជាតិបានយល់ព្រមធ្វើវិសោធនកម្មលើច្បាប់គ្រប់គ្រងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ហើយបានអនុម័តច្បាប់ថ្មីស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាជាតិ។ ទាំងវិសោធនកម្ម ទាំងច្បាប់ថ្មីមានបញ្ញត្តិដែលតំរូវអោយអង្គការសង្គមស៊ីវិលមានភាព "អព្យាក្រឹត" នៅក្នុងអំឡុងពេលនៃយុទ្ធនាការនយោបាយ ហើយហាមពួកគេមិនអោយ "ប្រមាថ" គណបក្សនយោបាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានប្រកាសអោយប្រើនៅខែសីហា រឹតត្បិតបន្ថែមទៀតនូវសេរីភាពក្នុងការនិយាយស្តី ដោយទាមទារអោយអង្គការសមាគមទាំងអស់មានអព្យាក្រឹតភាពនយោបាយ។

ច្បាប់ហាមប្រាមមិនអោយមានការត្រួតពិនិត្យចាប់ពិរុទ្ធមុនពេលបោះពុម្ពផ្សាយ ឬការដាក់ទោសជាប់ពន្ធនាគារ ដោយសារការសម្តែងមតិឡើយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានប្រើក្រមព្រហ្មទណ្ឌដើម្បីកាត់ទោសពលរដ្ឋពីបទបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់។ ក្រមព្រហ្មទណ្ឌមិនមានចែកពីការចាប់ដាក់ពន្ធនាគារចំពោះការបរិហារកេរ្តិ៍ទេ តែចែងពីការដាក់ពន្ធនាគារចំពោះការញុះញង់ ឬផ្សាយព័ត៌មានមិនពិត ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ ចៅក្រមក៏អាចបញ្ជាអោយបង់ការផាកពិន័យផងដែរ ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគារ បើមិនបង់ទេ។ តុលាការបានបកស្រាយក្នុងលក្ខណៈទូលំទូលាយនូវទោស "ញុះញង់" ហើយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលបានគំរាមឥស្សរជនគណបក្សប្រឆាំង ពីបទញុះញង់ ដោយសារអំពើ ដូចជាការអំពាវនាវអោយមាន "ការផ្លាស់ប្តូរក្នុងរដ្ឋាភិបាល" តាមមធ្យោបាយបោះឆ្នោត។

អង្គការ NGO ក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកវិភាគឯករាជ្យមួយចំនួនបានបន្តសំដែងកង្វល់ជាសាធារណៈអំពីសកម្មភាពរបស់រដ្ឋាភិបាលដែលដៅលើការងាររបស់គេ ដោយរួមទាំងករណីប្រឆាំងនឹងមន្ត្រីសមាគមអាដហុកផងដែរ។ នៅថ្ងៃទី ៩ ឧសភា សកម្មជនសិទ្ធិមនុស្សមួយក្រុមបានផ្តើមយុទ្ធនាការ "ថ្ងៃចន្ទពណ៌ខ្មៅ" ដើម្បីតវ៉ានឹងអំពើអយុត្តិធម៌របស់តុលាការ ហើយទាមទារអោយមានការដោះលែងអ្វីដែលគេហៅថា អ្នកទោសមនសិកា។ យុទ្ធនាការនេះអំពាវនាវអោយសមាជិកស្លៀកពាក់ខ្មៅដើម្បីសំដែងសាមគ្គីភាពជាមួយអ្នកជាប់ឃុំក្នុងពន្ធនាគារ។ នៅក្នុងករណីមួយចំនួន អាជ្ញាធរបានចាប់ខ្លួនអ្នកធ្វើយុទ្ធនាការ ហើយបានដោះលែងពួកគេមកវិញ ដោយភ្ជាប់លក្ខខ័ណ្ឌសន្យាមិនចូលរួមជាថ្មីក្នុងការតវ៉ា។

**<u>សេរីភាពសារព័ត៌មាន៖</u>** គណបក្សនយោបាយធំៗទាំងអស់មានលទ្ធភាពសមហេតុផល និងទៀងទាត់ ចំពោះកាសែត។ កាសែតធំៗទាំងអស់ជាភាសាខ្មែរទទួលបានការគាំទ្រថវិកាពីបុគ្គលដែលស្និទ្ធនឹងគណបក្សប្រជាជនដែលកំពុងដឹកនាំប្រទេស ។ បើយោងតាមក្រសួងព័ត៌មាន មានកាសែតជាភាសាខ្មែរប្រមាណ ១៣ ចំណែក "កាសែត" តូចៗចំនួនពី ៣០ ទៅ ៤០ បោះពុម្ពមិនទៀងទាត់ទេ។

ថ្វីបើអ្នកសង្កេតការណ៍ចាត់ទុកកាសែតចំនួន ៥ ដែលបោះពុម្ពច្រើនជាងគេ ថាគាំទ្រគណបក្សប្រជាជនក្តី តែកាសែតភាគច្រើនរិះគន់រដ្ឋាភិបាលក្នុងលក្ខណៈមិនធំ ពិសេសទាក់ទងនឹងអំពើពុករលួយ និងការចាប់យកដី។ គិតមកត្រឹមខែសីហា គ្មានកាសែតប្រឆាំងចេញទៀងទាត់ទេ តែសំលេងប្រឆាំងពឹងលើការផ្សាយអេឡិចត្រូនិច និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីសំដែងមតិនានា រួមទាំងមតិប្រឆាំងផង។ ថ្វីបើការប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ជាទូទៅគ្មានការចាប់ពិរុទ្ធក្តី តែសកម្មជនខ្លះមានកត់សំគាល់ឃើញមានកំណើននៃការបង្ក្រាបតាមគោលដៅដោយអាជ្ញាធរ ដែលនាំអោយអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមខ្លះរងការគំរាមការចាប់ខ្លួន និងការកាត់ទោសដោយអយុត្តិធម៌។

រដ្ឋាភិបាល កងកំលាំងយោធា និងគណបក្សនយោបាយកាន់អំណាចបានបន្តមានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយ ហើយបានប្រើឥទ្ធិពលលើខ្លឹមសារនៃការផ្សាយ។ មានស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកចំនួន ១៦ ហើយនិងស្ថានីយ៍វិទ្យុចំនួន ១៧៥។ ស្ថានីយ៍វិទ្យុភាគច្រើន និងស្ថានីយ៍ទូរទស្សន៍ទាំងអស់ស្ថិតក្រោមការគ្រប់គ្រង ឬក្រោមឥទ្ធិពលយ៉ាងខ្លាំងរបស់គណបក្សប្រជាជនកម្ពុជា ហើយមានតែចំនួនតិចតួចទេដែលឯករាជ្យ ឬមិនកាន់ខាងគណបក្សដទៃ។ យោងតាមអង្គការ NGO មួយដែលតាមដានប្រព័ន្ធផ្សព្វផ្សាយ ជាធម្មតារដ្ឋាភិបាលប្រើទូរទស្សន៍រដ្ឋដើម្បីផ្សាយពីសកម្មភាពរបស់រដ្ឋាភិបាល និងគណបក្ស CPP និងដើម្បីរិះគន់គណបក្សប្រឆាំង ដោយមិនផ្តល់លទ្ធភាពស្មើគ្នាអោយគណបក្សប្រឆាំងឡើយ។ នៅខែកក្កដា អង្គការសង្គមស៊ីវិលបានរិះគន់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ចំពោះការមិនបានផ្សាយពីព្រឹត្តិការណ៍នៃការសំលាប់លោក កែម ឡី។ អ្នកខ្លះនិយាយថា បណ្តាលមកពីមានការគាបសង្កត់ដោយគណបក្ស CPP និងរដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយ។

ជាផ្នែកមួយនៃកិច្ចព្រមព្រៀង ឆ្នាំ ២០១៤ ដែលបញ្ចប់ភាពជាប់គាំងនយោបាយរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង រដ្ឋាភិបាលបានផ្តល់អោយគណបក្សសង្គ្រោះជាតិនូវអាជ្ញាប័ណ្ណបើកស្ថានីយទូរទស្សន៍មួយ តែគណបក្ស CNRP ប្រឈមនឹងការពិបាកក្នុងការទទួលបានដីក្នុងមូលដ្ឋាន និងការអនុញ្ញាតសាងសង់។ នៅខែមេសា អាជ្ញាធរខេត្តកណ្តាលបានហាមមិនអោយគណបក្ស CNRP ដំឡើងអង់តែ

ទូរទស្សន៍ ដោយលើកពីកង្វល់របស់រស់នៅក្នុងមូលដ្ឋានថា ស្ថានីយ៍នេះនឹងបញ្ចេញចំហាយអេឡិចត្រូនិចដែលប៉ះពាល់ដល់សុខភាពរបស់គេ។ មន្ត្រីគណបក្ស CNRP បានចោទអាជ្ញាធរថាមានភាពលំអៀង ដោយកត់សំគាល់ថាអង់តែនរបស់ទូរទស្សន៍អប្សារាដែលគាំទ្រគណបក្ស CPP បានផ្សាយចេញពីកន្លែងមានមនុស្សរស់នៅកកកុញ ក្នុងក្រុងភ្នំពេញ តាំងពីឆ្នាំ ១៩៩៦ មក ដោយគ្មានបញ្ហាឬការតវ៉ាឡើយ។ គណបក្ស CNRP បានប្រកាសនៅខែមិថុនាថា ខ្លួននឹងរកទីតាំងថ្មីសំរាប់ស្ថានីយ៍ទូរទស្សន៍របស់ខ្លួន។

**<u>អំពើហឹង្សា និងការយាយី៖</u>** ហឹង្សា និងការគំរាមកំហែងលើអ្នកសារព័ត៌មាននៅមានច្រើននៅឡើយ។ នៅថ្ងៃទី១០ មេសា នគរបាលស្រុកប៉ៃលិន ឈ្មោះ យៀ សុខនបានផ្ទង់កាំភ្លើងទៅលើឈ្មោះ អ៊ុក តូច ដែលជាអ្នកសារព័ត៌មានរបស់កាសែតកម្ពុជាអភិវឌ្ឍន៍ ដោយអះអាងថា គាត់ខឹងនឹងការស៊ើបអង្កេតរបស់អ្នកសារព័ត៌មាននោះទៅលើការដែលគាត់បានបាញ់ទៅលើអ្នកភូមិ។ នៅក្នុងករណីដោយឡែកមួយ ប៉េអិមខេត្តមណ្ឌលគីរីបានឃាត់ខ្លួន វ៉ាន់ ទូច អ្នកធ្វើការអោយទូរទស្សន៍លេខ ៩ ដែលបានរាយការណ៍ថា មេបញ្ជាការរបស់គេបានទទួលសំណូកពីអ្នកកាប់ឈើខុសច្បាប់នៅតំបន់អភិរក្សជីវសាស្ត្រចំរុះសីមា។

**<u>ការចាប់ពិរុទ្ធ ឬការដាក់កំហិតលើសេចក្តីក្នុងអត្ថបទ៖</u>** មានសេចក្តីរាយការណ៍ខ្លះមកថាភ្នាក់ងាររដ្ឋាភិបាលបានយាយី ឬសំលុតអ្នកសារព័ត៌មាន អ្នកបោះពុម្ពផ្សាយ ឬអ្នកចែកចាយព័ត៌មាន។ ដោយសាររដ្ឋាភិបាលគ្រប់គ្រងលើច្បាប់អនុញ្ញាតនិងអាជ្ញាប័ណ្ណសំរាប់អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយភាគច្រើនបានធ្វើការចាប់ពិរុទ្ធលើខ្លួនឯងខ្លះ។ អ្នកយកព័ត៌មាន និងនិពន្ធនាយកខ្លះបានសារភាពថាបានបង្អង់ដៃក្នុងការសរសេររបស់គេដោយខ្លាចរដ្ឋាភិបាលធ្វើការសងសឹក។

**<u>ច្បាប់បរិហារកេរ្តិ៍ និងសន្តិសុខជាតិ៖</u>** រដ្ឋាភិបាលប្រើច្បាប់បរិហារកេរ្តិ៍ដើម្បីធ្វើការរឹតត្បិតលើការពិភាក្សាគ្នាជាសាធារណៈលើបញ្ហាដែលរដ្ឋាភិបាលគិតថាមានភាពរសើប ឬប្រឆាំងនឹងផលប្រយោជន៍របស់ខ្លួន។ រដ្ឋាភិបាលបានចេញដីការចាប់ខ្លួនចំពោះមេដឹកនាំប្រឆាំង គឺលោក សម រង្ស៊ី ដោយផ្អែកលើការដាក់ទោសរបស់តុលាការទាក់ទងនឹងការប្តឹងរបស់អតីតរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ស្តីពីការបរិហារកេរ្តិ៍ កាលពីឆ្នាំ២០០៨ (សូមមើលផ្នែកទី ៣)។

**<u>សន្តិសុខជាតិ៖</u>** រដ្ឋាភិបាលតែងតែលើកឡើងពីកង្វល់សន្តិសុខជាតិធ្វើជាហេតុផលនៃការរឹតត្បិតលើសិទ្ធិរបស់ពលរដ្ឋ ដែលរិះគន់មន្ត្រី និងនយោបាយរដ្ឋាភិបាល។ ដោយឡែក រដ្ឋាភិបាលតែងតែគំរាមកាត់ទោស និងចាប់

ខ្លួនអ្នកដែលចោទសួរពីការកំណត់ព្រំដែនរបស់រដ្ឋាភិបាលជាមួយប្រទេសវៀតណាម ឬអ្នកដែលនិយាយថា រដ្ឋាភិបាលបានកាត់ដីអោយវៀតណាម ។

**សេរីភាពអ៊ីនធ័រណែត**

រដ្ឋាភិបាលមិនបានដាក់កំហិតលើប្រព័ន្ធអ៊ិនធ័រណែត ឬចាប់ពិរុទ្ធ (Censor) សេចក្តីនៅក្នុង អ៊ិនធ័រណែតទេ តែមានរបាយការណ៍គួរអោយទុកចិត្តបានថា រដ្ឋាភិបាលបានតាមដានអ៊ីម៉េល ឬការឆ្លើយឆ្លង ផ្ទាល់ខ្លួនតាមអ៊ិនធ័រណែត ។ មានសេវាអ៊ិនធ័រណែតសំរាប់ប្រើជាទូទៅ ពិសេសនៅតាមទីប្រជុំជន ហើយ ជាង ៣១% នៃប្រជាជនកម្ពុជាអាចប្រើសេវាអ៊ិនធ័រណែត។ជាង ៩៨%នៃអ្នកប្រើប្រាស់ប្រើអ៊ិនធ័រណែត តាមរយៈ ទូរស័ព្ទដៃ ដោយមិនសូវមានការតខ្សែបណ្តាញដល់ផ្ទះទេ នេះបើតាមព័ត៏មានពីក្រសួង ទូរគមនាគមន៍ និងប្រៃសនីយ៍។

នៅខែធ្នូ ឆ្នាំ ២០១៥ ច្បាប់ស្តីពីទូរគមនាគមន៍បានចូលជាធរមាន ដែលបណ្តាលអោយមានប្រតិកម្ម ខ្លាំងពីសកម្មជនសិទ្ធិមនុស្ស និងសង្គមស៊ីវិលធំៗនៅក្នុងប្រទេស ដែលបានអះអាងថា វាផ្តល់អោយរដ្ឋាភិបាល នូវអំណាចទូលំទូលាយក្នុងការលួចស្តាប់ការពិភាក្សាជាសាធារណៈតាមអ៊ិនធ័រណែត ដោយប្រើឧបករណ៍ ទាក់ទងគ្នាជាឯកជន។ យោងតាមអង្គការសិទ្ធិមនុស្សលីកាដូ រដ្ឋាភិបាលមានអំណាចតាមផ្លូវច្បាប់ក្នុងការ តាមដានគ្រប់ការសន្ទនាតាមទូរស័ព្ទ សារតាមទូរស័ព្ទ អ៊ីម៉េល សកម្មភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងការ ឆ្លើយឆ្លងរបស់បុគ្គល ដោយគ្មានការយល់ព្រមឬដឹងពីពួកគេ។ មតិសំដែងដែលត្រូវបានគេគិតថា រំលោភលើ ន័យសន្តិសុខជាតិដែលកំណត់ដោយរដ្ឋាភិបាល អាចនាំដល់ការចាប់ដាក់ពន្ធនាគាររហូតដល់ ១៥ឆ្នាំ។ គិតមក ដល់ខែវិច្ឆិកា គ្មានការចាប់ខ្លួនដោយផ្អែកលើច្បាប់ថ្មីនេះទេ។

អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយបានអះអាងថា មានករណីចាប់ខ្លួនមនុស្សយ៉ាងតិច ២០ ដោយសារ ដែលគេបានបង្ហោះតាមអ៊ិនធ័រណែត។ នៅខែមិនា តុលាការក្រុងភ្នំពេញបានដាក់ទោសអោយយុវជនមនសិកា នយោបាយ គង់ រ៉ាយ៉ាជាប់ពន្ធនាគារចំនួន ១៨ ខែ ពីបទអំពាវនាវអោយមាន "បដិវត្តន៍ពណ៌" តាម ហ្វេសបុក។ ក្រុមសង្គមស៊ីវិលបានថ្កោលទោសការដាក់ទោសនោះ ហើយបានហៅវាថាជាវិធានការមួយ ដើម្បីរឹតត្បិតសេរីភាពនៃការបញ្ចេញមតិតាមអ៊ិធ័រណែត។ សកម្មជនមួយចំនួនបាននិយាយថា រដ្ឋាភិបាលបាន ប្រើករណីរបស់ឈ្មោះរ៉ាយ៉ាដើម្បីគំរាម សំលុត និងបង្ករជាឧបសគ្គសំរាប់សង្គមស៊ីវិល។

នៅឆ្នាំ ២០១៥ ក្រសួងមហាផ្ទៃបានប្រកាសថា នឹងចាប់អនុវត្តបទបញ្ជាអោយអ្នកប្រើ Sim Card ទាំងអស់បង្ហាញអត្តសញ្ញាប័ណ្ណ។ ការនេះនាំអោយមានការផ្តាច់ Sim card ចំនួនជិតមួយលាន។ គិតមកដល់ខែកញ្ញា Sim card ចំនួនប្រមាណ ១៩ លានត្រូវបានប្រើប្រាស់ ចំណែកនៅក្នុងឆ្នាំ ២០១៥ មានប្រមាណ ២០ លានត្រូវបានប្រើ។ នគរបាលបានលើកហេតុផលនៃវិធានការថ្មីថាជាជំហានចាំបាច់មួយដើម្បីទប់ស្កាត់បទល្មើស ដោយរួមទាំងការជួញដូរមនុស្ស និងអំពើភេរវកម្ម។ ទោះបីជាមានការទាមទារយ៉ាងនេះក្តី ក៏ក្រុមហ៊ុនទូរស័ព្ទចល័តជាច្រើនមិនបានបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ Sim card ដែរ។ ក្រុមសង្គមស៊ីវិលបន្តសំដែងកង្វល់ថា រដ្ឋាភិបាលអាចប្រើការប្រមូលព័ត៌មានផ្ទាល់ខ្លួនពីការចុះបញ្ជី Sim card ដើម្បីរាំងខ្ទប់ការសំដែងមតិតាមអ៊ិនធ័រណែត។

“ក្រុមសង្គ្រាមតាមប្រព័ន្ធអ៊ិនធ័រណែត” នៅក្នុងអង្គភាពប្រតិកម្មរហ័សនិងផ្នែកសារព័ត៌មានរបស់ទីស្តីការគណរដ្ឋមន្ត្រី មាននាទីតាមដាន និងប្រឆាំងនឹង ព័ត៌មាន “មិនត្រឹមត្រូវ” ពីផ្នែកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ព័ត៌មានធ្លាយមកស្តីពីពង្រាងច្បាប់ស្តីពីបទល្មើសតាមអ៊ិនធ័រណែត នៅខែកក្កដា ឆ្នាំ ២០១៥ បានធ្វើអោយគេមានការភ័យខ្លាចថែមទៀតថា រដ្ឋាភិបាលកំពុងតែបង្កើតយន្តការច្បាប់ថ្មីមួយដើម្បីពង្រីកអំណាចរបស់ខ្លួន ក្នុងការចាប់និងដាក់ទោសអ្នកដែលប្រឆាំងនឹងគំនិតរបស់ខ្លួន។ ជាការឆ្លើយតបរដ្ឋាភិបាលបានបញ្ជាក់ថា គោលបំណងរបស់ច្បាប់នោះគឺដើម្បី “ធ្វើអោយសាធារណជនដឹង” និងការពារ “កិត្តិនាម” របស់រដ្ឋាភិបាល និងការពារកុំអោយមានការ “ប្រមាថ” មកលើរដ្ឋាភិបាល។

## សេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌

ជាទូទៅ រដ្ឋាភិបាលពុំមានរឹតត្បិតសេរីភាពផ្នែកការសិក្សាអប់រំឬពិធីវប្បធម៌ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ ។ នៅខែឧសភា ក្រសួងអប់រំបានរំលឹកដល់គ្រឹះស្ថានអប់រំរដ្ឋ និងឯកជន ពីច្បាប់ដែលហាមការពិភាក្សា និងសកម្មភាពនយោបាយទាំងអស់។ ច្បាប់ចែងថា “សកម្មភាពនយោបាយនិងការឃោសនាអោយគណបក្សនយោបាយណាមួយ នៅក្នុងគ្រឹះស្ថានអប់រំត្រូវបានហាមឃាត់ដាច់ខាត”។ សកម្មជនជាច្រើនបានអះអាងថា ច្បាប់នេះមានបំណងរាំងខ្ទប់ការគាំទ្ររបស់យុវជនចំពោះគណបក្សប្រឆាំង ដោយបន្ថែមថា ភាគច្រើននៃនាយកសាលាគាំទ្រគណបក្ស CPP ។មន្ត្រីរដ្ឋាភិបាលហាក់ដូចជាលើកលែងអង្គការធំៗមួយចំនួននៅតាមសាលា ដែលមានការទាក់ទងជាមួយគណបក្សកាន់អំណាច ដោយលើកឡើងថាអង្គការទាំងនោះគឺជាក្រុម “ក្រៅការសិក្សា” ដែលជំរុញ “បុព្វហេតុមនុស្សធម៌”។

## ខ. សេរីភាពប្រមូលផ្តុំគ្នា និងសេរីភាពបង្កើតអង្គការ/សមាគម

### សេរីភាពប្រមូលផ្តុំគ្នា

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី ប៉ុន្តែមានពេលខ្លះ រដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះទេ នៅក្នុងការអនុវត្តជាក់ស្តែង ។

ច្បាប់អង្គការតំរូវអោយមានការសុំការអនុញ្ញាតជាមុន មុននឹងធ្វើការដង្ហែរក្បួនតវ៉ា ឬបាតុកម្ម ថ្វីបើអាជ្ញាធរមិនសូវអនុវត្តតាមការទាមទារនេះបានខ្ជាប់ខ្ជួនក្តី។ ខមួយចែងពីការត្រូវជំរាបប្រាប់ចំនួន ៥ ថ្ងៃមុនសំរាប់ការធ្វើបាតុកម្មដោយសន្តិវិធី ចំណែកខមួយទៀតចែងពីការតំរូវអោយជូនដំណឹងចំនួន ១២ ម៉ោងមុនសំរាប់ការប្រមូលផ្តុំគ្នាដោយមិនមានការគ្រោងទុក នៅលើទីកន្លែង ឯកជន ឬសំរាប់ការតវ៉ានៅកន្លែងកំណត់ ហើយកំរិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់ អាជ្ញាធរខេត្ត និងអាជ្ញាធរក្រុងមានអំណាចសំរេចចេញការអនុញ្ញាតអោយធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រីអាជ្ញាធរថ្នាក់ក្រោមប្រគល់សិទ្ធិអោយអាជ្ញាធរថ្នាក់ជាតិវិញ ក្នុងការសំរេច ហើយធ្វើការបដិសេធសំណើសុំ បើអាជ្ញាធរថ្នាក់ជាតិមិនផ្តល់ការអនុញ្ញាតច្បាស់អោយធ្វើការប្រមូលផ្តុំគ្នា។ តាមធម្មតា អាជ្ញាធរតាមគ្រប់លំដាប់ថ្នាក់មិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សដឹកនាំប្រទេសទេ ។

របាយការណ៍ដែលគួរអោយទុកចិត្តបាន បានអោយដឹងថា ពេលខ្លះ រដ្ឋាភិបាលរាំងមិនអោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរៀបចំពិធីជាសាធារណៈ ដោយលើកហេតុផលថា ក្រុមទាំងនោះមិនបានចុះបញ្ជីក្រោមច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ដែលទើបតែអនុម័តថ្មីៗនេះទេ ថ្វីបើបទបញ្ជាលើការអនុវត្តច្បាប់នេះមិនទាន់មានក្តី។ អាជ្ញាធរលើកហេតុផល"ស្ថិរភាព" និង "សន្តិសុខសាធារណៈ" សំរាប់ការមិនផ្តល់ការអនុញ្ញាត តែច្បាប់មិនកំណត់ច្បាស់នូវន័យនៃពាក្យ ថាស្ថិរភាព និងសន្តិសុខសាធារណៈ សំរាប់ធ្វើជាហេតុផលក្នុងការបដិសេធការអនុញ្ញាតទេ ។ អាជ្ញាធររដ្ឋាភិបាលពេលខ្លះថែមទាំងលើកឡើងពីខនៅក្នុងច្បាប់អង្គការ ដើម្បីរាំងអង្គការ សមាគមមិនអោយរៀបចំពិធីជាសាធារណៈ ឬបំបែកការប្រជុំឬការរៀនសូត្រ ដែលគេគិតថា ប្រឆាំងនឹងរដ្ឋាភិបាល។ ក្នុងករណីខ្លះ នគរបាលបំបែកហ្វូងមនុស្សដែលប្រមូលផ្តុំគ្នាដោយគ្មានការអនុញ្ញាត ដោយក្នុងករណីខ្លះ បណ្តាលអោយមានរបួសតិចតួចដល់បាតុករ។ កាសែតបានរាយការណ៍ពីការតវ៉ាជាសាធារណៈច្រើន ដោយភាគច្រើនទាក់ទងនឹងជំលោះដីធ្លី ឬជំលោះជាមួយកម្មករ។

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សមួយបាននិយាយថា រដ្ឋាភិបាលបានរារាំងការប្រជុំគ្នា ឬការថ្លែងជាសាធារណៈដោយសន្តិភាពយ៉ាងតិចចំនួន ៤២ ករណី ដែលជាចំនួនកើនឡើងទ្វេដងលើចំនួននៅឆ្នាំ ២០១៥។ អង្គការសម្ព័ន្ធភាពនៃសហគមន៍កសិករកម្ពុជា ដែលជាអង្គការសហគមន៍ ធ្វើការជាមួយកសិករដើម្បីកែលំអជីវភាពរបស់គេ បាននិយាយថា អាជ្ញាធរខេត្តព្រៃវែងបានបញ្ឈប់វគ្គរៀនសូត្រមួយរបស់គេ ហើយទាមទារឯកសារចុះបញ្ជីផ្លូវការ ថ្វីបើក្រសួងមហាផ្ទៃបានអះអាងថា ច្បាប់អង្គការមិនតំរូវអោយអង្គការបែបនោះធ្វើការចុះបញ្ជីឡើយ។

### សេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម តែរដ្ឋាភិបាលមិនបានគោរពសិទ្ធិ នេះអោយបានជាប់លាប់ទេ ពិសេសទាក់ទងនឹងសិទ្ធិរបស់កម្មករ (សូមមើលត្រង់ផ្នែក ៧.ក) ។

បទបញ្ញាតិដែលមិននិយាយច្បាស់នៅក្នុងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ហាមប្រាមសកម្មភាពដែលអាច “ធ្វើអោយខូចដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ” ឬប៉ះពាល់ដល់ “សន្តិសុខជាតិ សាមគ្គីជាតិ ប្រពៃណី និងវប្បធម៌ដ៏ល្អនៃសង្គមជាតិកម្ពុជា”។ អង្គការសង្គមស៊ីវិលបានសំដែងកង្វល់ចំពោះបទបញ្ញាតិដែលចែងមិនច្បាស់ ថា បានបង្កើតអោយមានការប្រឈមខ្លាំងនឹងការរឹតត្បិតតាមចិត្ត លើសិទ្ធិរបស់អង្គការ សមាគម។ យោងតាមអ្នករិះគន់ច្បាប់អង្គការចែងពីដំណើរការចុះបញ្ជីស្មុគស្មាញ និងច្រើនជំហាន ហើយខ្វះការការពារផ្នែករដ្ឋបាល ដែលជាការធ្វើអោយដំណើរការនៃការចុះបញ្ជីរងលក្ខណៈនយោបាយ។ ច្បាប់នេះថែមទាំងកំណត់អោយមានការធ្វើរបាយការណ៍យ៉ាងតឹងតែង ស្តីពីថវិកា និងសកម្មភាព។ កាតព្វកិច្ចបន្ថែមទៀតរួមមានការបង្ហាញសំណើសុំថវិកាដែលបានទទួលការយល់ព្រម កិច្ចព្រមព្រៀងលើថវិកាឬអំណោយថវិកា និងគណនេយ្យធនាគាររបស់អង្គការសមាគម។ ក្នុងពេលដែលស្ថិតិផ្លូវការមិនទាន់មាននៅឡើយ អង្គការ NGO ជាច្រើនបានលើកឡើងពីការលំបាកក្នុងការបំពេញការងារចុះបញ្ជីជាមួយរដ្ឋាភិបាល។

### គ. សេរីភាពសាសនា

ចំពោះសេចក្តីរៀបរាប់លំអិតស្តីពីសេរីភាពសាសនា សូមមើល*របាយការណ៍ស្តីពីសេរីភាពសាសនា* តាមគេហទំព័រ www.state.gov/religiousfreedomreport/ ។

## ឃ. សេរីភាពដើរហើរ ជនផ្លាស់ទីកន្លែងក្នុងប្រទេស ការការពារជនភៀសខ្លួន និងជនគ្មានរដ្ឋ

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស និរប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។

និរទេសៈ មេដឹកនាំបក្សប្រឆាំង សម រង្ស៊ីបានបន្តស្ថិតនៅក្នុងប្រទេសបារាំង ដោយធ្វើនិរទេសខ្លួនឯង។ រដ្ឋាភិបាលបានចេញដីការចាប់ខ្លួន នៅខែវិច្ឆិកា ឆ្នាំ ២០១៥ ដោយចោទពីបទបរិហារកេរ្តិ៍ ក្នុងពេលលោកស្ថិតនៅក្រៅប្រទេស ហើយមកដល់ដំណាច់ឆ្នាំ លោកមិនទាន់ត្រឡប់មកវិញទេ។

### ការការពារជនភៀសខ្លួន

<u>លទ្ធភាពទទួលបានការជ្រកកោន៖</u> ច្បាប់ប្រទេសកម្ពុជាមានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំប្រព័ន្ធមួយសម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន ។ រដ្ឋាភិបាលមិនបានផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធនេះដល់អ្នកសុំសិទ្ធិជ្រកកោនទាំងអស់ទេ។ ដូចជាថា អាជ្ញាធរច្រើនតែមិនផ្តល់លទ្ធភាពដល់ក្រុមអ្នកស្រុកភ្នំមកពីប្រទេសវៀតណាមដែលស្វែងរកសិទ្ធិជ្រកកោន នៅក្នុងដំណើរការចុះឈ្មោះជនភៀសខ្លួន។ ប្រព័ន្ធជាតិផ្នែកសិទ្ធិជ្រកកោនមានសមត្ថភាពនៅមានកំរិត ដែលជាការនាំអោយមានការយឺតយ៉ាវសំរាប់អ្នកស្វែងរកសិទ្ធិជ្រកកោនខ្លះ។ នៅខែមេសា រដ្ឋាភិបាលបានបញ្ជូនទាហានជាងមួយពាន់នាក់ទៅកាន់ព្រំដែនវៀតណាម ទៅកាន់ច្រកដាក់ឡាក់ជាប់ខេត្តរតនគីរី ដើម្បីរាំងកុំអោយអ្នកស្រុកភ្នំវៀតណាមមកស្វែងរកសិទ្ធិជ្រកកោននៅកម្ពុជា។ នៅខែឧសភា ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិសំរាប់ជនភៀសខ្លួនបានផ្ទេរអ្នកស្រុកភ្នំម៉ុងតាញ៉ាមួយក្រុមដែលមានគ្នា ១៣ នាក់ទៅមជ្ឈមណ្ឌលពិនិត្យមើលជនភៀសខ្លួននៅប្រទេសហ្វីលីពីន ហើយស្វែងរកប្រទេសទី ៣ សំរាប់ការតាំងទីលំនៅរបស់គេជាថ្មី។ អ្នកស្វែងរកសិទ្ធិជ្រកកោនចំនួន ១៦ នាក់បន្ថែមទៀតបានស្ម័គ្រចិត្តវិលត្រឡប់ទៅប្រទេសកំណើតរបស់គេវិញ នៅខែកក្កដា បន្ទាប់ពីមិនបានទទួលឋានៈជាជនភៀសខ្លួន នៅភ្នំពេញ។

<u>**ការចាប់បញ្ជូនជនភៀសខ្លួនត្រឡប់វិញ៖**</u> ដោយបាននិយាយថា ពួកគេគឺជា “ជនអន្តោប្រវេសន៍សេដ្ឋកិច្ច” រដ្ឋាភិបាលបានចាប់បញ្ជូនអ្នកស្រុកភ្នំវៀតណាមចំនួនយ៉ាងហោចណាស់ ៥០ នាក់ទៅប្រទេសវៀតណាមវិញ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ ដោយមិនបានធ្វើការកំណត់ឋានៈជនភៀសខ្លួនឡើយ។ យោងតាមឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ (UNHCR) បានរាយការណ៍ថា អ្នកស្រុកភ្នំវៀតណាមចំនួនជាង ១៧០ នាក់ បនៅភ្នំពេញបានបង្ហាញបំណងចង់ចុះឈ្មោះជាអ្នកស្វែងរកសិទ្ធិជ្រកកោន តែនាយកដ្ឋានជនភៀសខ្លួនរបស់ក្រសួងមហាផ្ទៃមិនអនុញ្ញាតអោយគេធ្វើដូច្នេះទេ។ នៅខែតុលា ក្រសួងបាន

ប្រកាសជាសាធារណៈថា ខ្លួនមិនបានផ្តល់សិទ្ធិជ្រកកោនដល់អ្នកស្រុកភ្នំវៀតណាមភាគច្រើនដែលបន្តស្នាក់នៅ បន្ទាប់ពីធ្វើសំភាសន៍ជាច្រើន ដោយនិយាយថា “ចំលើយរបស់គេមិនបំពេញបានតាមកតិសញ្ញាស្តីពីជនភៀសខ្លួន” ទេ។ ពីដំបូង សារព័ត៌មានក្នុងស្រុកបាននិយាយថា ក្រសួងបានផ្តល់អោយពួកគេនូវពេល ២ សប្តាហ៍សំរាប់ការចាកចេញពីប្រទេស បើគេមិនព្រមចេញទេ នោះគេនឹងត្រូវចាប់បញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ តែក្រោយមក ក្រសួងបានដកការកំណត់ពេលនោះវិញ។

**<u>ការងារ</u>**៖ បើយោងតាមអង្គការ NGO មួយ ឯកសារដែលត្រូវបានផ្តល់អោយដោយរដ្ឋាភិបាលគឺមិនគ្រប់គ្រាន់សំរាប់អោយមនុស្ស ៨៥ នាក់ដែលបានទទួលឋានៈជាជនភៀសខ្លួននៅឆ្នាំ ២០១៥ អាចធ្វើការ បើកគណនេយ្យធនាគារ ឬប្រើសេវាសាធារណៈបានទេ។

**<u>ដំណោះស្រាយយូរអង្វែង</u>**៖ យោងតាមកិច្ចព្រមព្រៀង ឆ្នាំ ២០១៤ ជាមួយប្រទេសអូស្ត្រាលី រដ្ឋាភិបាលបានទទួលយកអោយស្នាក់នៅ នូវជនភៀសខ្លួនចំនួន ៥ នាក់ ដែលត្រូវបានគេឃុំនៅកោះ Nauru ។ បន្ទាប់ពីការមកដល់នៃជនភៀសខ្លួន Rohingya ម្នាក់ មាន ៤ នាក់ទៀតបានមកដល់ដែរ។ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានរាយការណ៍ថា មនុស្ស ៤ នាក់ត្រូវបានគេទុកនៅក្នុងផ្ទះវីឡាមួយ ដែលផ្តល់ដោយរដ្ឋាភិបាល ហើយដោយផ្ទុយនឹងការធានា មិនត្រូវបានអនុញ្ញាតអោយស្វែងរកផ្ទះ ឬរស់នៅចូលក្នុងសង្គមឡើយ។ បន្ទាប់មកជនភៀសខ្លួនទាំង ៤ នាក់ ជាលទ្ធផល បានសុំត្រឡប់ទៅប្រទេសដើមរបស់គេវិញ រួមទាំងប្តីប្រពន្ធជនជាតិអ៊ីរ៉ង់ ដែលបានវិលត្រឡប់ទៅប្រទេសអ៊ីរ៉ង់វិញ នៅខែមិនា។ គ្មានវិធីច្បាស់លាស់សំរាប់អោយជនភៀសខ្លួនទទួលបានសញ្ជាតិទេ។ ជនភៀសខ្លួន Rohingya តាមសេចក្តីរាយការណ៍មកថា បាននៅក្នុងប្រទេសកម្ពុជានៅឡើយ។ គ្មានវិធីណាសំរាប់អោយជនភៀសខ្លួនទទួលបានសញ្ជាតិទេ។

**ជនគ្មានប្រទេស** [**ជនគ្មានរដ្ឋ**]

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានប្រទេស ចំណែកឯរដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់ជនទាំងនោះអោយទទួលបានសញ្ជាតិឡើយ។ (សូមមើលផ្នែកទី ៦ ស្តីពីកុមារ)

ការសិក្សាមួយនៅឆ្នាំ២០០៧ ដោយអង្គការ UNHCR ប៉ាន់ប្រមាណថា អ្នកដែលប្រហែលជាគ្មានប្រទេសជាច្រើនពាន់នាក់បានរស់នៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មានរបស់ការសិក្សានេះបានមកពីភស្តុតាងដែលគ្មានលក្ខណៈច្បាស់លាស់ ហើយតំណាងរបស់អង្គការ UNHCR នៅក្នុងស្រុកមិនបានចាត់ទុកថាតួលេខទាំងនេះមានលក្ខណៈប្រាកដប្រជាឡើយ ។ ហេតុផលដែលច្រើនមានជាងគេចំពោះភាពគ្មានប្រទេសគឺកង្វះឯកសារត្រឹមត្រូវពីប្រទេសកំណើត។

អង្គការ UNHCR បានថ្លែងថា ប្រជាជនដែលគ្មានប្រទេសនៅកម្ពុជា ភាគច្រើនគឺក្រុមអាណិកជនវៀតណាម។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិ ច្រើនមិនសូវបានទទួលបានការងារដែលមានលក្ខណៈផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការ និងកម្មសិទ្ធិដីធ្លីទេ។

## ផ្នែកទី៣. សេរីភាពក្នុងការចូលរួមក្នុងដំណើរការនយោបាយ

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនដោយសន្តិវិធី ហើយជាទូទៅប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិនេះនៅក្នុងការអនុវត្តជាក់ស្តែង តាមរយៈការបោះឆ្នោតតាមពេលវេលាទៀងទាត់ និងជាសាកល ។

## ការបោះឆ្នោត និងការចូលរួមផ្នែកនយោបាយ

**<u>ការបោះឆ្នោតជាតិថ្មីៗកន្លងទៅ</u>**៖ ការបោះឆ្នោតជាតិក្នុងពេលថ្មីៗបំផុត ដែលត្រូវបានធ្វើនៅឆ្នាំ ២០១៣ ជារួមមានលក្ខណៈស្ងប់ស្ងាត់ល្អ ដោយគ្រប់គណបក្សទាំងអស់បានចូលរួមដោយគ្មានការជ្រៀតជ្រែក នៅក្នុងយុទ្ធនាការមួយ ដែលជាទូទៅ គ្មានការគំរាមកំហែង ដែលខុសពីការបោះឆ្នោតជាតិពីមុន។ ថ្វីបើមានការរំជើបរំជួលតិចតួចនៅថ្ងៃបោះឆ្នោតក្តី តែដំណើរការបោះឆ្នោតពោរពេញទៅដោយភាពមិនប្រក្រតី ដូចជាមានការចោទប្រកាន់ថា មានច្រើនលើសការរំពឹងទុកនូវចំនួនប័ណ្ណបោះឆ្នោតបណ្តោះអាសន្ន។ តាមការគណនារបស់រដ្ឋាភិបាលខ្លួនឯង អ្នកមានសិទ្ធិបោះឆ្នោតចំនួនជាង ៩%មិនអាចបោះឆ្នោតបាន ដោយសារមានបញ្ហាបញ្ជីអ្នកបោះឆ្នោត។ អង្គកាសង្គមស៊ីវិលជាច្រើនបានរកឃើញបញ្ហានៃអ្នកបោះឆ្នោតដែលនមិនអាចទៅបោះឆ្នោតបាន នៅមុនពេលបោះឆ្នោតទៅទៀត តែគណកម្មាធិការរៀបចំការបោះឆ្នោតមិនបានចាត់វិធានការកែតំរូវជាដុំកំភួនទេ។ អ្នកសង្កេតការណ៍បានបង្ហាញថា កំរិតនៃភាពមិនប្រក្រតីនៃការបោះឆ្នោតគួរតែមានការស៊ើបអង្កេតដោយឯករាជ្យ តែការស៊ើបអង្កេតពេញលេញ និងដោយឯករាជ្យមិនត្រូវបានធ្វើទេ។ គណបក្ស

សង្គ្រោះជាតិមិនចូលប្រជុំសភាទេ រហូតដល់ខែកក្កដា ឆ្នាំ ២០១៤ នៅពេលមានការព្រមព្រៀងជាមួយគណបក្សប្រជាជនដែលដឹកនាំប្រទេស លើកំណែទំរង់នៃគណកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ គណបក្សទាំងពីរថែមទាំងបានយល់ស្របគ្នាប្តូរពេលបោះឆ្នោតមកត្រឹមខែកុម្ភៈ ឆ្នាំ ២០១៨ វិញ ដើម្បីអោយត្រូវនឹងរដូវប្រាំង ដើម្បីអោយមានអ្នកមកបោះឆ្នោតច្រើន។ តែនៅខែសីហា ឆ្នាំ ២០១៥ រដ្ឋាភិបាលបានប្រកាសថា ការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ ២០១៨ វិញ ដែលគេមើលឃើញថា ជាការរំលោភទៅលើកិច្ចព្រមព្រៀង។ ក្នុងពេលដែលកម្ពុជារៀបចំខ្លួនសំរាប់ការបោះឆ្នោតឃុំ នៅឆ្នាំ ២០១៧ និងការបោះឆ្នោតជាតិនៅឆ្នាំ ២០១៨ សកម្មជនក្នុងសង្គមស៊ីវិល និងសកម្មជនសិទ្ធិមនុស្សត្រូវបានគេនិយាយថា មានការបារម្ភក្រែងរដ្ឋាភិបាលប្រើល្បិចបន្ថែមទៀត ដើម្បីគាបសង្កត់លើអ្នកដែលប្រឆាំងនឹងទស្សនៈរបស់ខ្លួន។ អ្នកសង្កេតការណ៍បានសំដែងកង្វល់លើអព្យាក្រិត្យភាពនៃគណកម្មាធិការ នៅពេលសមាជិកដែលតែងតាំងដោយគណបក្ស CNRP ឬមានទំនាក់ទំនងជាមួយគណបក្សនេះនៅក្នុង គជបបានទទួលរងនូវការយាយីតាមផ្លូវច្បាប់យ៉ាងធ្ងន់ធ្ងរ។ រដ្ឋាភិបាលបានចាប់ឃុំអគ្គលេខាធិការរងនៃគជប ឈ្មោះ នី ចរិយា ដោយចោទថា គាត់បានជួយអ្នកការពារសិទ្ធិមនុស្សចំនួន ៤ នាក់នៅក្នុងសមាគមអាដហុក ដែលត្រូវបានចោទពីបទសូកប៉ាន់ស្រីកំណាន់របស់លោក កឹម សុខា តាមការចោទមកនោះ។ ក្រៅពីនេះទៀត តុលាការក្រុងភ្នំពេញបានកោះហៅ លោក រ៉ុង ឈុន ដែលស្ថិតក្នុងចំណោមមនុស្សដែលតែងតាំងដោយគណបក្ស CNRP ពីបទចោទថាបានចូលរួមនៅក្នុងការតវ៉ា ក្នុងឆ្នាំ ២០១៤។

**<u>គណបក្សនយោបាយ និងការចូលរួមនយោបាយ</u>៖** នៅខែតុលា ឆ្នាំ ២០១៥ អ្នកតវ៉ាបានវាយសមាជិកសភាពីររូបនៃគណបក្សប្រឆាំង បន្ទាប់ពីមានការតវ៉ានៅក្រៅរដ្ឋសភាជាតិ។ ក្រុមសង្គមស៊ីវិលខ្លះបាននិយាយថា ការតវ៉ានោះត្រូវបានរៀបចំដោយរដ្ឋាភិបាល។ អ្នកប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមបានអះអាងថា គេស្គាល់ថា យ៉ាងហោចណាស់អ្នកវាយម្នាក់ក្នុងចំណោមអ្នកវាយទាំងនោះគឺជាសមាជិកនៃកងអង្គរក្សរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ នៅខែវិច្ឆិកា ឆ្នាំ ២០១៥ ជនបីរូបនៃជនដែលត្រូវបានគេសង្ស័យថា ជាអ្នកប្រព្រឹត្តដែលសុទ្ធតែជាសមាជិកនៃអង្គភាពកងអង្គរក្សនៃនាយករដ្ឋមន្ត្រី បានប្រគល់ខ្លួនអោយនគរបាល។ គណកម្មាការមួយរបស់រដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដើម្បីស៊ើបអង្កេតលើការវាយដំនោះ បាននិយាយថា ខ្លួននឹងមិនធ្វើការស៊ើបអង្កេតលើជនសង្ស័យបន្ថែមទៀតឡើយ បើគ្មានដីកាតុលាការ ទោះបីជាមានភស្តុតាងវីដេអូនៃការពាក់ព័ន្ធរបស់ជនប្រព្រឹត្តដទៃទៀតក៏ដោយ។ តុលាការបានកាត់ទោសអ្នកប្រព្រឹត្តទាំងនោះអោយជាប់ពន្ធនាគារចំនួន ៤ ឆ្នាំ តែក្រោយមក បានបន្ថយទោសរបស់គេមកនៅត្រឹមមួយឆ្នាំវិញ។

នៅខែវិច្ឆិកា ឆ្នាំ ២០១៥ តុលាការក្រុងភ្នំពេញបានបញ្ជាអោយចាប់ខ្លួនប្រធានគណបក្សប្រឆាំង សមរង្ស៊ី ដោយយោងលើការដាក់ទោសពីបទបរិហារកេរ្តិ៍ ដែលប្តឹងដោយលោកហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស នៅឆ្នាំ ២០០៨។ អ្នកគាំទ្រគណបក្សប្រឆាំងបាននិយាយថា ការប្រទានការលើកលែងទោសដោយព្រះមហាក្សត្រដល់លោក សម រង្ស៊ី នៅឆ្នាំ ២០១៣ ដែលអនុញ្ញាតិអោយគាត់វិលត្រឡប់មកពីការនិរទេសខ្លួនដោយខ្លួនឯង ហើយចូលរួមនៅក្នុងការបោះឆ្នោតនៅឆ្នាំ ២០១៣ បានធ្វើអោយសាលដីកានោះគ្មានសុពលភាព។ តុលាការបានចេញសាលដីកាតែរយៈពេល ២៤ ម៉ោង បន្ទាប់ពីនាយករដ្ឋមន្ត្រីធ្វើការព្រមានជាសាធារណៈដល់លោក រង្ស៊ីថា ការវាយប្រហារជាពាក្យសំដីរបស់លោកទៅលើរដ្ឋាភិបាលអាចនាំដល់ការកាត់ទោសលើរូបលោក។ បន្ទាប់មក រដ្ឋសភាជាតិបានបោះឆ្នោតដកលោក សម រង្ស៊ីចេញពីសភាជាតិ ដែលជាការដកហូតយកអភ័យឯកសិទ្ធិពីរូបលោក។ ការបញ្ជាអោយចាប់ខ្លួនលោក សម រង្ស៊ីមានឡើងនៅពេលលោកស្ថិតនៅក្រៅប្រទេស ដែលអ្នកសង្កេតការណ៍បាននិយាយថា ជាភស្តុតាងថា រដ្ឋាភិបាលមានបំណងរារាំងមិនអោយមេដឹកនាំបក្សប្រឆាំងវិលមកចូលប្រទេសវិញ។

បន្ទាប់មក រដ្ឋាភិបាលបានធ្វើការស៊ើបអង្កេត និងប្តឹងអនុប្រធានបក្សប្រឆាំង កឹម សុខា ដោយផ្តើមចេញពីការចោទប្រកាន់ពីរឿងសាហាស្មន់ជាមួយជាងអ៊ុតសក់អាយុ ២៣ ឆ្នាំ ឈ្មោះ ខុំ ចាន់ដារាទី។ នៅខែកុម្ភៈ ការសន្ទនាតាមទូរស័ព្ទតាមការចោទមក រវាងលោក សុខា និងនាងដារាទីត្រូវបានគេបង្ហោះតាមអ៊ិនធ័រណែត។ នៅក្នុងផ្នែកមួយ មនុស្សប្រុសដែលគេថាជាលោក សុខា បានព្រមផ្តល់ប្រាក់ខ្លះ និងផ្ទះមួយទៅ អោយនារីនោះ។ ផ្អែកលើនេះ អង្គភាពប្រឆាំងអំពើពុករលួយបានបើកការស៊ើបអង្កេតទៅលើហិរញ្ញវត្ថុរបស់លោកកឹម សុខា។ ស្ថាប័នរដ្ឋដទៃទៀត ព្រមទាំងអង្គភាពប្រឆាំងភេរវកម្មរបស់ក្រសួងមហាផ្ទៃ និងតុលាការក្រុងភ្នំពេញ តាមសេចក្តីរាយការណ៍មក បានបើកការស៊ើបអង្កេតលើរឿងនេះដែរ។ នៅថ្ងៃទី ២ ឧសភា សមាជិកសភារបស់គណបក្ស CNRP ត្រូវបានតុលាការកោះហៅ ទាក់ទងនឹងការចោទប្រកាន់ពីបទជួញដូរមនុស្ស ក្នុងការសំរួលការធ្វើដំណើររបស់នាងដារាទីទៅប្រទេសថៃ ដើម្បីជួបជាមួយលោក សុខា។ នៅថ្ងៃទី ១៧ ឧសភា អាជ្ញាធរបានកោះហៅលោក សុខាមកសាកសួរ។ ដោយលើកពីអភ័យឯកសិទ្ធិសភារបស់លោក លោក សុខាមិនព្រមធ្វើតាមកោះហៅនេះ និងការកោះហៅក្រោយមកទៀតទាក់ទងនឹងរឿងនេះ។ នៅថ្ងៃទី ៩ ខែកញ្ញា តុលាការបានកំណត់អោយលោកសុខាជាប់ពន្ធនាគារចំនួន ៥ ខែ និងពិន័យជាប្រាក់ចំនួន ៨០០ ០០០ រៀល ((២០០ ដុល្លា) ចំពោះការមិនធ្វើតាមដីការតុលាការ។ នៅថ្ងៃទី ៤ វិច្ឆិកា សាលាឧទ្ធរណ៍បាន ដំកល់ទោសជាប់ពន្ធនាគារ ៥ ខែនេះ។ អាជ្ញាធរមិនដែលស៊ើបអង្កេតការបែកធ្លាយពីដើមមកនៃការសន្ទនាតាម ទូរស័ព្ទ ដែលត្រូវបានថតនោះទេ។

អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយមួយចំនួន បានចោទប្រកាន់ថា សមាជិកភាព នៅក្នុងគណបក្សប្រជាជនកម្ពុជាដែលដឹកនាំប្រទេស បានផ្ដល់អត្ថប្រយោជន៍ ដូចជាអំណោយ ជំនួយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល និងសម្បទានដីសេដ្ឋកិច្ច ។ នៅខែមិថុនា ឆ្នាំ ២០១៥ រដ្ឋាភិបាលបានប្រកាសថា ឯកអគ្គរដ្ឋទូតរបស់ខ្លួនដែលបំរើការនៅបរទេស ក៏បំរើ “គណៈកម្មាធិការនាយក”របស់គណបក្សប្រជាជនដែរ ហើយត្រូវមាននាទីដឹកនាំយុទ្ធនាការប្រមូលសមាជិក ហើយរៃអង្គាសប្រាក់ជំនួយអោយគណបក្សប្រជាជន នៅក្នុងប្រទេសដែលគេធ្វើការ។ នៅខែវិច្ឆិកា ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូងបានប្រាប់ពលរដ្ឋខ្មែរដែលរស់នៅក្នុងប្រទេសកូរ៉េខាងត្បូងថា គេអាចប្រឈមនឹងការចាប់ខ្លួន ឬការបណ្ដេញចេញ បើគេចូលរួមក្នុងការជួបជុំគ្នាដែលគាំទ្រគណបក្សប្រឆាំង រៀបចំដោយមេដឹកនាំគណបក្សប្រឆាំងដែលកំពុងធ្វើទស្សនកិច្ចនៅទីនោះ។

លោកសង្ឃជាដរាបមក មានការពិបាកក្នុងការចុះឈ្មោះបោះឆ្នោត ឬត្រូវបានគេមិនអោយចូលរួមពេញលេញនៅក្នុងដំណើរការបោះឆ្នោត។ ព្រះសង្ឃរាជមហានិកាយបានអំពាវនាវកុំអោយព្រះសង្ឃចូលរួមក្នុងការបោះឆ្នោតនៅក្នុងប្រទេស ហើយបានសុំអោយរដ្ឋាភិបាលចេញច្បាប់ហាមប្រាមដូច្នេះ។ គជបរាយការណ៍ថា ទោះបីជាខ្លួនគាំទ្រសិទ្ធិបោះឆ្នោតរបស់លោកសង្ឃក្តី តែក្រសួងមហាផ្ទៃមិនព្រមចេញប័ណ្ណបោះឆ្នោតអោយលោកសង្ឃទេ។

គិតមកដល់ខែកញ្ញា ក្រសួងមហាផ្ទៃមិនបានបញ្ចេញព័ត៌មានស្តីពីចំនួនគណបក្សនយោបាយដែលទើបចុះបញ្ជីថ្មី តែផ្នែកសារព័ត៌មានបានប្រាប់ពីគណបក្សថ្មីមួយចំនួន។

**<u>ការចូលរួមរបស់ស្ត្រី និងក្រុមជនជាតិភាគតិច</u>**៖គ្មានច្បាប់ដែលដាក់កំហិតព្រំដែនលើការចូលរួមរបស់ស្ត្រី និងជនជាតិភាគតិច នៅក្នុងដំណើរការនយោបាយទេ តែវប្បធម៌ប្រពៃណីកម្រិតការចូលរួមរបស់ ស្ត្រីនៅក្នុងរដ្ឋាភិបាល ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីបានចូលរួមនៅក្នុងការបោះឆ្នោតជាតិ ឆ្នាំ ២០១៣។

## ផ្នែកទី៤ ៖ អំពើពុករលួយ និងកង្វះតម្លាភាពក្នុងរដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនានា ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់តែងតែប្រព្រឹត្តអំពើពុករលួយដោយមាននិទណ្ឌភាព ។

**អំពើពុករលួយ៖** ក្រុមព្រហ្មទណ្ឌបានកំណត់អំពើពុករលួយនានា ហើយកំណត់ច្បាស់នូវទោសចំពោះការប្រព្រឹត្តអំពើទាំងនេះ។ ច្បាប់ប្រឆាំងអំពើពុករលួយចែងពីមូលដ្ឋានច្បាប់សំរាប់អោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយទទួល និងស៊ើបអង្កេតបណ្តឹងទាក់ទងនឹងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយមិនសហការអោយបានញឹកញាប់ជាមួយសង្គមស៊ីវិល ហើយត្រូវបានគេមើលឃើញថា គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ នៅខែមិថុនា ឆ្នាំ ២០១៥ ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលជាស្ថាប័នក្នុងសាខាប្រតិបត្តិ បានចេញបទបញ្ជាតំរូវអោយមន្ត្រីរាជការត្រូវមានការយល់ព្រមពីប្រធាន មុនពេលឆ្លើយសំណួររបស់សាខានិតិបញ្ញាតិ ទាក់ទងនឹងការចោទប្រកាន់ទាក់ទងនឹងអំពើពុករលួយ។

អំពើពុករលួយមានលក្ខណៈរាលដាល និងទូលំទូលាយនៅគ្រប់ផ្នែកនៃសង្គម និងគ្រប់ផ្នែកទាំងអស់ក្នុងរដ្ឋាភិបាល។ មានសេចក្តីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជំរះក្តី បានទទួលសំណូកពីអ្នករកស៊ីខុសច្បាប់។ ពលរដ្ឋតែងតែត្អូញត្អែជាសាធារណៈអំពីអំពើពុករលួយ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកអោយ មាន“អំពើពុករលួយដើម្បីរស់” ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៍និទណ្ឌភាពធ្វើអោយអំពើពុករលួយរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។

យោងតាមអង្គការ NGO មួយដែលធ្វើការតាមដានអំពើពុករលួយ នៅឆ្នាំ ២០១៥ មានករណីពុករលួយចំនួន ២៩៧ (នៅក្នុងឆ្នាំ ២០១៤ មាន ២១៧) ១១ ករណីទាក់ទងនឹងការការរំលោភអំណាចធ្ងន់ធ្ងរដោយមេដឹកនាំជាន់ខ្ពស់នៅក្នុងសាខាតុលាការ និតិប្រតិបត្តិ និងនិតិបញ្ញតិ ១៣៥ ករណី ពាក់ព័ន្ធនឹងការស្មុកប៉ាន់ និងការកេងបន្លំដោយមន្ត្រីសាធារណជាន់ខ្ពស់ ១៣៣ ករណីពាក់ព័ន្ធនឹងការប្រើធនធានរបស់រដ្ឋដោយមិនត្រឹមត្រូវ ដើម្បីបំណងនយោបាយ ហើយ ១៨ ករណីពាក់ព័ន្ធនឹងការនិយមបក្សពួក។ របាយការណ៍មួយទៀតនិយាយពីភាគហ៊ុនដ៏ច្រើនរបស់សមាជិកគ្រួសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

**ការប្រកាសទ្រព្យសម្បត្តិ៖** រាជការ រួមទាំងមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោតផង តាមច្បាប់ ត្រូវប្រកាសទ្រព្យសម្បត្តិរបស់គេ។ អង្គភាពប្រឆាំងអំពើពុករលួយទទួលខុសត្រូវក្នុងការទទួលយកសេចក្តីប្រកាស ចំណែកការពិន័យចំពោះការមិនគោរពតាមមានការជាប់ពន្ធនាគាររាប់ពី ១ ខែទៅ ១ ឆ្នាំ។ នៅឆ្នាំ ២០១៥ ACU បានរាយការណ៍ថា ក្នុងចំណោមមន្ត្រីរដ្ឋាភិបាលចំនួន ៥ ២៥៥ នាក់ដែលត្រូវបានតំរូវអោយប្រកាសទ្រព្យសម្បត្តិ មាន ៩៩,៩% បានគោរពតាមការតំរូវ។ ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីជាន់ខ្ពស់មិនត្រូវបានអោយដឹងដល់សាធារណៈទេ ហើយនៅបិទជិតក្នុងស្រោមសំបុត្រ រហូតទាល់តែមានការប្តឹងទាក់ទងនឹង

អំពើពុករលួយ។ នៅខែមិនា ACU បានប្រកាសថា ខ្លួននឹងបើកស្រោមសំបុត្ររបស់លោក កឹម សុខា ដោយសារមានការចោទប្រកាន់ថា លោកបានសន្យាទិញដី និងផ្តល់លុយដល់ស្រីកំណាន់តាមការចោទមករបស់គាត់។ កន្លងមក មិនដែលមានការបើកស្រោមសំបុត្រប្រកាសទ្រព្យសម្បត្តិទេ។

**<u>លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន៖</u>** ច្បាប់អនុញ្ញាតអោយគេមើលឯកសារព័ត៌មានដោយគ្មានកំណត់ នៅក្នុងប័ណ្ណសារសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះផ្តល់លទ្ធភាពអោយមើលឯកសាររដ្ឋាភិបាលដែលមិនត្រូវបានបញ្ជាក់ច្បាស់ តែក្នុងរយៈ ២០ ឆ្នាំក្រោយមកតែប៉ុណ្ណោះ ចំណែកឯកសារប៉ះពាល់ដល់សន្តិសុខជាតិ និងការពារជីវិតផ្ទាល់ខ្លួនអាចបញ្ចេញអោយបានបន្ទាប់ពីរយៈពេល ៤០ឆ្នាំ និង ១២០ ឆ្នាំក្រោយមកតែប៉ុណ្ណោះ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា នៅក្នុងភាពជាក់ស្តែង ខ្លួនមានការលំបាកក្នុងការសុំបានព័ត៌មានមកមើល។ រដ្ឋាភិបាល ជាញឹកញាប់ មិនបាន ឬមិនអាចឆ្លើយតបចំពោះសំណើសុំព័ត៌មានបានឡើយ ។

## ផ្នែកទី៥ ៖ ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិផ្សេងៗ ជាទូទៅ ធ្វើការដោយគ្មានការរឹតត្បិតពីរដ្ឋាភិបាលឡើយ ក្នុងការស៊ើបអង្កេត និងផ្សាយរបកគំហើញអំពីករណីសិទ្ធិមនុស្សរបស់ខ្លួន ។ ជារឿយៗមន្ត្រីរដ្ឋាភិបាលបានសហការជាមួយបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍ជាច្រើនអំពីកង្វះការសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័យដោយមន្ត្រី រដ្ឋាភិបាល ដូចជាករណីប្រឆាំងនឹងសមាគមអាដហុក (សូមមើលផ្នែក ១ ង) ។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិជួបប្រទះការគម្រាមកំហែង និងការធ្វើទុក្ខបុកម្នេញពីមន្ត្រីមូលដ្ឋាន ។ អំពើទាំងនេះមានលក្ខណៈជាទម្រង់រឹតត្បិត និងការរំខានដល់ការជួបប្រជុំដែលឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាលនានា ការបំភិតបំភ័យដោយពាក្យសម្តី ការគម្រាមចាត់វិធានការផ្លូវច្បាប់ និងការរារាំងតាមបែបការិយាធិបតេយ្យ ដោយផ្អែកលើបញ្ញត្តិក្នុងច្បាប់អង្គការ ។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ២៥ នៅក្នុងប្រទេស និងមានចំនួនប្រហែល ១០០ ទៀតដែលផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្សជាផ្នែកមួយនៃការងាររបស់

គេនៅក្នុងវិស័យផ្សេងទៀត ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ។

**<u>អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត</u>**៖ រដ្ឋាភិបាលជាទូទៅបានសហការជាមួយអង្គការអន្តរជាតិហើយបានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច ។ អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី Rhona Smith បានមកធ្វើទស្សនកិច្ចនៅកម្ពុជាចំនួន ១ ដង កាលពីខែមិនា ដើម្បីពិនិត្យមើលស្ថានភាពនៃក្រុមដែលស្ថិតក្នុងស្ថានភាពខ្សត់ខ្សោយ និងមិនសូវទទួលបានការយកចិត្តទុកដាក់ ដូចជាក្រុមស្រ្តី ជនជាតិភាគតិច និងជនរងគ្រោះដោយការប្រកាន់ពូជសាសន៍ និងប្រកាន់ជាតិពន្ធ ។ លោកស្រី Rhona Smith បានបន្តធ្វើទស្សនកិច្ចបន្ថែមទៀត នៅទីក្រុងភ្នំពេញនៅខែតុលា។ មន្ត្រីច្រើនតែលើក “ហេតុផលរដ្ឋបាល” ដើម្បីពន្យល់ពីការដែលមន្ត្រីរដ្ឋាភិបាលមិនចង់ជួបលោកស្រី។ រដ្ឋាភិបាលតែងតែរិះគន់តំណាងពិសេសនៃអង្គការសហប្រជាជាតិជាសាធារណៈ ចំពោះការនិយាយរបស់គេស្តីពីបញ្ហានានាផ្នែកសិទ្ធិមនុស្ស។

**<u>ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល</u>**៖ រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ ដែលរួមមានគណៈកម្មាធិការដាច់ដោយឡែកចំនួន ២ ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង ដោយស្ថាប័នមួយស្ថិតក្រោមព្រឹទ្ធសភា និងមួយទៀតស្ថិតក្រោមរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលស្ថិតនៅក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការទាំងនេះពុំមានការប្រជុំទៀងទាត់ ឬដំណើរការប្រកបដោយតម្លាភាពឡើយ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រគល់របាយការណ៍របស់រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្សជាអន្តរជាតិ ដូចជាការពិនិត្យទៀងទាត់ជាសកល និងបានឆ្លើយតបចំពោះរបាយការណ៍របស់ស្ថាប័នរដ្ឋាភិបាលអន្តរជាតិ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតស្ថានភាពសិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលគួរឱ្យទុកចិត្តបាន ចាត់ទុកសមត្ថភាពរបស់គណៈកម្មាធិការរបស់រដ្ឋាភិបាលថា នៅមានកម្រិត។

រដ្ឋាភិបាលបានធ្វើជាម្ចាស់ផ្ទះសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ដែលដំណើរការរួមគ្នាជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននៅសម័យខ្មែរក្រហម ។ អ្នកសង្កេតការណ៍ខ្លះមានជំនឿថា សេចក្តីអត្ថាធិប្បាយជាសាធារណៈរបស់អ្នកដឹកនាំរដ្ឋាភិបាលអំពីបញ្ហាទាក់ទងនឹងអាណាត្តិយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាគឺជាទម្រង់មួយនៃការជ្រៀតជ្រែករបស់អ្នកនយោបាយ ។ទោះជាយ៉ាង

ណាក៏ដោយ គ្មានភស្តុតាងដែលបង្ហាញថា សេចក្តីអត្ថាធិប្បាយទាំងនោះ បានរាំងស្ទះដល់ការងាររបស់តុលាការឡើយ។ នៅដំណាច់ឆ្នាំ ២០១៥ តុលាការបានបើកសវនាការទាក់ទងនឹងចុងចោទនៃរបបនោះ ដែលរួមមានអំពើប្រល័យពូជសាសន៍លើក្រុមជនជាតិភាគតិចចាម ការបង្ខំអោយរៀបការ ការរំលោភផ្លូវភេទ ការធ្វើវិសុទ្ធកម្មផ្ទៃក្នុង និងបទចោទប្រកាន់ពីអំពើឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខខ្លះ និងនៅតាមការដ្ឋាន។

## ផ្នែកទី៦៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញហាមប្រាមការរើសអើងទាក់ទងនឹងពូជសាសន៍ យេនឌ័រ ពិការភាព ភាសា ឬឋានៈសង្គម ប៉ុន្តែ ជាទូទៅ រដ្ឋាភិបាលមិនបានអនុវត្តបំរាមទាំងនេះអោយមានប្រសិទ្ធភាពឡើយ ។

## ស្ត្រី

**ការ<u>រំលោភសេពសន្ថវៈ និងហិង្សាក្នុងគ្រួសារ</u>៖** ច្បាប់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើរំលោភសេពសន្ថវៈ និងការបំពារបំពាន។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិបានរាយការណ៍ថា អំពើហិង្សាប្រឆាំងស្ត្រី មានដូចជាអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ កើតមានជាទូទៅ។ អំពើរំលោភសេពសន្ថវៈត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ។ អំពើរំលោភសេពសន្ថវៈ ប្តី/ប្រពន្ធមិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែ អាចធ្វើការចោទប្រកាន់ថាជា “អំពើរំលោភសេពសន្ថវៈ” “ការបង្ករបួសស្នាម” ឬ “ការបំពារបំពានមិនសមរម្យ”បាន។ យោងតាមច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈប្តី/ប្រពន្ធអាចស្ថិតនៅក្នុងនិយមន័យនៃអំពើហិង្សាក្នុងគ្រួសារដែលរួមបញ្ចូល “ការបំពានផ្លូវភេទ” ផងដែរ។ កម្រមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈប្តី/ប្រពន្ធតាមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារណាស់។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកំណត់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ មិនមានចែងជាក់លាក់អំពីការដាក់ទោសឡើយ។ ប៉ុន្តែ គេអាចប្រើក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសចំពោះបទល្មើសហឹង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារចាប់ពី ១ ឆ្នាំរហូតដល់ ១៥ឆ្នាំ។ បើយោងតាមរបាយការណ៍របស់អង្គការ លើកលែងទោសអន្តរជាតិ ឈ្មោះ Amnesty International មានមន្ទីរពេទ្យរដ្ឋតែមួយនៅតាមខេត្តនិមួយៗនិងមន្ទីរពេទ្យធំៗមួយចំនួន នៅភ្នំពេញ ដែលមានកន្លែងគ្រប់គ្រាន់សំរាប់ពិនិត្យជនរងគ្រោះដោយការរំលោភផ្លូវភេទ ហើយចេញប័ណ្ណបញ្ជាក់ដែលអាចយកជាភស្តុងតាងបានដោយតុលាការ។

គិតមកត្រឹមខែតុលាក ឆ្នាំ ២០១៥ អង្គការមិនមែនរដ្ឋាភិបាលមួយ ឈ្មោះអាដហុកបានទទួលរបាយការណ៍អំពីករណីរំលោភសេពសន្ថវៈចំនួន ១៨៣ ករណី ដោយក្នុងនោះ មាន ៣ ករណីបណ្តាលអោយជនរងគ្រោះស្លាប់ ។ នៅក្នុងចំណោមករណីទាំងនេះ មាន ៣៣ ករណី ត្រូវបានកាត់ក្តីដោយតុលាការ ១ ករណីត្រូវបានសម្របសម្រួលដោយអាជ្ញាធរដែនដី ហើយករណីដែលនៅសល់នៅរង់ចាំសវនាការ។ អំពើហិង្សាក្នុងគ្រួសារនិងការរំលោភផ្លូវភេទមានការកើនឡើង បើប្រៀបធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៤ តែច្រើនតែមិនត្រូវបានគេរាយការណ៍អស់ ដោយសារស្ត្រីខ្លាចការសងសឹកដោយជនល្មើស។ នៅខែមករា ក្រសួងផែនការ និងក្រសួងកិច្ចការនារីបានចេញការអង្កេតថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រី។ ការអង្កេតនេះបង្ហាញថា ស្ត្រីម្នាក់ក្នុងចំណោម ៥ នាក់នៅក្នុងប្រទេសរងហិង្សាក្នុងគ្រួសារ និងហិង្សាផ្លូវ ភេទ។ បើយោងតាមក្រសួងមហាផ្ទៃ ការរំលោភផ្លូវភេទមានការកើនឡើងចំនួន ១២ % លើសឆ្នាំ ២០១៤ ទោះបីជាបទល្មើសទូទៅមានការថយចុះក្តី។ នៅក្នុងរបាយការណ៍ឆ្នាំ ២០១៣ របស់សហប្រជាជាតិ ជិត ២០% នៃបុរសចំនួន ១៨៦៣ នាក់ ដែលត្រូវបានសំភាសន៍ បានសារភាពថា បានរំលោភស្ត្រី។

នៅខែកក្កដា ក្រសួងកិច្ចការនារីបានប្រជុំជាមួយតំណាងនៃរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីពិភាក្សាពីការអនុវត្តផែនការសកម្មភាពជាតិលើកទី ២ ស្តីពីការការពារហិង្សាលើស្ត្រី ដែលរួមមានទាំងហិង្សាផ្លូវភេទនិងហិង្សាប្រព្រឹត្តដោយដៃគូ។ ក្រសួងបានប្រកាសប្រព័ន្ធរាយការណ៍ថ្មីមួយនៅក្នុងរដ្ឋាភិបាល ដើម្បីបង្កើនតំលាភាព និងគណនេយ្យភាព នៅក្នុងករណីដែលរដ្ឋាភិបាលឆ្លើយតបនឹងហិង្សាទៅលើស្ត្រី។ ក្រសួងកិច្ចការនារីថែមទាំងបានសំរបសំរួលអង្គការ NGO មួយចំនួន និងផ្នែកសារព័ត៌មានខ្លះ ដើម្បីធ្វើកម្មវិធីតាមវិទ្យុ និងទូរទស្សន៍ស្តីពីបញ្ហាទាក់ទងនឹងស្ត្រី។ រដ្ឋាភិបាលថែមទាំងបានផ្តល់ថវិកាដល់អង្គការ NGO ដែលបានផ្តល់ការបណ្តុះបណ្តាលសំរាប់ស្ត្រីក្រីក្រ ដែលងាយរងគ្រោះដោយការធ្វើបាបដោយប្តី ពេស្យាចារ និងការជួញដូរមនុស្ស។

ដោយគិតមកត្រឹមខែសីហា អង្គការអាដហុកបានធ្វើការស៊ើបអង្កេតលើករណីហិង្សាក្នុងគ្រួសារចំនួន ៥២ ករណី ករណីសេពសន្ថវៈចំនួន ៦៧ ករណី ចំណែកអង្គការសិទ្ធិមនុស្សលីកាដូបានស៊ើបអង្កេតករណីហិង្សាដោយឡែកក្នុងគ្រួសារចំនួន ៦២ និងករណីរំលោភផ្លូវភេទចំនួន ៣៣ ករណី។ អង្គការ NGO បាននិយាយថា អាជ្ញាធរមិនសូវប្រឹងប្រែងខ្លាំងក្នុងការអនុវត្តច្បាប់គ្រួសារទេ ហើយជៀសវាងការពាក់ព័ន្ធក្នុងជំលោះក្នុងគ្រួសារ។

***ការបៀតបៀនផ្លូវភេទ៖*** ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌចំពោះការបៀតបៀនផ្លូវភេទ ដោយដាក់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ និងពិន័យជាទឹកប្រាក់ចំនួនពី ១០០ ០០០រៀលទៅ ៥០០ ០០០រៀល (២៥ ទៅ ១២៥ ដុល្លារអាមេរិក)។ អង្គការ ILO នៅក្នុងរបាយការណ៍ឆ្នាំ ២០១៣ របស់ខ្លួន បាននិយាយថា កម្មករិនីកាត់ម្នាក់ក្នុងចំណោម ៥ នាក់បានរងការបៀតបៀនផ្លូវភេទ។ នៅខែឧសភា អាជ្ញាធរបានបកសក្តិមន្ត្រីជាន់ខ្ពស់ម្នាក់មកពីក្រសួងអប់រំ បន្ទាប់ពីគាត់បានបៀតបៀនផ្លូវភេទលើអ្នកបកប្រែភាសាជាជនជាតិកូរេខាងត្បូងម្នាក់ ដែលគេបានអោយមកធ្វើការជាមួយគាត់ ក្នុងអំឡុងទស្សនកិច្ចជាផ្លូវការនៅប្រទេសកូរេខាងត្បូង។ មន្ត្រីបានទំលាក់ការចោទប្រកាន់ បន្ទាប់ពីកាត់បានបង់ប្រាក់ពិន័យចំនួន ១២ ៣០០ ដុល្លាអាមេរិក។ សកម្មជនជាច្រើនបានអះអាងថា ទណ្ឌកម្មនោះតិចពេក តែក្រសួងបានបញ្ជាក់ថា ការសំរេចចិត្តរបស់ខ្លួនក្នុងការបញ្ចុះឋានៈបុគ្គលនោះគឺផ្អែកលើច្បាប់គ្រប់គ្រងមន្ត្រីរាជការ។

***សិទ្ធិបន្តពូជ៖*** គូស្វាមីភរិយា និងបុគ្គលម្នាក់ៗអាចសម្រេចចិត្តលើចំនួនកូនដែលចង់បាន គម្លាតមានកូន និងពេលមានកូន ហើយពួកគេមានព័ត៌មាន និងមធ្យោបាយដើម្បីធ្វើការសម្រេចចិត្តដោយសេរី ដោយគ្មានការរើសអើង ការបង្ខំ ឬហឹង្សា។ ស្ត្រីមានសិទ្ធិទទួលសេវាពន្យារកំណើត និងការថែទាំមុនពេលសម្រាល ព្រមទាំងឆ្មបមានជំនាញ និងការថែទាំក្រោយពេលសម្រាលផងដែរ ប៉ុន្តែជារឿយៗ សិទ្ធិនេះនៅមានកម្រិតដោយសារ ឧបសគ្គប្រាក់ចំណូល និងកត្តាភូមិសាស្ត្រ។ យោងតាមអង្គការសុខភាពពិភពលោក ប្រទេសកម្ពុជា មានអត្រាមរណៈមាតា នៅឆ្នាំ ២០១៥ ចំនួន ១៦១ នាក់ក្នុងទារកកើតរស់ចំនួន ១០០ ០០០នាក់ ។ នៅក្នុងឆ្នាំ ២០១៤ មាន១៧០ នាក់ ក្នុងចំណោមទារកកើតមករស់ចំនួន ១០០ ០០០ នាក់។ កត្តាចម្បង ដែលមានឥទ្ធិពលលើអត្រាមរណៈមាតាខ្ពស់នៅក្នុងប្រទេសរួមមានកង្វះមណ្ឌលសុខភាពត្រឹមត្រូវ ថ្នាំសង្គ្រោះ និងកង្វះឆ្មបមានជំនាញត្រឹមត្រូវ។ បើយោងតាមការអង្កេតផ្នែកសុខភាពនិងប្រជាសាស្ត្រនៅកម្ពុជា ក្នុងឆ្នាំ ២០១៤ អត្រាប្រេវ៉ាឡង់នៃការប្រើមធ្យោបាយពន្យារកំណើតក្នុងចំណោមស្ត្រីដែលរៀបការហើយ និងស្ថិតក្នុងអាយុពី ១៥ ទៅ ៤៩ ឆ្នាំ គឺមានប្រហែល ៣៩% ហើយស្ត្រីចំនួន ១២% ដែលស្ថិតក្នុងអាយុពី ១៥ ទៅ ១៩ ឆ្នាំបានឆ្លងទន្លេ ឬមានផ្ទៃពោះកូនដំបូង។

***ការរើសអើង៖*** រដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិស្មើភាពគ្នាសំរាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៍ពិពាហ៍។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិតាមផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ប៉ុន្តែ ប្រពៃណីវប្បធម៌ និងការទទួលខុសត្រូវក្នុងការមើលកូនបានកម្រិតលទ្ធភាពរបស់ស្ត្រីដើម្បីឈាន

ទៅដល់ការទទួលបានមុខតំណែងខ្ពស់នៅក្នុងការងារ ឬបានការងារធ្វើ។ បុរសយ៉ាងច្រើនលើសលុបបម្រើការងារយោធា នគរបាល និងការងាររាជការស៊ីវិល។

## កុមារ

**<u>ការចុះសំបុត្រកំណើត</u>៖** តាមច្បាប់ សញ្ជាតិអាចទទួលបានតាមរយៈកំណើតពីឪពុកម្តាយដែលមិនមែនជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះបានកើត និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ទទួលបានសញ្ជាតិកម្ពុជា។ ក្រសួងមហាផ្ទៃបានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើតតាមបែបទំនើប ប៉ុន្តែទារកទាំងអស់មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ដោយសារតែឪពុកម្តាយពន្យារពេល។ ក្រៅពីនេះ កុមារដែលបានកើតចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ជាទូទៅ មិនត្រូវបានចុះបញ្ជីកំណើតឡើយ ដោយសារការគ្រប់គ្រងរបស់វៀតណាម/ខ្មែរក្រហម/សង្គ្រាមស៊ីវិល។ អ្នកដែលមិនបានចុះបញ្ជីទាំងនេះជាច្រើន ដែលក្រោយមកមានគ្រួសារផ្ទាល់ខ្លួន មិនបានយល់អំពីភាពចាំបាច់នៃការចុះបញ្ជីនេះទេ។ ជាទូទៅ កុមារមិនទៅចុះបញ្ជីកំណើតឡើយ រហូត ទាល់តែគេត្រូវការចាំបាច់។

ការខកខានមិនបានចុះបញ្ជីកំណើតនាំអោយមានការរើសអើង រួមទាំងការមិនផ្តល់សេវាសាធារណៈផង។ ការសិក្សាមួយនៅឆ្នាំ ២០០៧ ដែលធ្វើឡើងដោយអង្គការ UNHCR ស្តីពីភាពគ្មានសញ្ជាតិនៅក្នុងប្រទេសកម្ពុជាបាននិយាយថា ជារឿយៗ កុមារជនជាតិភាគតិច និងកុមារដែលគ្មានសញ្ជាតិត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាចំពោះសហគមន៍ដែលត្រូវបានគេផាត់ចេញ បានរាយការណ៍ថា ជារឿយៗ កុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារ បាត់បង់លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះក៏បានបញ្ជាក់ផងដែរថា អ្នកទាំងនេះច្រើនតែគ្មានលទ្ធភាពក្នុងការទទួលបានការងារធ្វើ ការមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការចូលរួមបោះឆ្នោត ឬការប្រើប្រាស់ប្រព័ន្ធច្បាប់។

**<u>ការអប់រំ</u>៖** ការអប់រំរហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយ ប៉ុន្តែ មិនមែនជាកាតព្វកិច្ចត្រូវតែរៀនទេ។ កុមារជាច្រើនបានឈប់រៀនដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត ចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែ ជារឿយៗ គ្រួសារដែលមានធនធានមានកំរិត ផ្តល់អាទិភាពដល់ក្មេងប្រុសជាងក្មេងស្រី ពិសេសនៅតំបន់ជនបទ។ បើយោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពី

កម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំងនៅតំបន់ក្រុង ចំណែកការចូលរៀនរបស់ក្មេងប្រុសនៅក្រោយថ្នាក់បឋមសិក្សា មានចំនួនធ្លាក់ចុះច្រើនគួរសម នៅតំបន់ជនបទ។ សាលារៀននៅក្នុងតំបន់ជាច្រើនស្ថិតនៅឆ្ងាយពីផ្ទះ ហើយការធ្វើដំណើរក៏ជាបញ្ហាមួយផងដែរ។ កត្តានេះបានធ្វើឱ្យប៉ះពាល់ដល់ក្មេងស្រីជាពិសេស ដោយសារកង្វល់ពីសុវត្ថិភាពក្នុងការធ្វើដំណើរពីផ្ទះទៅសាលារៀន។

<u>**ការធ្វើបាបកុមារ៖**</u> បើតាមអ្នកសង្កេតការណ៍ ការធ្វើបាបកុមារត្រូវគេបានជឿថា មានជាទូទៅ ហើយការប្តឹងប្រឆាំងនឹងជនប្រព្រឹត្តកម្រមានណាស់។ របាយការណ៍ឆ្នាំ ២០១៤ របស់អង្គការ UNICEF និយាយថា ៦១% នៃកុមារីដែលឆ្លើយសំណួរ និង ៥៨% នៃកុមារាដែលឆ្លើយសំណួរ ដែលស្ថិតក្នុងអាយុពី ១៣ ទី ១៧ ឆ្នាំបានរងការវាយដំនៅក្នុងគ្រួសារ។ ការរំលោភសេពសន្ថវៈកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅឡើយ។ អង្គការមិនមែនរដ្ឋាភិបាល ADHOC បានរាយការណ៍ ថា ករណីរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈចំនួន ៩៩ ករណីបានកើតឡើងចំពោះកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ។ អង្គការលីកាដូបានធ្វើការស៊ើបអង្កេតលើករណីរំលោភផ្លូវភេទចំនួន ១១៦ ក្នុងនោះមានការរំលោភបូកចំនួន ៤ ករណី។

<u>**ការឆាប់រៀបអាពាហ៍ពិពាហ៍ និងការបង្ខំអោយរៀបអាពាហ៍ពិពាហ៍៖**</u> អាយុគ្រប់ការតាមច្បាប់សំរាប់ក្មេងប្រុស និងក្មេងស្រីគឺ ១៨ ឆ្នាំ តែកុមារអាយុត្រឹម ១៦ ឆ្នាំអាចរៀបការដោយស្របច្បាប់បាន បើមានការយល់ព្រមពីឪពុកម្តាយ។ តាមប្រពៃណីវប្បធម៌ ការរៀបការរបស់កុមារមិនត្រូវបានចាត់ទុកថា ជាបញ្ហាទេ។ រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានលើកកំពស់ការយល់ដឹងលើអាយុអប្បបរិមាដូចដែលត្រូវបានកំណត់ដោយច្បាប់។

<u>**ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖**</u> ការរួមភេទជាមួយកុមារអាយុក្រោម ១៥ ឆ្នាំ គឺជាអំពើខុសច្បាប់។ ប៉ុន្តែពេស្យាចារ្យកុមារបានកើតឡើង។ នគរបាលបានបន្តឆ្មក់ចូលផ្ទះបន ដើម្បីសង្គ្រោះក្មេងស្រីមិនគ្រប់អាយុដែលត្រូវបានគេជួញដូរធ្វើពេស្យា ថ្វីបើភាគច្រើននៃការជួញដូរផ្លូវភេទលើកុមារមានការលាក់បាំង មាននៅតាមកន្លែងបំរើផ្លូវភេទ “ដោយមិនផ្ទាល់” ដូចជាតាមបៀហ្គាដិន កន្លែងធ្វើម៉ាសា កន្លែងកែសម្ផស្ស បាខារ៉ាអូខេ និងកន្លែងមិនមែនធ្វើពាណិជ្ជកម្មនានា។ នគរបាលបន្តស៊ើបអង្កេតលើករណីជួញដូរកុមារ នៅតាមផ្ទះបន ឬក្នុងករណីដែលជនរងគ្រោះមកប្តឹងដោយផ្ទាល់ តែមិនធ្វើការលើករណីស្មុគស្មាញខ្លាំងទេ។ រដ្ឋាភិបាលមិនបានចេញការណែនាំជាផ្លូវការដែលអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់នៅក្នុងការស៊ើបអង្កេតលើការជួញដូរទេ ហើយកង្វះសិទ្ធិអំណាចច្បាស់លាស់បានបន្តរាំងស្ទះមិនអោយនគរបាលចាប់អោយអ្នកប្រព្រឹត្តិការជួញដូរលើកុមារទទួលខុសត្រូវពេញលេញបានទេ។

ប្រទេសកម្ពុជានៅតែជាគោលដៅទេសចរណ៍ផ្លូវភេទលើកុមារ។ អង្គការ NGO មួយបានចេញរបាយការណ៍ឆ្នាំ ២០១៥ ដោយពិនិត្យលើការមានកុមារជាច្រើននៅក្នុងចំណោមមនុស្សនៅកន្លែងបំរើផ្លូវភេទនៅតាមទីក្រុងសំខាន់ ៣ ហើយបានរកឃើញថា កុមារមានចំនួនត្រូវជា ២,២% នៃមនុស្សនៅទីនោះ ចំណែកនៅឆ្នាំ ២០១៣ មាន ៨,២%។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ ដើម្បីកាត់ទោសទាំងអ្នកទេសចរផ្លូវភេទ ទាំងពលរដ្ឋដែលកេងប្រវ័ញ្ចកុមារក្នុងពេស្យាចារ។ ច្បាប់ដាក់ទោសជាប់ពន្ធនាគារចាប់ពី ២ ទៅ ១៥ ឆ្នាំ ចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ច្បាប់នេះក៏ហាមប្រាមផងដែរនូវការផលិត និងការមានរូបអាសអាភាសកុមារ។

បើយោងតាមអង្គការផ្នែកសិទ្ធិមនុស្សក្នុងស្រុកមួយ ជនប្រព្រឹត្តដែលមានខ្សែរយៈក្នុងរដ្ឋាភិបាលមិនត្រូវបានចាប់អោយទទួលខុសត្រូវ នៅក្រោមច្បាប់ឡើយ ហើយអ្នកជំនាញក្នុងស្រុកបានសំដែងកង្វល់អំពីការខកខានរបស់រដ្ឋាភិបាល ក្នុងការដាក់ទោសអោយបានសមស្របទៅលើជនបរទេសដែលទិញការរួមភេទជាមួយកុមារ។ អំពើពុករលួយដែលរាលដាលនៅគ្រប់ផ្នែកទាំងអស់ក្នុងរដ្ឋាភិបាលដាក់កំហិតព្រំដែនយ៉ាងខ្លាំងលើលទ្ធភាពរបស់មន្ត្រីម្នាក់ៗ ក្នុងការចាប់អោយជនប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារទទួលខុសត្រូវ ហើយរដ្ឋាភិបាលមិនធ្វើការស៊ើបអង្កេតឬកាត់ទោសមន្ត្រីដែលឃុបឃិតឡើយ។

**<u>កុមារផ្លាស់ទីលំនៅ</u>**៖ រដ្ឋាភិបាលបានផ្តល់សេវាមានកំរិត និងមិនគ្រប់គ្រាន់ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់នៅមជ្ឈមណ្ឌលស្តារនីតិសម្បទា។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវក្នុងចំនួនប្រហែលនឹងចំនួនក្នុងឆ្នាំ ២០១៤ គឺមានប្រមាណជា ១២០០ ទៅ ១៥០០ នាក់នៅក្នុងរាជធានីភ្នំពេញ ដែលគ្មានទំនាក់ទំនងគ្រួសារ ហើយកុមារប្រមាណជាពី ១៥ ០០០ ទៅ ២០ ០០០នាក់ បានធ្វើការងារនៅតាមចិញ្ចើមផ្លូវ ប៉ុន្តែ បានត្រឡប់ទៅផ្ទះវិញនៅពេលយប់។ កុមារប្រមាណជា ២០០ ទៅ ៤០០ នាក់បានរស់នៅជាមួយគ្រួសាររបស់ខ្លួននៅតាមចិញ្ចើមផ្លូវនៃរាជធានីភ្នំពេញ។

ការអង្កេតមួយរបស់រដ្ឋាភិបាល នៅឆ្នាំ ២០១៤ បានរកឃើញថាចំនួន ៧០% នៃកុមារកំព្រាចំនួន ១២ ០០០ នាក់ ដែលរស់នៅតាមមជ្ឈមណ្ឌលរបស់រដ្ឋ និងឯកជន មានឪពុកម្តាយ ឬបងប្អូន។ ចំនួនមជ្ឈមណ្ឌលកុមារកំព្រានៅក្នុងប្រទេសមានកំណើនពី ១៥៥ នៅឆ្នាំ ២០០៥ ដល់២២៥ នៅឆ្នាំ ២០១៤ ដែលក្នុងចំនួននេះ មានតែ ២៣ ទេដែលគ្រប់គ្រងដោយរដ្ឋ។ អង្គការ NGO និងអ្នកសង្កេតការណ៍ដទៃទៀតបានចោទថា មជ្ឈមណ្ឌលកុមារកំព្រាឯកជនជាច្រើនគ្មានការគ្រប់គ្រងល្អទេ ហើយមានកុមារអត់កំព្រាច្រើនដើម្បីទាក់ទាញអំណោយពីជនបរទេស។

ការចាប់ជំរិតកុមារឆ្លងដែន៖ ប្រទេសកម្ពុជាមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជំរិតកុមារឆ្លងដែនឡើយ។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីពីការចាប់កុមារឆ្លងដែន តាម travel.state.gov/content/childabduction/en/legal/compliance.html ។

## ការប្រឆាំងនឹងសាសនាជ្វីស (Anti-Semitism)

មានសហគមន៍អនិកជនកាន់សាសនាជ្វីសតូចមួយនៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពីទង្វើប្រឆាំងនឹងសាសនានេះឡើយ។

## ការជួញដូរមនុស្ស

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gov/j/tip/rls/tiprpt/។

## ជនពិការ

ច្បាប់ហាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ។ នៅក្នុងច្បាប់នេះ និយមន័យជនពិការរួមមានទាំងជនដែលមានជំងឺសតិស្មារតី និងជនពិការប្រាជ្ញាផងដែរ ហើយច្បាប់នេះក៏តម្រូវផងដែរថា អាគារសាធារណៈ និងទីតាំងផ្តល់សេវារដ្ឋាភិបាល រួមទាំងគ្រឹះស្ថានអប់រំផងដែរ ត្រូវមានមធ្យោបាយដែលអាចឱ្យជនពិការចេញចូលបាន។ ច្បាប់នេះមិននិយាយពីមធ្យោបាយចេញចូល ឬឡើងចុះពេលធ្វើដំណើរតាមយន្តហោះ ឬធ្វើដំណើរតាមមធ្យោបាយផ្សេងឡើយ។ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវរួមលើការការពារសិទ្ធិជនពិការ ថ្វីបើច្បាប់នេះកំណត់ភារកិច្ចជាក់លាក់សំរាប់បណ្តាក្រសួងផ្សេងទៀតដែរ ដូចជា ក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងការពារជាតិ។ រដ្ឋាភិបាលបានស្នើឱ្យបណ្តាញទូរទស្សន៍ទាំងអស់ប្រើប្រាស់ការបកប្រែភាសាសញ្ញាក្នុងកម្មវិធីទាំងអស់របស់ខ្លួន។ គិតត្រឹមខែកញ្ញា មានស្ថានីយទូរទស្សន៍ធំជាងគេមួយមានការបកប្រែភាសាសញ្ញា។ ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តអនុក្រឹត្យចំនួន ៤ ដែលគាំទ្រច្បាប់នេះ។

កម្មវិធីដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលនានា បានធ្វើការកែលម្អគួរឱ្យកត់សម្គាល់ចំពោះការប្រព្រឹត្ត និងការស្មារតីនីតិសម្បទាលើជនពិការ ប៉ុន្តែ ពួកគាត់បានប្រឈមនឹងការរើសអើងពីសង្គមយ៉ាងច្រើន ជាពិសេសលទ្ធភាពក្នុងការទទួលបានការងារជំនាញ។

កុមារពិការតិចតួចអាចចូលសាលារៀនធម្មតាបានដែរ។ កុមារដែលពិការខ្លាំង បានចូលរៀននៅសាលាដាច់ដោយឡែក ដែលឧបត្ថម្ភដោយអង្គការ NGO នៅភ្នំពេញ។ បើយោងតាមអង្គការ NGO មួយ ការសិក្សាសំរាប់កុមារដែលមានភាពពិការខ្លាំង គ្មាននៅក្រៅក្រុងភ្នំពេញទេ។

គ្មានការដាក់កំហិតផ្លូវច្បាប់លើសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមនៅក្នុងកិច្ចការស៊ីវិលឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានខិតខំប្រឹងប្រែងសហការណាមួយ ដើម្បីជួយពួកគាត់ឱ្យមានការចូលរួមក្នុងការងារពលរដ្ឋជាធម្មតាឡើយ។

## សញ្ជាតិ/ពូជសាសន៍/ជនជាតិដើមភាគតិច

ច្បាប់ស្តីពីសញ្ជាតិមិនមានចែងច្បាស់លាស់អំពីសិទ្ធិរបស់ជនជាតិដើមភាគតិចឡើយ។ ការការពារតាមរដ្ឋធម្មនុញ្ញនិយាយតែពី “ប្រជាជនខ្មែរ” ប៉ុណ្ណោះ។ អាណិកជនចិន និងវៀតណាមគឺជាជនជាតិភាគតិចភាគច្រើនជាងគេ។ ជនជាតិចិនត្រូវបានទទួលយកនៅក្នុងសង្គម ប៉ុន្តែ មានការបន្តស្អប់ខ្ពើមចំពោះជនជាតិវៀតណាម ដែលត្រូវបានគេមើលឃើញថា ជាការគំរាមកំហែងចំពោះប្រទេសជាតិ និងវប្បធម៌។ ក្រុមមួយចំនួនរួមទាំងក្រុមអ្នកនយោបាយផងក្នុងបក្សប្រឆាំងផង បានបន្តនិយាយប្រឆាំងនឹងជនជាតិវៀតណាមយ៉ាងខ្លាំងក្លា។ ក្រុមទាំងនេះបានស្តីបន្ទោសថា មានការគ្រប់គ្រងផ្នែកនយោបាយពីប្រទេសវៀតណាមលើគណបក្សប្រជាជនកម្ពុជា បញ្ហាទន្ទ្រាននៅតាមតំបន់ព្រំដែន និងបញ្ហាជាច្រើនផ្សេងទៀត ដែលក្រុមទាំងនេះបានដាក់កំហុសទៅលើជនជាតិវៀតណាម យ៉ាងហោចណាស់ក៏ក្នុងចំណែកខ្លះដែរ។

## ជនជាតិដើមភាគតិច

ជាការជួយដល់ការខិតខំប្រឹងប្រែងរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងកិច្ចការពារទឹកដីដូនតា និងធនធានធម្មជាតិរបស់ខ្លួន ក្រសួងដែនដីបានចេញប័ណ្ណកម្មសិទ្ធិដីរួមទៅអោយសហគមន៍ជនជាតិដើមចំនួន

១១ សហគមន៍ ដែលមានគ្រួសារចំនួន ៧៥២ ហើយរស់នៅដីទំហំ ២២ ៣៧៨ acre។ អង្គការមិនមែនរដ្ឋាភិបាលបានរិះគន់ដំណើរការអនុវត្តយឺតនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីហើយបានបន្តសុំអោយមានការផ្អាកការលក់ដី និងការផ្តល់សម្បទានដីដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិមានសកម្មភាពយ៉ាងសកម្មក្នុងការអប់រំសហគមន៍ជនជាតិដើមភាគតិចអំពីដំណើរការចុះបញ្ជីដី ព្រមទាំងផ្តល់ជាតំណាងផ្នែកច្បាប់ក្នុងវិវាទផងដែរ។

## អំពើហឹង្សា ការរើសអើង ព្រមទាំងអំពើហឹង្សាដោយហេតុផលផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

មិនមានច្បាប់ដែលដាក់ទោសព្រហ្មទណ្ឌលើការស្រឡាញ់ភេទដូចគ្នាឡើយ ហើយក៏មិនមានការរើសអើងជាផ្លូវការប្រឆាំងនឹងក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលដែលស្រឡាញ់ទាំងបុរស និងស្ត្រី និងអ្នកវះកាត់កែអវៈយវៈភេទ (LGBT) នោះទេ ទោះបីជានៅតែបន្តមានការរើសអើងពីសង្គមមួយចំនួន និងការនាំគ្នាស្អប់ ជាពិសេសនៅក្នុងតំបន់ជនបទក្តី។ រដ្ឋាភិបាលបានផ្តល់ម៉ោងផ្សាយសំរាប់កម្មវិធីទាក់ទងនឹងសិទ្ធិរបស់ក្រុម LGBTI ។

គ្មានរបាយការណ៍អំពីការរើសអើងពីសំណាក់រដ្ឋាភិបាល ផ្អែកលើលក្ខណៈនៃចំណង់ផ្លូវភេទ នៅក្នុងការងារ ភាពគ្មានសញ្ជាតិ ឬលទ្ធភាពទទួលបានការអប់រំ ឬការថែទាំសុខភាពឡើយ។ ប៉ុន្តែ ការស្រឡាញ់ភេទដូចគ្នា ជាទូទៅ ទទួលរងការខ្មាចអរអារ និងការសង្ស័យពីសំណាក់ប្រជាជនទូទៅ ហើយមានក្រុមគាំទ្រតិចតួចប៉ុណ្ណោះដែលអាចរាយការណ៍ប្រាប់ពីករណីរើសអើង ។ ការរើសអើងក្រៅផ្លូវការប្រឆាំងនឹងក្រុម LGBT នៅតែមាន។ បើយោងតាមរបាយការណ៍ឆ្នាំ ២០១៥ មួយស្តីពីការរើសអើងប្រឆាំងនឹងក្រុម LGBTI នៅតាមសាលា ដែលផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ៦២,៧% នៃមនុស្សមកពីក្រុម LGBTI បាននិយាយថាបានរងការសំឡុត ដោយមាន ៩៣,៦% នៃពួកគេនិយាយថា វាជាការឆ្លើយតបនឹងលក្ខណៈនៃចំណង់ផ្លូវភេទរបស់គេ ឬអត្តសញ្ញាណយេនឌ័ររបស់គេ។ ជិត ១៧% នៃអ្នកដែលត្រូវបានសាកសួរ បាននិយាយថា គ្រូរបស់គេបានសំឡុតពួកគេ។

អង្គការក្នុងស្រុកមួយដែលធ្វើការលើសិទ្ធិរបស់ក្រុម LGBTI បានរាយការណ៍ពីករណីជាង ១០០នៃហឹង្សា ឬការរំលោភបំពានទៅលើមនុស្សក្នុងក្រុម LGBTI ដោយរួមទាំងអំពើហឹង្សាក្នុងគ្រួសារដែលប្រព្រឹត្ត

ដោយសមាជិកគ្រួសារ។ តែការមាក់ងាយ ឬការគំរាមកំហែងអាចជាកត្តាមួយក្នុងការរារាំងមិនអោយមានការប្រាប់ពីករណីបែបនេះ។

## ការមាក់ងាយពីសង្គមទាក់ទងនឹងមេរោគ និងជំងឺអេដស៍

ការសិក្សាផ្នែកវាយតំលៃពីសុខភាពរបស់វិទ្យាស្ថានមួយនៃសាកលវិទ្យាល័យ Washington បង្ហាញថា ចំនួនអ្នកមានមេរោគអេដស៍នៅកម្ពុជា ក្នុងឆ្នាំ ២០១៥ គឺប្រហែល ៨២ ៩៧០ នាក់ ដែលការកើនឡើងចំនួន ៦,៦% លើឆ្នាំ ២០១៤។ ការអង្កេតផ្នែកសុខភាពនិងប្រជាសាស្ត្រ ឆ្នាំ ២០១០ បានកត់សំគាល់ឃើញថា ២១% នៃស្ត្រី និង ១៨% នៃបុរសបាននិយាយថាគេមានឥរិយាបទរើសអើងទៅលើអ្នកជំងឺអេដស៍ ឬអ្នកមានផ្ទុកមេរោគអេដស៍។ បន្ទាប់ពីមានឧប្បត្តិហេតុកាលពីឆ្នាំ ២០១៤ ដែលក្នុងនោះ គ្រូពេទ្យគ្មានច្បាប់អនុញ្ញាតម្នាក់បានធ្វើអោយឆ្លងមេរោគអេដស៍ដោយអចេតនាដល់អ្នកភូមិប្រមាណ ២៩០ នាក់ អ្នកភូមិបាននិយាយពីការមាក់ងាយជាទូទៅពីអ្នកភូមិដទៃទៀត ដោយមានអ្នកខ្លះមិនទាក់ទងជាមួយជនរងគ្រោះតែម្តង។

## ផ្នែកទី ៧៖ សិទ្ធិកម្មករ និយោជិត

### ក. **សេរីភាពចូលរួម និងសិទ្ធិចរចាអនុសញ្ញារួម** (Freedom of Association and the Right to Collective Bargaining)

ច្បាប់ការពារសិទ្ធិរបស់អ្នកធ្វើការក្នុងវិស័យឯកជនក្នុងការបង្កើតនិងចូលរួមក្នុងសហជីព តាមការជ្រើសរើសរបស់គេដោយគ្មានការអនុញ្ញាតជាមុន សិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម។ រដ្ឋសភាជាតិបានអនុម័តច្បាប់ថ្មីស្តីពីសហជីព (TUL) នៅថ្ងៃទី ៤ មេសា។ មុនពេលចូលជាធរមាន ច្បាប់ TUL ទាមទារការផ្សព្វផ្សាយបទបញ្ញាសំរាប់អនុវត្តចំនួន ៩ ចំណុច ដែលចាំបាច់សំរាប់បកស្រាយច្បាប់ TUL។ ៤ ចំណុចត្រូវបានចេញ ដោយគិតមកត្រឹមខែវិច្ឆិកា។ ច្បាប់ TUL ក៏អំពាវនាវផងដែរអោយមានការអនុវត្តច្បាប់ស្តីពីការបង្កើតតុលាការការងារ។

ច្បាប់ TUL ក៏ដាក់កំរិតព្រំដែនថ្មីផងដែរលើសិទ្ធិក្នុងការធ្វើកូដកម្ម សំរួលដល់អន្តរាគមរបស់រដ្ឋាភិបាលនៅក្នុងកិច្ចការផ្ទៃក្នុងរបស់សហជីព មិនអោយកម្មករក្នុងប្រភេទក្រុមខ្លះចូលរួមក្នុងសហជីព អនុញ្ញាតអោយភាគីទីបីស្វែងរកការរំលាយសហជីព ដោយទន្ទឹមនឹងនោះ ដាក់ពិន័យតិចតួចទៅលើនិយោជក ចំពោះការ

ប្រព្រឹត្តមិនត្រឹមត្រូវជាមួយកម្មករ។ ច្បាប់នេះតំរូវអោយសហជីពបង្ហាញលក្ខខន្តិកៈ បញ្ជីឈ្មោះបុគ្គលិក និង សេចក្តីលំអិតជាមួយធនាគារ ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ច្បាប់ TUL ហាមមិនអោយ សហជីពដែលមិនទាន់ចុះបញ្ជីការ ធ្វើសកម្មភាព។ អង្គការ ILO បានផ្តល់ហើយរដ្ឋាភិបាលបានទទួល នូវ "បេសកកម្មទាក់ទងដោយផ្ទាល់" ដែលគេរំពឹងថា នឹងមានមកនៅត្រីមាសទី១ នៃឆ្នាំ ២០១៧ សំរាប់ផ្តល់ការ ណែនាំលើការគោរពតាមបទដ្ឋានអន្តរជាតិ។

មន្ត្រីរាជការ គ្រូបង្រៀន អ្នកធ្វើការក្នុងសហគ្រាសរដ្ឋ និងអ្នកធ្វើការនៅក្នុងផ្នែកធនាគារ ការថែទាំ សុខភាព និងវិស័យឯកជនអាចបង្កើតបានតែសមាគមទេ នៅក្រោមច្បាប់ស្តីពីអង្គការ មិនមែនសហជីពទេ។ អង្គការ ILO បន្តសុំអោយរដ្ឋាភិបាលធានាសិទ្ធិរបស់និយោជិតសាធារណៈ ក្នុងការចូលរួមក្នុងក្រុម សមាគម និងការចចារអនុសញ្ញារួម។ បុគ្គលិកនៅក្នុងឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងផ្លូវទឹកមានសេរីភាព ក្នុងការបង្កើតសហជីព ប៉ុន្តែគ្មានសិទ្ធិទទួលបានអត្ថប្រយោជន៍របបធានាផ្នែកសង្គម និងប្រាក់សោធននិវត្តន៍ ឡើយ ហើយទទួលការលើកលែងពីការកំហិតម៉ោងការងារដែលមានចែងនៅក្នុងច្បាប់។

បទប្បញ្ញត្តិស្តីពីការចរចាអនុសញ្ញារួមទាមទារអោយសហជីពតែមួយនៅក្នុងសហគ្រាសមួយបង្ហាញ "ឋានៈជាតំណាងច្រើនបំផុត" (MRS) គឺមានន័យថា សហជីពតំណាងអោយចំនួននិយោជិតច្រើនបំផុតនៅ ក្នុងក្រុមចរចា ឬយ៉ាងហោចណាស់និយោជិតចំនួនយ៉ាងតិច ៣០% នៅក្នុងសហគ្រាស។ នៅពេលដែល សហជីពបានទទួល MRS គ្មានសហជីពណាផ្សេងទៀតអាចធ្វើជាតំណាងអោយកម្មករនៅក្នុងជំលោះរួម បានទេ។ តែTUL អនុញ្ញាតអោយភាគីទីបីធ្វើការជំទាស់ចំពោះការផ្តល់អោយសហជីពនូវភាពជាតំណាង ច្រើនបំផុត ហើយការជំទាស់នេះអាចយកធ្វើជាហេតុផលសំរាប់អោយរដ្ឋាភិបាលបដិសេធឋានៈនេះ។ អង្គការ ILO បានកត់សំគាល់ឃើញថា ការអនុញ្ញាតអោយមានការជំទាស់ពីភាគីទី៣ផ្ទុយទៅនឹងសិទ្ធិស្តីពី ការងារដែលមានការយល់ព្រមជាអន្តរជាតិ ទាក់ទងនឹងសេរីភាពនៃការចងក្រងជាក្រុមជាសមាគម និងការ ចរចាអនុសញ្ញារួម។ បទប្បញ្ញត្តិទាំងនេះក៏ចងភ្ជាប់កាតព្វកិច្ចគូភាគីឱ្យឯកភាពនឹងដំណើរការចរចាដែលមាន លំដាប់លំដោយត្រឹមត្រូវ និងផ្តល់សំណើ និងជាសំណើតបដែលសមស្រប និងសមហេតុផល។ និយោជក ត្រូវតែផ្តល់ទីតាំងសំរាប់ការធ្វើសកម្មភាពរបស់សហជីព និងព័ត៌មានទាំងអស់ទាក់ទងនឹងដំណើរការចរចា តាមការស្នើសុំរបស់សហជីព។

ច្បាប់ចែងថា កម្មករអាចធ្វើកូដកម្មបាន តែត្រូវបំពេញតាមការទាមទារមួយចំនួនសិន ដូចជាការចុះ បញ្ជីសហជីពបានត្រឹមត្រូវ ការបរាជ័យនៃវិធីផ្សេងទៀតក្នុងការដោះស្រាយការវិវាទ (ដូចជាការចរចា ការ

សំរបសំរួលដោយអាជ្ញាកណ្តាល) រយៈពេលយ៉ាងតិច ៦០ ថ្ងៃបន្ទាប់ពីមានលេចឡើងនូវជំលោះ ការបោះឆ្នោតដោយសំងាត់របស់សមាជិកសហជីព និងការជំរាបប្រាប់មុនចំនួន ៧ ថ្ងៃ ទៅនិយោជក និងក្រសួងការងារ។ TUL ចែងថា ការសំរេចចិត្តរបស់សហជីពក្នុងការធ្វើកូដកម្មត្រូវមានការយល់ព្រមរបស់សំលេងភាគច្រើនដាច់ខាតរបស់សមាជិកសហជីព ដែលចូលរួមក្នុងការប្រជុំស្តីពីការធ្វើកូដកម្ម។ ការប្រជុំនេះត្រូវមានកូរ៉ុមនៃចំនួនភាគច្រើនដាច់ខាតនៃសមាជិកសហជីពសរុប។ បន្ទាប់ពីសហជីពបានបោះឆ្នោតសំរេចលើការធ្វើកូដកម្មហើយ តុលាការមានអំណាចចេញបញ្ជាប្រឆាំងនឹងការធ្វើកូដកម្ម ហើយតំរូវអោយមានការចាប់ផ្តើមឡើងវិញនូវការចរចាជាមួយនិយោជក។

ការពង្រឹងដោយរដ្ឋលើការអនុវត្តសិទ្ធិបង្កើតក្រុម សមាគម សេរីភាពចាកផុតពីការរើសអើងប្រឆាំងនឹងសហជីព និងសិទ្ធិក្នុងការចរចាអនុសញ្ញារួមមានលក្ខណៈមិនស៊ីសង្វាក់ទេ។ ច្បាប់ចែងពីការដាក់ពិន័យចំនួនច្រើនបំផុត ៥ លានរៀល ចំពោះការរំលោភសិទ្ធិក្នុងការចងក្រងក្រុម សមាគម និងបញ្ញតិស្តីពីការចរចាអនុសញ្ញារួម។ យ៉ាងណាក្តី ការរើសអើងប្រឆាំងសហជីព ការសំឡុត និងការសងសឹកដោយនិយោជក ឬសមាជិកសហជីពដែលគាំទ្ររដ្ឋាភិបាល ជាទូទៅមិនទទួលបាននូវការដាក់ទណ្ឌកម្មទេ។ ចេតនារបស់រដ្ឋាភិបាលក្នុងការពង្រឹងការអនុវត្តសិទ្ធិទាំងនេះត្រូវបន្ទុចបង្អាក់ដោយសារទំនាក់ទំនងជិតស្និទ្ធនៅក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និយោជក និងមេដឹកនាំសហជីព ពិសេសអ្នកដឹកនាំសហជីពដែលគាំទ្ររដ្ឋាភិបាល។ ទំនាក់ទំនងទាំងនេះបង្អាក់មិនអោយមេដឹកនាំសហជីពរាយការណ៍ពីករណីរើសអើង ហើយរាំងស្ទះដល់ដំណើរការបំពេញការងាររដោយឯករាជ្យរបស់សហជីព ដោយសហជីពភាគច្រើននៅក្នុងប្រទេសមានទំនាក់ទំនងជាមួយគណបក្សដឹកនាំប្រទេស ហើយមានតែចំនួនតិចតួចទេដែលមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង ឬធ្វើការដោយឯករាជ្យ។ រដ្ឋាភិបាលមិនបានផ្តល់ធនធានគ្រប់គ្រាន់ដល់ផ្នែកអនុវត្តច្បាប់ទេ ពិសេសការផ្តល់ការ បណ្តុះបណ្តាល និងធនធាន ដើម្បីធានាអោយផ្នែកអធិការកិច្ចការងារមានដំណើរការទៅល្អ។

ករណីជាច្រើនដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកដោះស្រាយ ស្ថិតនៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងសំលៀកបំពាក់។ ភាគច្រើននៃការសំរេចរបស់ក្រុមប្រឹក្សានេះគ្មានភ្ជាប់កាតព្វកិច្ចទេ បន្ទាប់ពីផុតសុពលភាព នៅឆ្នាំ ២០១៤ នៃអនុស្សារណៈនៃការយោគយល់ ឆ្នាំ ២០១២ រវាងក្រុមឧស្សាហកម្មនៃសមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) និងសហព័ន្ធសហជីពចំនួន ៨ ដែលកំណត់អោយរោងចក្រនិងកម្មករទទួលយកការសំរេចរបស់ក្រុមប្រឹក្សានេះ។ តាំងពីឆ្នាំ ២០១៤ មក នៃអនុស្សារណៈនេះបានជួបគ្នាចំនួន ៣ ដង ដើម្បីពិភាក្សាជាមួយគ្នា ទាក់ទងនឹងបញ្ហាច្បាប់ការងារ។ សហជីពខ្លះស្នើអោយរដ្ឋាភិបាល

ពង្រឹកតួនាទីរបស់ក្រុមប្រឹក្សា ដោយបញ្ចូលការវិវាទទាក់ទងនឹងប្រយោជន៍បុគ្គល និងប្រយោជន៍សមូហភាព និងធ្វើអោយការសំរេចរបស់ខ្លួនមានការភ្ជាប់កាតព្វកិច្ចប្រកបដោយការឯកភាពគ្នា។

និតិវិធីក្នុងការដោះស្រាយវិវាទជាផ្លូវការរបស់ក្រសួងការងារ ដំបូងគឺគេចង់អោយមានសំរបសំរួលគ្នាសិន ដោយបន្ទាប់មក ទើបមានអាជ្ញាកណ្តាលចូលដោះស្រាយ។ តែតាមភាពជាក់ស្តែង ដំណោះស្រាយចំពោះវិវាទរួមមានលក្ខណៈឯកភាពគ្នាទេ។ ការបង្កើតគណកម្មាធិការដោះស្រាយកូដកម្ម និងបាតុកម្ម ដើម្បីធ្វើការងារលើកជំលោះទាក់ទងនឹងកូដកម្មបាននាំអោយមានភាពមិនច្បាស់លាស់ផ្នែកយុត្តាធិការជាមួយនឹងនាយកដ្ឋានដោះស្រាយជំលោះការងារ។ ក្នុងករណីខ្លះ ក្រសួងមិនព្រមធ្វើការទាក់ទងនឹងនិតិវិធីដោះស្រាយការវិវាទតាមផ្លូវច្បាប់តែម្តង ដោយបែរជាផ្ញើលិខិតទៅតុលាការសុំអន្តរាគមទៅវិញ។ នៅក្នុងករណីខ្លះទៀតក្រសួងបញ្ជូនករណីទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានលិខិតស្នាមចាំបាច់ ដែលជាការធ្វើអោយការវិវាទនៅតែដោះស្រាយមិនចេញ។

វិវាទបុគ្គលអាចយកមកដោះស្រាយនៅចំពោះមុខតុលាការ តែប្រព័ន្ធតុលាការមិនមានភាពអព្យាក្រិតនិងតម្លាភាពទេ។ គ្មានតុលាការឯកទេសសំរាប់កាត់ក្តីជំលោះក្នុងការងារទេ តែដូចដែលត្រូវបានកំណត់ដោយច្បាប់ TUL ក្រសួងការងារបានសន្យាថានឹងបង្កើតតុលាការនេះ (ត្រូវបានហៅថា តុលាការការងារ) នៅក្រោមសមត្ថកិច្ចរបស់ខ្លួន នៅត្រឹមឆ្នាំ ២០១៧។ នៅតែមានការជជែកគ្នាជាបន្តលើសមាសភាព និងមុខងារនៃតុលាការនេះ ហើយមកដល់ថ្ងៃទី ១៣ ធ្នូ ក្រសួងមិនទាន់បានបំភ្លឺពីលក្ខណៈនៃទំនាក់ទំនងរបស់ខ្លួនទៅនឹងក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

តាមសេចក្តីរាយការណ៍មក កម្មករជួបឧបសគ្គក្នុងការអនុវត្តសិទ្ធិរបស់គេក្នុងការបង្កើតក្រុម ដោយសារនិយោជកខ្លះមិនព្រមចុះហត្ថលេខាលើសំបុត្រជូនដំណឹង ដែលទទួលស្គាល់សហជីពជាផ្លូវការ (ចំពោះរឿងនេះ រដ្ឋាភិបាលមិនបានផ្តល់ការដោះស្រាយជាផ្លូវការទេ) ឬបន្តកុងត្រាការងារសំរាប់រយៈពេលខ្លីដល់កម្មករដែលចូលរួមក្នុងសហជីព។ ក្រៅពីនេះទៀត កម្មករនៅក្នុងវិស័យកាត់ដេរនៅកម្ពុជាត្រូវបានជួលដូចជាអ្នកម៉ៅការបន្ត ដែលជាការធ្វើអោយការចូល ឬបង្កើតសហជីពមានការពិបាក។

ការរៀបចំបង្កើតសហជីព ឬសមាគមនៅក្នុងចំណោមបុគ្គលិកក្នុងវិស័យសាធារណៈបានប្រឈមមុខនឹងឧបសគ្គជាច្រើន។ឧទាហរណ៍ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានចុះបញ្ជីការជា “សមាគម” ដោយសារការហាមឃាត់ការបង្កើតសហជីពក្នុងវិស័យសាធារណៈ ហើយ រដ្ឋាភិបាលបានបដិសេធសំណើសុំការ

អនុញ្ញាតដង្ហែរក្បួន និងធ្វើការតវ៉ា ។ សមាគមវិស័យសាធារណៈមួយផ្សេងទៀតគឺ សមាគមមន្រ្តីរាជការឯករាជ្យកម្ពុជា បានលើកឡើងថា ការភ័យខ្លាចការបៀតបៀន ការរើសអើង ឬបញ្ចុះតំណែងជាកត្តាដែលរារាំងគេមិនឱ្យចូលរួមក្នុងសមាគម។

មានរបាយការណ៍គួរអោយជឿទុកចិត្តថា មានការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសហជីពពីសំណាក់និយោជក រួមទាំងការបណ្តេញមេដឹកនាំសហជីពក្នុងរោងចក្រកាត់ដេរ និងសហគ្រាសផ្សេងទៀតចេញពីការងារផងដែរ។ កម្មវិធីមួយដែលមានឈ្មោះថា រោងចក្រល្អនៅកម្ពុជា (Better Factories Cambodia ឬ BFC) ដែលជាកម្មវិធីរបស់អង្គការ ILO និងមូលនិធិ IMF ដែលតាមដានរោងចក្រនាំចេញទាំងអស់ បានកត់សំគាល់នៅក្នុងរបាយការណ៍របស់ខ្លួន ពីថ្ងៃខែឧសភា ឆ្នាំ ២០១៥ ដល់ខែមេសា ថា ៦,៨% នៃរោងចក្របានកាត់បន្ថយលុយបង់មកសហជីព ដោយគ្មានការយល់ព្រមដោយសេរីរបស់កម្មករ ឬបានរារាំងកម្មករមិនអោយបង្កើតឬចូលរួមក្នុងសហជីពដោយគ្មានការគំរាមកំហែងផ្តាច់កុងត្រាឡើយ។ កម្មវិធី BFC ក៏បានរកឃើញផងដែរថា ២,៩% នៃរោងចក្រដែលត្រូវបានពិនិត្យ បានជ្រៀតជ្រែកក្នុងចំណោមកម្មករ ឬក្នុងសហជីព នៅពេលគេបង្កើតបទបញ្ជារបស់គេ ធ្វើការបោះឆ្នោត ឬរៀបចំការគ្រប់គ្រងរបស់គេ ហើយ ២,៩% នៃរោងចក្របានខិតខំច្រើន ក្នុងការធ្វើអោយសហជីពស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន។ ការងារគ្រប ដណ្តាប់របស់ BFC មានត្រឹមតែនៅក្នុងវិស័យនាំចេញទេ ហើយកំរិតនៃការយាយីទៅលើសហជីពនៅក្នុងឧស្សាហកម្មទាំងមូលប្រហែលជាមានច្រើនជាងនេះ ដូចជាការបណ្តេញចេញ ពិសេសចំពោះមេដឹកនាំសហជីព ការរំលោភលើកុងត្រារយៈពេលខ្លី និងការយាយីលើរាងកាយ។ ក្នុងពេលថ្មីៗនេះ អង្គការ Human Rights Watch បាននិយាយថា កម្មករកាត់ដេរដែលធ្វើការនៅតាមរោងចក្រដែលមិនត្រូវបានចុះបញ្ជីជាផ្លូវការ ដែលច្រើនតែជាអ្នកម៉ៅការបន្តពីរោងចក្រនាំចេញធំៗ ងាយរងនឹងការរំលោភក្នុងការងារ ទាក់ទងនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ អង្គការនេះនិយាយថា “បញ្ហាអាក្រក់ៗខ្លាំងខ្លះដែលយើងបានចងក្រងជាឯកសារ មានឡើងនៅតាមរោងចក្រម៉ៅការបន្ត ហើយវាគួរតែមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើការពង្រឹកអធិការកិច្ចនៅតាមរោងចក្រទាំងនោះ”។

គ្មាននរណាម្នាក់ត្រូវបានចាប់អោយទទួលខុសត្រូវចំពោះហឹង្សាដែលប្រព្រឹត្តទៅលើអ្នកតវ៉ា នៅឆ្នាំ ២០១៤ ដែលធ្វើអោយមានស្លាប់ ៥ នាក់ និងរបួសជាច្រើននាក់ទៀត។ មនុស្សជាច្រើននៅក្នុងសង្គមស៊ីវិលមិនបានគិតថា គណកម្មាធិការរបស់រដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងដើម្បីស៊ើបអង្កេតការវាយប្រហារទាំងនេះ មានលក្ខណៈគួរអោយយកជាការបានណាស់។ អង្គការ ILO ស្នើអោយរដ្ឋាភិបាលបញ្ចេញលទ្ធផលរកឃើញ និងការសន្និដ្ឋានរបស់ខ្លួន អោយសាធារណជនដឹង។

បន្ទាប់ពីមានការតវ៉ាដោយហឹង្សានៅឆ្នាំ ២០១៣ សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) បានប្តឹងទៅតុលាការក្រុងភ្នំពេញប្រឆាំងនឹងសហព័ន្ធសហជីពចំនួន ៦ ដោយចោទថា សហព័ន្ធទាំងនោះបានញុះញង់អោយកម្មករធ្វើការតវ៉ាដោយហឹង្សា ដែលនាំអោយប៉ះពាល់និងខូចខាតដល់ផលិតកម្ម និងសំភារៈរោងចក្រ។ តុលាការក្រុងភ្នំពេញបានដាក់អោយមេដឹកនាំសហជីពទាំងនោះអោយស្ថិតនៅក្រោមការតាមមើលរបស់តុលាការ រារាំងមិនអោយគេចូលរួម ឬរៀបចំការតវ៉ាណាមួយ អោយគេទៅនៅកន្លែងផ្សេងដោយគ្មានការប្រាប់មុន ហើយបញ្ជាអោយគេបង្ហាញខ្លួននៅស្នាក់ការអាជ្ញាធរមូលដ្ឋាន រាល់ខែ។ ដោយគិតមកត្រឹមខែធ្នូ ការបញ្ជានោះនៅតែមានសុពលភាពនៅឡើយ។ ការចោទបទព្រហ្មទណ្ឌប្រឆាំងនឹងមេដឹកនាំសហជីពឯករាជ្យទាំង ៦ នៅមិនទាន់ត្រូវបានចាត់ការទៅលើនៅឡើយ។ មេដឹកនាំកម្មករបាននិយាយថា តុលាការដែលរងឥទ្ធិពលនយោបាយបានបន្តរក្សាករណីចោទនៅឡើយ ដើម្បីគំរាមកំហែងចលនាសហជីពឯករាជ្យ។

មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា កម្មករ-និយោជិតត្រូវបានបណ្តេញចេញពីការងារដោយសារ ហេតុផលមិនត្រឹមត្រូវ បន្ទាប់ពីពួកគេបានរៀបចំ ឬចូលរួមនៅក្នុងកូដកម្ម។ ទោះបីជាកូដកម្មភាគច្រើនមិនស្របច្បាប់ក៏ដោយ តែការចូលរួមនៅក្នុងកូដកម្មមិនស្របច្បាប់មិនមែនជាហេតុផលដែលអាចទទួលយកបានតាមផ្លូវច្បាប់សំរាប់ បណ្តេញកម្មករ-និយោជិតចេញពីការងារឡើយ។ នៅក្នុងករណីខ្លះ និយោជកបានដាក់សម្ពាធលើកូដករឱ្យទទួលយកសំណង និងឈប់ពីការងាររបស់ខ្លួន ដោយលើកហេតុផលថា កុងត្រារយៈពេលខ្លីរបស់គេបានដាច់។

ខាងចលនាសហជីពជាទូទៅមិនជឿថា ការដោះស្រាយចំពោះការបណ្តេញចេញមានប្រសិទ្ធភាពនោះទេ។ ឧទាហរណ៍ ក្រសួងសង្គមកិច្ចអាចចេញបញ្ជាអោយទទួលយកកម្មករវិញ តែរឿងនេះច្រើនតែជំរុញអោយថៅកែគាបសង្កត់អោយកម្មករលាលែងជាថ្នូនឹងទូទាត់ប្រាក់។ ពេលខ្លះ ថៅកែមិនបានគោរពតាមដីកាតុលាការអោយទទួលយកកម្មករអោយធ្វើការវិញទេ។ ឧទាហរណ៍ នៅខែកក្កដា ថៅកែក្រុមហ៊ុនឡានក្រុងកាពីតូលបានបណ្តេញមេដឹកនាំសហជីព ៥ នាក់ ប៉ុន្មានថ្ងៃបន្ទាប់ពីគេបានសុំការយល់ព្រមពីក្រសួង ដើម្បីបង្កើតសហជីពមួយ។ ពួកគេមិនត្រូវបានអោយចូលធ្វើការវិញទេ ទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាអោយថៅកែទទួលពួកគេអោយចូលធ្វើការវិញ កាលពីថ្ងៃទី៣០ កក្កដា។ គិតមកត្រឹមខែសីហា ឆ្នាំ ២០១៥ សមាជិកនិងមេដឹកនាំសហជីពចំនួន ៤៥ នាក់ នៅក្នុងក្រុមហ៊ុនត្រូវបានបណ្តេញចេញដោយសារសកម្មភាពសហជីពរបស់គេ។ នៅខែកុម្ភៈ ជនល្មើសដែលស្លៀកពាក់ខ្មៅ ហើយពាក់មួកជិះម៉ូតូបានវាយតប់យ៉ាងខ្លាំងទៅលើនិយោជិតនៃក្រុមហ៊ុនឡានក្រុងនោះ ដែលកំពុងធ្វើការតវ៉ា។

## ខ. ការហាមឃាត់មិនអោយមានការងារដោយបង្ខំ ឬការងារបែបកាតព្វកិច្ច

ច្បាប់ហាមប្រាមមិនអោយមានការងារដោយបង្ខំ ឬជាកាតព្វកិច្ចគ្រប់ទំរង់ទាំងអស់។

រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះអោយមានប្រសិទ្ធភាព នៅគ្រប់ករណីទាំងអស់ទេ។ ពិសេស មន្ត្រីរដ្ឋាភិបាលបាននិយាយពីការពិបាកក្នុងការបញ្ជាក់ស្ថានភាពការងារ និងប្រាក់ខែ ក្នុងផ្នែកនេសាទ កសិកម្ម សំណង់ និងការងារនៅ ក្នុងផ្ទះ ដោយសារលក្ខណៈមិនផ្លូវការនៃការងារទាំងនេះ។ ទណ្ឌកម្មក្រោមច្បាប់ចំពោះពលកម្មដោយបង្ខំគឺខ្លាំង ដោយរួមមានទាំងការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់។ តែគ្មានភស្តុតាងនៃការខិតខំរបស់រដ្ឋាភិបាលក្នុងការយកចិត្តទុកដាក់ទៅលើបញ្ហានៃការបង្ខំអោយធ្វើពលកម្មនៅតាមផ្ទះ។ លើសពីនេះទៀត មានភស្តុតាងខ្លះថា អាជ្ញាធរអនុវត្តច្បាប់ក្នុងមូលដ្ឋានត្រូវបានថៅកែប្រើដើម្បីអោយកម្មករនៅជាប់បំណុលពលពលកម្ម ដូចជានៅកន្លែងធ្វើអិដ្ឋក្បឿង។ អង្គការលីកាដូបានលើកឡើងនូវករណីមួយចំនួននៃអន្តរាគមបែបនេះរបស់រដ្ឋ។ នៅក្នុងករណីមួយ អង្គការលីកាដូបានចូលអន្តរាគមជួសមុខអោយយុវជនម្នាក់ដែលបានចាកចេញពីរោងចក្រ ពីព្រោះថៅកែរោងចក្របានយកលុយដែលគ្រួសារគាត់រកបានទាំងអស់ ដើម្បីទូទាត់បំណុលរបស់គេ ដែលជាការធ្វើអោយពួកគេអស់លុយរលីងពីខ្លួន។ គាត់បានទៅរោងចក្រទី ២ ហើយសាកខ្ចីលុយគេ តែម្ចាស់រោងចក្រទី១បានអោយនគរបាលចាប់ឪពុកម្តាយរបស់បុរសនោះ ហើយបង្ខំអោយកូនប្រុសវិលត្រឡប់មកធ្វើការវិញ។ នៅក្នុងករណីទី ២ អង្គការលីកាដូបាននិយាយថា ស្ត្រីម្នាក់ខំធ្វើការដើម្បីដោះបំណុលចំនួន ១២ លានរៀល (៣០០០ ដុល្លាអាមេរិក) ដែលខ្ចីដោយកូនប្រសារប្រុសរបស់គាត់ តែគាត់ត្រូវទទួលរង ដោយសារកូនប្រសារប្រុសនោះបានរត់គេចចេញពីរោងចក្រ។ គាត់ចង់ប្តឹងនគរបាល នៅពេលដែលកូនប្រុសអាយុ ៧ ឆ្នាំរបស់គាត់បានរងរបួសដោយម៉ាស៊ីរោងចក្រ តែនគរបាលបានប្រាប់គាត់ថា បើគាត់ប្តឹង ម្ចាស់រោងចក្រនឹងប្តឹងតបវិញ ដើម្បីទារបំណុលរបស់កូនប្រសារប្រុសគាត់ ហើយគាត់ត្រូវចូលគុក។

ពលកម្មដោយបង្ខំកើតមាននៅតាមផ្ទះ និងនៅក្នុងវិស័យក្រៅផ្លូវការ ។ កុមារនៅក្នុងគ្រួសារក្រីក្រនៅតែប្រឈមនឹងហានិភ័យ ដោយសារគ្រួសារអ្នកមានទ្រព្យ ពេលខ្លះ ប្រើលេសមនុស្សធម៌ ដើម្បីជួលកុមារអោយបំរើការងារក្នុងផ្ទះ តែបែរជាធ្វើបាប និងកេងប្រវ័ញ្ចលើពួកគេទៅវិញ (សូមមើលផ្នែក ៧គ)។ មានការនិយាយផងដែរពីពលកម្មដោយបង្ខំនៅក្នុងផ្នែកនេសាទ កសិកម្ម សំណង់។

កម្មវិធី BFC បានរាយការណ៍មកថា រោងចក្រកាត់ដេរសំលៀកបំពាក់ និងវាយនភណ្ឌចំនួន ៦ មានករណីនៃការបង្ខំអោយមនុស្សធ្វើពលកម្ម។ ករណី ៥ ក្នុងចំណោមករណីទាំង ៦ នេះទាក់ទងនឹងការបង្ខំអោយធ្វើការថែមម៉ោង ដោយក្នុងនោះ កម្មករត្រូវបានតំរូវអោយសុំការយល់ព្រមជាលាយលក្ខណ៍អក្សរមេការបរទេស មុនពេលគេចាកចេញពីរោងចក្រ។ កម្មករបានត្អូញត្អែរថា គេខ្លាចការបញ្ឈប់ពីការងារ បើសិនជាគេមិនព្រមធ្វើការថែមម៉ោង។

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក តាមគេហទំព័រ [www.state.gov/j/tip/rls/tiprpt/](http://www.state.gov/j/tip/rls/tiprpt/)។

## គ. ការហាមឃាត់ចំពោះពលកម្មកុមារ និងអាយុធ្វើការងារអប្បបរិមា

ច្បាប់កំណត់ថា អាយុធ្វើការងារអប្បបរិមាគឺ ១៥ ឆ្នាំ ហើយសម្រាប់ការងារដែលមានគ្រោះថ្នាក់ អាយុអប្បបរិមានេះគឺ ១៨ ឆ្នាំ។ ច្បាប់អនុញ្ញាតឱ្យកុមារអាយុចន្លោះពី ១២ ទៅ ១៥ឆ្នាំ ធ្វើ “ការងារស្រាល” ដែលជាការងារមិនមានគ្រោះថ្នាក់ដល់សុខភាពរបស់កុមារទាំងនោះ ក៏ដូចជាមិនប៉ះពាល់ដល់ការសិក្សានៅសាលា។ ច្បាប់កំណត់ថា ម៉ោងការងាររបស់កុមារអាយុពី ១២ ទៅ ១៥ឆ្នាំ មិនអាចលើសពី ៤ ម៉ោងក្នុងមួយថ្ងៃឡើយ សម្រាប់ថ្ងៃសិក្សា និង ៧ ម៉ោងក្នុងមួយថ្ងៃ សម្រាប់ថ្ងៃឈប់សម្រាក ហើយហាមឃាត់ការធ្វើការនៅចន្លោះពីម៉ោង ៨:០០ យប់ ដល់ម៉ោង ៦:០០ព្រឹក។ រដ្ឋាភិបាលក៏ហាមឃាត់ការទទួលកុមារឱ្យបម្រើការងារនៅក្នុងវិស័យ ដែលមានហានិភ័យខ្ពស់ដល់សុវត្ថិភាព ឬហានិភ័យសុខភាពចំពោះអនីតិជន។ តែការការពារអាយុអប្បបរិមាគ្មានសំរាប់ការងារនៅតាមផ្ទះទេ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានការទទួលខុសត្រូវក្នុងការធ្វើអធិការកិច្ចលើពលកម្មកុមារ ទាំងក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ និងក្រៅផ្លូវការ ។ ប៉ុន្តែ អធិការការងាររបស់ក្រសួងនេះមិនបានធ្វើអធិការកិច្ចក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ ឬពង្រឹងការអនុវត្តច្បាប់នៅក្នុងឧស្សាហកម្មខុសច្បាប់ទេ ដូចជានៅតាម រោងចក្រកាត់ដេរដែលមិនចុះបញ្ជីការ និងបើកដំណើរការដោយមិនមានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម។ នៅក្នុងវិស័យផ្លូវការ អធិការការងារបានធ្វើការពិនិត្យជាប្រចាំចំពោះឧស្សាហកម្មមួយចំនួន ដូចជាវិស័យកាត់ដេរ (ដែលមានបញ្ហាពលកម្មកុមារតិចតួចប៉ុណ្ណោះ) ប៉ុន្តែនៅក្នុងឧស្សាហកម្មមួយចំនួនទៀតដែលអាចមានពលកម្មកុមារខ្ពស់បំផុត ការធ្វើអធិការកិច្ចការងារកើតឡើងតែក្នុងករណីដែលមានពាក្យបណ្តឹងប៉ុណ្ណោះ។ គិតមកដល់ឆ្នាំ ២០១៤ ដែលជាឆ្នាំចុងក្រោយដែលមាន

ទិន្នន័យនេះ មានអធិការការងារចំនួន ៥៨ នាក់ ដែលបានទទួលការបណ្តុះបណ្តាលអោយធ្វើអធិការកិច្ចលើពលកម្មកុមារ។ ក្រុមអធិការកិច្ចអន្តរមន្ទីរស្ថាប័នរបស់ក្រសួងការងារ ដែលរួមមានអធិការចំនួន ៨ នាក់ មកពីមន្ទីរស្ថាប័នចំនួន៨ ដែលរួមមានម្នាក់មកពីនាយកដ្ឋានពលកម្មកុមារ បានបន្តដំណើរការងារ។ មានតែអធិការដែលបានរៀនពីការធ្វើអធិការកិច្ចលើពលកម្មកុមារទេ ដែលបានធ្វើអធិការកិច្ច ដើម្បីរកមើលបទល្មើសពលកម្មកុមារ យ៉ាងសកម្ម។

នាយកដ្ឋានទទួលបន្ទុកពលកម្មកុមារបាននិយាយថា ដោយសារកង្វះថវិកា ខ្លួនអាចធ្វើអធិការកិច្ចតែនៅក្នុង និងនៅជុំវិញរាជធានីភ្នំពេញតែប៉ុណ្ណោះ។ ចំនួនអធិការនៅមិនគ្រប់គ្រាន់សំរាប់ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធឡើយ។ ច្បាប់ការងារចែងអំពីការដាក់ពិន័យចំនួនពី ៣១ ទៅ ៦០ ដង នៃប្រាក់ឈ្នួលប្រចាំខែ ចំពោះចុងចោទដែលត្រូវបានចោទប្រកាន់ពីបទរំលោភលើបទបញ្ញត្តិស្តីពីពលកម្មកុមារ។ ទណ្ឌកម្មបែបនេះគ្រប់គ្រាន់សំរាប់ធ្វើអោយគេមិនហ៊ានរំលោភ តែកម្រត្រូវបានគេអនុវត្តណាស់។

ពលកម្មកុមារមានច្រើនក្នុងផ្នែកកសិកម្ម ដែលរួមមានការផលិតស្ករអំពៅ សិប្បកម្មផលិតឥដ្ឋ ការដ្ឋានផលិតអំបិល សិប្បកម្មកែច្នៃបង្គារ វិស័យនេសាទ ការងារតាមផ្ទះ ផលិតកម្មកៅស៊ូ ការជួសជុលឡាន វាយណភណ្ឌ ការកាប់ឈើ ទីសត្តឃាត និងការផលិតស្រា ស្រាបៀ។ កុមារក៏មានធ្វើជាអ្នកសុំទាន អ្នកដើរលក់តាមផ្លូវ អ្នកខាត់ស្បែកជើង និងអ្នកដើររើសរបស់អេតចាយផងដែរ។ពលកម្មកុមារក៏ត្រូវបានគេរាយការណ៍ថា មាននៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ក៏ដូចជាវិស័យបដិសណ្ឋារកិច្ចផងដែរ។

កម្មវិធីរោងចក្រល្អនៅកម្ពុជា (BFC) បាននិយាយថា គិតមកដល់ដំណាច់ខែមេសា ខ្លួនបានរកឃើញករណីពលកម្មកុមារចំនួន ១៦ ករណី នៅតាមរោងចក្រចំនួន ៣៨១ ដែលរបាយការណ៍នេះបានសិក្សាទៅលើ។ ចំនួនករណីនេះមានការថយចុះ ដោយក្នុងរយៈពេលដូចគ្នានេះ ក្នុងឆ្នាំ ២០១៥ មាន ៣០ ករណី។ យ៉ាងណាក្តី កុមារខ្លះបានទទួលការងារដោយសារផ្តល់ឯកសារអត្តសញ្ញាណកម្មក្លែងក្លាយ។ កុមារទាំងនេះធ្វើការពេញវេន ហើយជាញឹកញាប់ ដោយប្រើម៉ាស៊ីនដែលមានគ្រោះថ្នាក់ផង។ អត្ថបទមួយក្នុងសារព័ត៌មាននៅក្នុងឆ្នាំ ២០១៥ បាននិយាយពីកុមារីអាយុ ១៤ ឆ្នាំម្នាក់ ដែលបានចោះរន្ធស្បែកជើងចំនួន ៣០០ ក្នុងមួយថ្ងៃ ហើយកម្មកររោងចក្រដែលមានអាយុពី ១៦ ឆ្នាំ ដល់ ១៧ ឆ្នាំ ត្រូវបានគេអោយធ្វើការរយៈពេល ១៥ ម៉ោង ហើយត្រូវបានបណ្តេញចេញពីការងារ បើគេមិនព្រមធ្វើការថែមម៉ោង លើសពីម្តងឬពីរដង។

សូមចូលមើល*របកគំហើញស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ* របស់ក្រសួងការងារសហរដ្ឋអាមេរិក នៅតាមគេហទំព័រ www.dol.gov/ilab/reports/child-labor/findings/ ។

## ឃ. ការរើសអើងទាក់ទងនឹងការងារ

ច្បាប់ហាមប្រាមការរើសអើងក្នុងការងារដោយផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា ពិការភាព មតិនយោបាយ កំណើត ប្រវត្តិដើមក្នុងសង្គម ឬសមាជិកភាពក្នុងសហជីពឡើយ។ មានច្បាប់ពីរដាច់ដោយឡែកពីគ្នាដែលហាមប្រាមយ៉ាងច្បាស់នូវការរើសអើងដោយសារការមានមេរោគអេដស៍។ ច្បាស់មិនហាមប្រាមច្បាស់ លើការរើសអើងក្នុងការងារ ដោយសារភេទនៃមនុស្សដែលគេស្រឡាញ់ និង/ឬអត្តសញ្ញាណជេនឌ័រ អាយុ ភាសា និងជំងឺឆ្លងទេ។ រដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋខ្មែរទាំងពីរភេទទទួលបានប្រាក់ខែស្មើគ្នា ចំពោះការងារស្មើគ្នា។

ជាទូទៅ រដ្ឋាភិបាលគ្មានសមត្ថភាពក្នុងការពង្រឹងការអនុវត្តច្បាប់ទាំងនេះទេ។ ទណ្ឌកម្មនៅក្រោមច្បាប់ លើការរើសអើងក្នុងការងាររួមមានការពិន័យជាប្រាក់ សំណងរដ្ឋបាល និងស៊ីវិល ។ ការពិន័យចំពោះការរើសអើងនៅកន្លែងការងារមានពី ២,៥ លានរៀល (៦២៥ ដុល្លា) ដល់ ៣,៦ លានរៀល (៩០០ ដុល្លា) ។ កម្មវិធីរោងចក្រល្អនៅកម្ពុជា (BFC) បាននិយាយថា នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ថៅកែរោងចក្រច្រើនតែមានការរើសអើងទៅលើបុរស ក្នុងការជ្រើសរើសអោយមកធ្វើការ និងក្នុងការផ្តល់អត្ថប្រយោជន៍ ហើយជាទូទៅ ទង្វើនេះគ្មានទទួលផលវិបាកទេ។ របាយការណ៍របស់ BFC ពីខែឧសភា ឆ្នាំ ២០១៥ ដល់ខែមេសា បានរកឃើញអត្រានៃការរើសអើងក្នុងការងារ តាមភេទ ចំនួន ១០%។ មានហេតុផលផ្សេងៗគ្នាចំពោះការរើសអើងនេះ រាប់ពីការដែលរោងចក្រមិនចង់រើសបុរសធ្វើការ ដោយសារគេគិតថា បុរសច្រើនបង្កបញ្ហា ហើយហេតុផលនៃការរើសអើងលើនារីគឺការអាចមានផ្ទៃពោះ និងការសំរាកមាតុភាព។ អង្គការ ILO បានកត់សំគាល់ដោយក្តីកង្វល់នូវសេចក្តីរាយការណ៍ស្តីពីការរើសអើងប្រឆាំងសហជីពដោយនិយោជក តាមរយៈការជ្រៀតជ្រែក និងការបណ្តេញសមាជិកនៃសហជីពឯករាជ្យចេញពីការងារ និងតាមរយៈការបង្កើតសហជីពដែលគាំទ្រដោយថៅកែ។ អង្គការ ILO បានអំពាវនាវអោយមានការកែប្រែច្បាប់ ដើម្បីអោយមានការផ្តល់ការការពារគ្រប់គ្រាន់ប្រឆាំងនឹងការរើសអើងទៅលើសហជីព និងទណ្ឌកម្មគ្រប់គ្រាន់ល្មមដើម្បីកុំអោយមានការប្រព្រឹត្តល្មើស។

## ង. លក្ខខ័ណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់ផ្តល់អោយសហជីពការងារនូវអំណាចក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរិមា ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាការងារ ដែលជាក្រុមមានសមាសភាពមកពីភាគីបី គឺតំណាងរដ្ឋាភិបាល សហជីព និងថៅកែ។ នៅខែតុលា គណៈកម្មាធិការបានប្រកាសថា ប្រាក់ឈ្នួលអប្បបរិមាថ្មីសំរាប់កម្មករកាត់ដេរ ក្នុងឆ្នាំ ២០១៧ នឹងឡើងដល់ចំនួន ៦២៥ ៥០០ រៀល (១៥៦ ដុល្លា) ពីចំនួនបច្ចុប្បន្ន ដែលមាន ៥៦០ ០០០ រៀល (១៤០ ដុល្លា) ក្នុងមួយខែ ដោយផ្អែកលើការងារចំនួន ៤៨ ម៉ោងក្នុងមួយសប្តាហ៍។ ច្បាប់មិនកំណត់អោយមានប្រាក់ឈ្នួលអប្បបរិមាសំរាប់វិស័យផ្សេងទៀតទេ។

ច្បាប់ចែងពីការងារជាបទដ្ឋានក្នុងមួយសប្តាហ៍មាន ៤៨ ម៉ោង ហើយមិនត្រូវលើសពី ៨ ម៉ោងក្នុងមួយថ្ងៃទេ។ ច្បាប់កំណត់អត្រា ១៣០% នៃប្រាក់ឈ្នួលពេលថ្ងៃសំរាប់ការងារពេលយប់ ហើយនិង ១៥០% សំរាប់ការងារលើសម៉ោង ដែលឡើងដល់ ២០០% បើសិនជាការងារលើសម៉ោងនោះធ្វើនៅពេលយប់ នៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ។ និយោជិតត្រូវបានអនុញ្ញាតអោយធ្វើការលើសម៉ោងចំនួន ២ ម៉ោងយ៉ាងច្រើន ក្នុងមួយថ្ងៃ។ ច្បាប់ហាមប្រាមការធ្វើការលើសម៉ោងជ្រុល និយាយថា ការងារលើសម៉ោងត្រូវធ្វើតែក្នុងលក្ខណៈស្ម័គ្រចិត្ត ហើយចែងពីការឈប់សំរាកប្រចាំឆ្នាំ ដោយមានប្រាក់ខែ។ កន្លែងធ្វើការគួរមានស្តង់ដារសុខភាព និងសុវត្ថិភាពគ្រប់គ្រាន់ដើម្បីផ្តល់សុខមាលភាពដល់កម្មករ-និយោជិត។ ច្បាប់មានចែងអំពីការពិន័យដែរ ហើយរោងចក្រត្រូវបានពិន័យទៅតាមរូបមន្តស្មុគស្មាញ ដោយអាស្រ័យលើកំរិតនៃបទល្មើស។ អធិការកិច្ចរបស់ក្រសួងការងារមានអំណាចវាយតំលៃការពិន័យនៅនឹងកន្លែង ដោយគ្មានការធ្វើសហប្រតិបត្តិការចាំបាច់របស់នគរបាលឡើយ ប៉ុន្តែគ្មានបទប្បញ្ញត្តិជាក់លាក់ដើម្បីការពារកម្មករ-និយោជិត ដែលតវ៉ាអំពីលក្ខខ័ណ្ឌគ្មានសុវត្ថិភាព ឬប៉ះពាល់ដល់សុខភាពឡើយ។

រដ្ឋាភិបាលមិនបានអនុវត្តច្បាប់ទំលាប់ស្តីពីម៉ោងការងារ និងការងារលើសម៉ោងប្រកបដោយប្រសិទ្ធភាពឡើយ។ កម្មករ-និយោជិតបាននិយាយថា ជារឿយៗ ការងារថែមម៉ោងមានចំនួនលើសលុបពេក ហើយពេលខ្លះជាការតម្រូវឱ្យធ្វើតែម្តង។ នៅក្រៅពីឧស្សាហកម្មកាត់ដេរ បទប្បញ្ញត្តិស្តីពីម៉ោងការងារកម្រត្រូវបានអនុវត្តណាស់។ និយោជកច្រើនតែបង្ខិតបង្ខំឱ្យនិយោជិតធ្វើការងារ។ ជារឿយៗ បុគ្គលិកកម្មករប្រឈមមុខនឹងការពិន័យ ការបណ្តេញចេញពីការងារ ឬការបាត់បង់ប្រាក់ឧបត្ថម្ភ ប្រសិនបើពួកគេបដិសេធមិនធ្វើការងារថែមម៉ោង។

រដ្ឋាភិបាលបានពង្រឹងការអនុវត្តស្តង់ដារដែលត្រូវបានកំណត់ មិនបានខ្ជាប់ខ្ជួនទេ ម្យ៉ាងដោយសារខ្វះបុគ្គលិកដែលមានជំនាញ និងខ្វះឧបករណ៍។មន្ត្រីក្រសួងការងារបានសារភាពពីអសមត្ថភាពរបស់គេ នៅក្នុងការធ្វើអធិការកិច្ចលើម៉ោងការងារ។ នាយកដ្ឋានអធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញការព្រមានចំនួន ១៨៣ ស្តីពីការរំលោភ នៅក្នុងរយៈពេល ៦ ខែដំបូង បើប្រៀបធៀបទៅនៅក្នុងពេលដូចគ្នានេះក្នុងឆ្នាំ ២០១៥ មានការចេញការព្រមានចំនួន ១៩៧ ដង។ នាយកដ្ឋានថែមទាំងបានធ្វើការពិន័យលើក្រុមហ៊ុន/រោងចក្រចំនួន ១៩ ចំណែកនៅឆ្នាំ ២០១៥ មានការពិន័យលើក្រុមហ៊ុន/រោងចក្រចំនួន ២៩។ ថ្វីបើក្រសួងបាននិយាយថា ខ្លួនមានអធិការកិច្ចការងារចំនួន ៤៩៩ នាក់ក្តី តែការខ្វះថវិកា អំពើពុករលួយជាទូទៅ និងការដាក់ទណ្ឌកម្មមិនគ្រប់គ្រាន់ចំពោះការរំលោភលើច្បាប់ការងារគឺជាឧបសគ្គដល់ការពង្រឹងការអនុវត្តច្បាប់របស់រដ្ឋាភិបាល។ ដោយលើកឡើងពីកង្វះធនធានមនុស្ស និងថវិកា ក្រសួងមិនបានធ្វើអធិការកិច្ចបានទៀងទាត់ និងគ្រប់គ្រាន់ នៅតាមរោងចក្រទេ។ ថ្វីបើជាញឹកញាប់ ក្រសួងច្រើនសំរេចអោយខាងនិយោជិតឈ្នះយ៉ាងណាក្តី តែក្រសួងកម្រប្រើអំណាចតាមផ្លូវច្បាប់របស់ខ្លួន ដើម្បីដាក់ពិន័យលើថៅកែដែលមិនគោរពបទបញ្ជារបស់ខ្លួនណាស់។ ឧទាហរណ៍ ក្នុងចំណោមសហគ្រាសចំនួន ១៨៣ ដែលបានទទួលការព្រមានទាក់ទងនឹងការរំលោភច្បាប់ការងារ ពីក្រសួងកាលពីឆ្នាំទៅ មានតែសហគ្រាសចំនួន ១៩ តែ ដែលត្រូវបានពិន័យ។

បញ្ហាសុខភាព និងរបួសដោយសារការងារមានច្រើន។ រោងចក្រកាត់ដេរធំៗភាគច្រើនដែលផលិតសំរាប់ទីផ្សារនៅក្នុងប្រទេសអភិវឌ្ឍន៍ បំពេញបានច្រើនគួរសមទៅនឹងបទដ្ឋានសុវត្ថិភាព និងសុខភាព ដែលជាលក្ខខ័ណ្ឌនៃកុងត្រារបស់គេជាមួយអ្នកទិញ។ លក្ខខ័ណ្ឌការងារនៅតាមរោងចក្រតូចៗខ្លះ និងនៅតាមរោងសិប្បកម្មមិនល្អទេ ហើយច្រើនតែមិនបំពេញបានតាមបទដ្ឋានអន្តរជាតិ។ មូលនិធិជាតិសន្តិសុខសង្គម (NSSF) បាននិយាយថា នៅក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំរបាយការណ៍ មានកម្មកររបួសទាក់ទងនឹងការងារចំនួន ១៦ ០៨០ នាក់ ហើយមានស្លាប់ចំនួន ៨៤ នាក់។ ក្នុងចំណោមអ្នកស្លាប់ទាំង ៨៤ នាក់នេះ NSSF បាននិយាយថា ៦៦ នាក់បានស្លាប់នៅក្នុងគ្រោះថ្នាក់ចរាចរ។ NSSF មិនបានបង្ហាញរបាយការណ៍របស់ខ្លួនស្តីពីការពិន័យ ឬការប្តឹងប្រឆាំងនឹងសហគ្រាសទេ។

នៅក្នុងរបាយការណ៍របស់ខ្លួនដែលគ្របដណ្តប់លើរយៈពេលពីខែឧសភា ឆ្នាំ ២០១៥ដល់ខែមេសា កម្មវិធី BFC បាននិយាយថា ផ្នែកជាច្រើនទាក់ទងនឹងសុខភាព និងសុវត្ថិភាពក្នុងការងារ នៅតែជាបញ្ហាប្រឈមមួយសំរាប់រោងចក្រកាត់ដេរ ហើយច្រើនតែជាលទ្ធផលនៃកង្វះគោលនយោបាយ និតិវិធី និងការបែងចែកតួនាទី និងការទទួលខុសត្រូវសមស្រប។ កម្មវិធី BFC បានរាយការណ៍ថា នៅតាមរោងចក្រចំនួន

១៨៤ ដែលត្រូវជាចំនួន ៥០% នៃរោងចក្រនាំចេញ សារធាតុគីមី និងសារធាតុពុលត្រូវបានគេសរសេរស្លាកសញ្ញា ទុកដាក់ មិនបានត្រឹមត្រូវ ហើយប៉ះពាល់ដល់កម្មករ។ BFC បានកត់សំគាល់ឃើញថា មានរោងចក្រចំនួន ១០៩ មិនបានធ្វើការហ្វឹកហាត់សំរាប់បង្ការគ្រាអាសន្ន រាល់រយៈពេល ៦ ខែម្តង តាមការតម្រូវនៃច្បាប់ឡើយ។

ការដួលសន្លប់យ៉ាងច្រើននៅតែជាបញ្ហាមួយ។ មូលនិធិជាតិសន្តិសុខសង្គម (NSSF)បាននិយាយថា សំរាប់រយៈពេល ៦ ខែដំបូង មានកម្មករចំនួន 285 នាក់បានដួលសន្លប់នៅតាមរោងចក្រចំនួន 6 នៅទូទាំងប្រទេស ក្នុងពេលដែលពួកគេកំពុងបំពេញការងារ។ ចំនួននេះថយចុះចំនួន ៤៧% ពីចំនួន ៥៣៨ នាក់ ដែលបានសន្លប់នៅក្នុងរយៈពេលដូចគ្នានេះ ក្នុងឆ្នាំ ២០១៥។ គ្មានរបួសធ្ងន់ធ្ងរដោយសារសន្លប់ត្រូវបានរាយការណ៍មកទេ។ អ្នកសង្កេតការណ៍បាននិយាយថា ការងារច្រើនពេក សុខភាពមិនល្អ ការដេកមិនគ្រប់គ្រាន់ ខ្យល់អាកាសចេញចូលមិនល្អ កង្វះអាហារូបត្ថម្ភសមរម្យសំរាប់កម្មករ និងចំហាយពុលពីផលិតកម្មបានរួមចំណែកអោយមានសន្លប់ច្រើនគ្នា។ លើសពីនេះទៀត ការធ្វើដំណើរទៅធ្វើការក៏មានគ្រោះថ្នាក់សំរាប់កម្មកររោងចក្រដែរ។ របាយការណ៍របស់ NSSF បានបញ្ជាក់ថា នៅឆ្នាំ ២០១៥ មានគ្រោះថ្នាក់ចំនួន ៦ ៤៩១ ទៅលើកម្មករចំនួន ៧៣៥៧ នាក់ ដោយក្នុងនោះ កម្មករចំនួន ១៣០ នាក់បានស្លាប់ ហើយ ១០៦៨ នាក់ទៀតបានរងរបួសធ្ងន់។